ធនាគារជាតិនៃកម្ពុជា
ប្រាក់រៀល ស្ថិរភាព អភិវឌ្ឍន៍



# ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ

២០២២

# មាតិកា


**អារម្ភកថា** .................... i

**អក្សរកាត់** .................... iii

**ខ្លឹមសារសង្ខេប** .................... vi

**ទស្សនវិស័យ និងហានិភ័យ** .................... ix

**I. ស្ថានភាពនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច** .................... ១

១.១ ស្ថានភាពវិស័យខាងក្រៅ .................... ១

ក. សេដ្ឋកិច្ចពិភពលោក .................... ១

ខ. ជញ្ជីងទូទាត់កម្ពុជា .................... ៣

ខ.១ គណនីចរន្ត .................... ៣

ខ.២ គណនីហិរញ្ញវត្ថុ .................... ៤

គ. អត្រាប្តូរប្រាក់ និងទុនបម្រុងអន្តរជាតិ .................... ៥

១.២ ស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក .................... ៧

ក. កំណើនសេដ្ឋកិច្ច .................... ៧

ខ. ស្ថានភាពអតិផរណា និងរូបិយវត្ថុ .................... ១០

ប្រអប់ ១.១: កត្តាជំរុញអតិផរណានៅកម្ពុជាក្នុងឆ្នាំ២០២២ និងតួនាទីនៃស្ថិរភាពអត្រាប្តូរប្រាក់នៅក្នុងសេដ្ឋកិច្ចដុល្លារូបនីយកម្ម .................... ១២

គ. វិស័យសារពើពន្ធ .................... ១៤

១.៣ សន្និដ្ឋាន .................... ១៥

**II. ប្រព័ន្ធធនាគារ៖ ប្រតិបត្តិការ និងស្ថិរភាព** .................... ១៧

២.១ ទិដ្ឋភាពប្រព័ន្ធធនាគារ .................... ១៨

២.២ គ្រឹះស្ថានធនាគារពាណិជ្ជ .................... ២០

ក. អន្តរការិយកម្មឥណទាន និងហានិភ័យឥណទាន .................... ២០

ខ. មូលនិធិ និងសន្ទនីយភាព .................... ២៧

គ. លទ្ធភាពស្វែងរកប្រាក់ចំណេញ .................... ២៩

ប្រអប់ ២.១: យុទ្ធសាស្ត្រចាកចេញពីវិបត្តិរបស់ធនាគារជាតិនៃកម្ពុជា៖ ការធ្វើប្រក្រតីកម្មវិធានការគាំទ្រដែលដាក់ចេញក្នុងវិបត្តិកូវីដ-១៩ .................... ៣៣

២.៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ .................... ៣៥

ក. ប្រតិបត្តិការឥណទាន .................... ៣៥

ខ. គុណភាពឥណទាន .................... ៣៧

គ. ស្ថានភាពសន្ទនីយភាព និងមូលនិធិ .................... ៣៨

ឃ. លទ្ធភាពស្វែងរកប្រាក់ចំណេញ .................... ៣៩

ង. ស្ថានភាពដើមទុន .................... ៤០

២.៤ គ្រឹះស្ថានធនាគារឯកទេស .................... ៤១

២.៥ សន្និដ្ឋាន .................... ៤២

**III. វិស័យហិរញ្ញវត្ថុមិនមែនធនាគារ**..........៤៤
៣.១ ទីផ្សារទ្រព្យសកម្ម..........៤៤
ក. ទីផ្សារមូលបត្រកម្មសិទ្ធិ..........៤៤
ខ. ទីផ្សារមូលបត្របំណុល..........៤៦
- មូលបត្ររដ្ឋ..........៤៦
- សញ្ញាបណ្ណសាជីវកម្ម..........៤៧
៣.២ វិស័យធានារ៉ាប់រង..........៤៨
៣.៣ សន្និដ្ឋាន..........៥០
ប្រអប់ ៣.១: ការវិភាគតារាងតុល្យការ..........៥១
**IV. ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់**..........៥៣
**ឧបសម្ព័ន្ធទី១**..........៥៧
**ឧបសម្ព័ន្ធទី២**..........៦១
**ឧបសម្ព័ន្ធទី៣**..........៦៧
**ឧបសម្ព័ន្ធទី៤**..........៧២

## អារម្ភកថា

ឆ្នាំ២០២២ បានចាប់ផ្តើមប្រកបដោយសុទិដ្ឋិនិយម ជាមួយការងើបឡើងសន្សឹមៗនៃសេដ្ឋកិច្ចរបស់បណ្តាប្រទេសនានា ក្រោយពីបានបើកប្រទេសពេញលេញឡើងវិញ បន្ទាប់ពីករណីឆ្លងជំងឺកូវីដ-១៩ បានធូរស្បើយ។ ប៉ុន្តែ មិនយូរប៉ុន្មាន សុទិដ្ឋិនិយមនេះ បានថមថយវិញដោយភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយរវាងរុស្ស៊ីនិងអ៊ុយក្រែន ដែលបានធ្វើឱ្យថ្លៃប្រេងនិងម្ហូបអាហារនៅលើទីផ្សារអន្តរជាតិកើនឡើងខ្លាំង និងនាំឱ្យអតិផរណាសកលកើនឡើងជាទូទៅ។ ការណ៍នេះបានធ្វើឱ្យធនាគារកណ្តាលត្រូវប្រឈមនឹងបញ្ហាលំបាកក្នុងការរក្សាស្ថិរភាពថ្លៃ ក៏ដូចជាគាំទ្រដល់កំណើនសេដ្ឋកិច្ច។ ប្រទេសអភិវឌ្ឍន៍ជាច្រើនបានរឹតបន្តឹងនយោបាយរូបិយវត្ថុ ដែលនាំឱ្យមានលំហូរមូលធនចេញពីប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ ការធ្លាក់ចុះតម្លៃរូបិយប័ណ្ណនៃប្រទេសជាច្រើន ការធ្លាក់ចុះទុនបម្រុងអន្តរជាតិ និងការកើនឡើងអត្រាការប្រាក់ ដែលនាំឱ្យប៉ះពាល់ដល់ទស្សនវិស័យនៃកំណើនសេដ្ឋកិច្ចពិភពលោកនិងតំបន់។

សេដ្ឋកិច្ចកម្ពុជាក៏បានទទួលរងសម្ពាធផងដែរ ជាមួយនឹងអត្រាអតិផរណាខ្ពស់បំផុតក្នុងរយៈពេលជាងមួយទសវត្សរ៍ចុងក្រោយ ប៉ុន្តែអាចសម្រេចបានអត្រាកំណើន ៥,២% សម្រាប់ឆ្នាំ២០២២ ដោយសារភាពល្អប្រសើរនៃការនាំចេញក្នុងអំឡុងឆមាសទី១ និងការងើបឡើងឆាប់រហ័សនៃវិស័យទេសចរណ៍ និងសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក។ ការងើបឡើងនៃសេដ្ឋកិច្ចក៏មានការរួមចំណែកដោយភាពធន់នៃប្រព័ន្ធធនាគារ ដែលបានបំពេញតួនាទីអន្តរការីយ៉ាងសកម្មក្នុងការកៀរគរ និងបែងចែកមូលនិធិទៅកាន់វិស័យផលិតភាពផ្សេងៗ សំដៅគាំទ្រដល់ការវិនិយោគនិងការប្រើប្រាស់ក្នុងស្រុក។ សូចនាករភាពរឹងមាំវិស័យហិរញ្ញវត្ថុ ដូចជា ស្ថានភាពសាធនភាព សន្ទនីយភាព និងគុណភាពនៃទ្រព្យសកម្ម បានឆ្លុះបញ្ចាំងពីភាពធន់និងស្ថិរភាពនៃប្រព័ន្ធធនាគារកម្ពុជា ដែលបានឆ្លងកាត់ដោយជោគជ័យនូវការប៉ះទង្គិចជាច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ទោះយ៉ាងណា ហានិភ័យនៅតែមាន ដោយសារការអូសបន្លាយនៃភាពតានតឹងនិងការបែងចែកភូមិសាស្ត្រនយោបាយ ភាពមិនច្បាស់លាស់ជុំវិញអត្រាអតិផរណាសកលនិងការដំឡើងអត្រាការប្រាក់នាពេលខាងមុខ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងហានិភ័យនៃការបំប្លែងខ្លួនថ្មីរបស់វីរុសកូវីដ-១៩។ ឆ្លើយតបនឹងបញ្ហាប្រឈមទាំងនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តតាមដានយ៉ាងយកចិត្តទុកដាក់នូវការវិវត្តសេដ្ឋកិច្ចនិងហានិភ័យដែលអាចកើតមានចំពោះប្រព័ន្ធធនាគារ និងចាត់វិធានការចាំបាច់ប្រកបដោយស្មារតីបុរេសកម្ម ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ។

សៀវភៅរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុឆ្នាំ២០២២ បង្ហាញពីកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់ធនាគារជាតិនៃកម្ពុជាក្នុងការត្រួតពិនិត្យ និងផ្សព្វផ្សាយព័ត៌មាន ស្តីពីស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា។ របាយការណ៍នេះ ផ្តោតលើការអភិវឌ្ឍនិងបញ្ហាប្រឈមថ្មីៗ ជាពិសេសនៅក្នុងប្រព័ន្ធធនាគារ ដោយលើកឡើងពីហានិភ័យដែលអាចកើតមាន និងវិធានការក្នុងការបង្ការ ឬកាត់បន្ថយហានិភ័យ។ របាយការណ៍ ក៏ពិពណ៌នាអំពីការអភិវឌ្ឍសេដ្ឋកិច្ចទូទៅ ដោយរួមបញ្ចូលទាំងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងប្រព័ន្ធទូទាត់កម្ពុជាផងដែរ។ ខ្ញុំជឿជាក់ថារបាយការណ៍នេះនឹងផ្តល់ដល់គ្រប់ភាគីពាក់ព័ន្ធ និងសាធារណជនទូទៅ នូវការយល់ដឹងបន្ថែមទៀតអំពីការអភិវឌ្ឍសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិ ហើយអាចត្រៀមខ្លួនបានកាន់តែប្រសើរ ចំពោះបញ្ហាប្រឈមដែលអាច

កើតមាននាពេលខាងមុខ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ចំពោះកិច្ចខិតខំប្រឹងប្រែង និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ និងរួមចំណែកឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣

ទេសាភិបាល

ជា.ចាន់តូ

# អក្សរកាត់

| | | |
|---|---|---|
| ABC | ធនាគារអេស៊ីលីដា | ACLEDA Bank Plc. |
| AFT | បរធនបាលកិច្ចហិរញ្ញវត្ថុអេស៊ីលីដា | ACLEDA Financial Trust |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) | Association of Southeast Asian Nations |
| BoP | សមតុល្យជញ្ជីងទូទាត់ | Balance of Payment |
| CAR | អនុបាតសាធនភាព | Capital Adequacy Ratio |
| CCB | ទ្រនាប់ដើមទុនខនស៊ើវេសិន | Capital Conservation Buffers |
| CCyB | អនុបាតទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល | Countercyclical Capital Buffer |
| CSS | ប្រព័ន្ធខេមបូឌានស៊ែស្វីច | Cambodian Shared Switch |
| CSX | ផ្សារមូលបត្រកម្ពុជា | Cambodia Security Exchange |
| DBDE | ឌីប៊ីឌី អ៊ិនជីនារីង ម.ក | DBD Engineering Plc. |
| EMP | សម្ពាធទីផ្សារប្តូរប្រាក់ | Exchange Market Pressure |
| FDI | វិនិយោគផ្ទាល់បរទេស | Foreign Direct Investment |
| FSR | របាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ | Financial Stability Review |
| FTAs | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី | Free Trade Agreements |
| GDP | ផលិតផលក្នុងស្រុកសរុប | Gross Domestic Production |
| GFC | វិបត្តិហិរញ្ញវត្ថុសកល | Global Financial Crisis |
| GTI | ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី | Grand Twins International (Cambodia) Plc. |
| IPO | ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | Initial Public Offering |
| JSL | ជេអេស លែន ភីអ៊ិលស៊ី | JS LAND PLC |
| LCR | អនុបាតគ្របខ័ណ្ឌសន្ទនីយភាព | Liquidity Coverage Ratio |
| LVPS | ប្រព័ន្ធទូទាត់តម្លៃធំ | Large Value Payment System |
| M2 | រូបិយវត្ថុទូទៅ | Broad Money |
| MDI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | Microfinance Deposit-Taking Institution |
| MEF | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | Ministry of Economy and Finance |

| | | |
|---|---|---|
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | Microfinance Institution |
| MSME | សហគ្រាសធុនមីក្រូ តូច និងមធ្យម | Micro, Small and Medium Enterprise |
| NBC | ធនាគារជាតិនៃកម្ពុជា | National Bank of Cambodia |
| NCS | ប្រព័ន្ធផាត់ទាត់ជាតិ | National Clearing System |
| NEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាម | Nominal Effective Exchange Rate |
| NFC | គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ | Non-Financial Corporations |
| NGO | អង្គការក្រៅរដ្ឋាភិបាល | Non-Governmental Organization |
| NPL | ឥណទានមិនដំណើរការ | Non-Performing Loan |
| NPLR | អនុបាតឥណទានមិនដំណើរការ | Non-Performing Loan Ratio |
| OBS | ប្រព័ន្ធធនាគារអនឡាញ | Online Banking System |
| ODC | គ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត | Other Depository Corporations |
| PAS | កំពង់ផែស្វយ័តក្រុងព្រះសីហនុ | Sihanoukville Autonomous Port |
| PESTECH | ផេសថិច (ខេមបូឌា) ម.ក | PESTECH (Cambodia) Plc. |
| PPAP | កំពង់ផែស្វយ័តក្រុងភ្នំពេញ | Phnom Penh Autonomous Port |
| PPSP | ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី | Royal Group Phnom Penh SEZ Plc. |
| PPWSA | រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | Phnom Penh Water Supply Authority |
| RCEP | កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ | Regional Comprehensive Partnership Agreement |
| REER | អត្រាប្តូរប្រាក់មានប្រសិទ្ធភាពពិត | Real Effective Exchange Rate |
| ROA | អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម | Return on Assets |
| ROE | អនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក | Return on Equity |
| RPPI | សន្ទស្សន៍ថ្លៃលំនៅដ្ឋាន | Residential Property Price Index |

| | | |
|---|---|---|
| RRR | អត្រាប្រាក់បម្រុងកាតព្វកិច្ច | Reserve Requirement Ratio |
| SOE | សហគ្រាសរដ្ឋ | State-Owned Enterprise |
| SME | សហគ្រាសធុនតូច និងមធ្យម | Small and Medium Enterprise |
| SOFR | អត្រាហិរញ្ញប្បទានអូវើណាយដោយមានការធានា | Secured Overnight Financing Rate |
| SREP | វិធីសាស្រ្តស្រេប | Supervisory Review and Evaluation Process |

# ខ្លឹមសារសង្ខេប

**សេដ្ឋកិច្ចពិភពលោកបានថមថយល្បឿនគួរឱ្យកត់សម្គាល់នៅឆ្នាំ២០២២ ដោយសារភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយរវាងរុស្ស៊ីនិងអ៊ុយក្រែន អត្រាអតិផរណាខ្ពស់ និងការរឹតត្បិតនយោបាយរូបិយវត្ថុ ប៉ុន្តែកំណើនសេដ្ឋកិច្ចក្នុងតំបន់មានភាពរឹងមាំ។** កំណើនសេដ្ឋកិច្ចពិភពលោករួមទាំងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ បានថយចុះពី ៦,២% នៅឆ្នាំ២០២១ មក ៣,៤%។ ដោយឡែក កំណើនសេដ្ឋកិច្ចតំបន់អាស៊ានបានកើនឡើងពី ៣,១% នៅឆ្នាំ២០២១ ដល់ ៥,៦% នៅឆ្នាំ២០២២ ដែលគាំទ្រដោយការកើនឡើងនៃការនាំចេញ ការវិលត្រឡប់ទៅរកភាពប្រក្រតីនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងវិស័យទេសចរណ៍ បន្ទាប់ពីជំងឺកូវីដ-១៩មានភាពធូរស្រាល។

**ដូចទៅនឹងប្រទេសផ្សេងទៀតក្នុងតំបន់អាស៊ានដែរ សេដ្ឋកិច្ចកម្ពុជាមានកំណើនរឹងមាំក្នុងអត្រា ៥,២% នៅឆ្នាំ២០២២ ខ្ពស់ជាងកំណើន ៣% នៅឆ្នាំ២០២១។** កំណើននេះត្រូវបានគាំទ្រជាចម្បងដោយភាពល្អប្រសើរនៃការនាំចេញសម្លៀកបំពាក់និងផលិតផលកម្មន្តសាលផ្សេងទៀត និងសន្ទុះលឿនជាងការរំពឹងទុកក្នុងវិស័យទេសចរណ៍ និងពាណិជ្ជកម្មលក់ដុំនិងរាយ។ អតិរេកជញ្ជីងទូទាត់បានកើនឡើងពី ០,៣% ដល់ ១,២% នៃផ.ស.ស. ដោយសារលំហូរវិនិយោគផ្ទាល់បរទេសកើនឡើង ២,៧%រួមជាមួយនឹងភាពប្រសើរឡើងនៃឱនភាពពាណិជ្ជកម្មទំនិញ និងការស្ទុះងើបឡើងវិញនៃប្រាក់បង្វែរពីក្រៅប្រទេស និងចំណូលពីវិស័យទេសចរណ៍។

**ទោះបីជាប្រាក់ដុល្លារអាមេរិកបានឡើងថ្លៃខ្លាំងនៅលើទីផ្សារអន្តរជាតិក៏ដោយ អត្រាប្តូរប្រាក់រៀលបន្តមានស្ថិរភាព ហើយទុនបម្រុងអន្តរជាតិស្ថិតក្នុងកម្រិតខ្ពស់គ្រប់គ្រាន់។** អត្រាប្តូរប្រាក់មានកម្រិតជាមធ្យម ៤.១០២ រៀលក្នុងមួយដុល្លារអាមេរិក នៅឆ្នាំ២០២២ ដោយបានធ្លាក់ចុះបន្តិច ១% ធៀបនឹងឆ្នាំ២០២១។ ទោះជាយ៉ាងណា អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតបានឡើងថ្លៃ ៣,៥% ធៀបនឹងដៃគូពាណិជ្ជកម្មសំខាន់ៗ ដោយសាររូបិយប័ណ្ណជាច្រើនបានធ្លាក់ថ្លៃធៀបនឹងប្រាក់ដុល្លារអាមេរិក ដែលការណ៍នេះអាចប៉ះពាល់ដល់ការប្រកួតប្រជែងពាណិជ្ជកម្មរបស់កម្ពុជា។ ទុនបម្រុងអន្តរជាតិបន្តស្ថិតក្នុងកម្រិតគ្រប់គ្រាន់ ដែលអាចទូទាត់ការនាំចូលទំនិញនិងសេវាកម្មក្នុងគ្រាបន្ទាប់បានប្រមាណ ៧ខែ ដែលខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (៣ខែ)។

**អត្រាអតិផរណាបានកើនឡើងពី ២,៩% នៅឆ្នាំ២០២១ ដល់ ៥,៤% ដែលជាអត្រាខ្ពស់បំផុតចាប់តាំងពីឆ្នាំ២០១១ មក។** ជាលទ្ធផលនៃការកើនឡើងនៃថ្លៃប្រេងឥន្ធនៈ និងម្ហូបអាហារនៅលើទីផ្សារពិភពលោក អតិផរណារបស់កម្ពុជាបានឡើងដល់ចំណុចខ្ពស់ នៅខែមិថុនា ឆ្នាំ២០២២ មុនពេលធ្លាក់ចុះនៅក្នុងឆមាសទីពីរ មកត្រឹមអត្រាជាមធ្យម ៥,៤%។ ក្នុងបរិការណ៍សេដ្ឋកិច្ចមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ការផ្តល់អាទិភាពដល់ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលគឺជាការចាំបាច់ដើម្បីអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាមានជម្រើសនយោបាយរូបិយវត្ថុទូលំទូលាយ។

**ស្ថានភាពសារពើពន្ធមានភាពប្រសើរឡើងជាមួយនឹងអតិរេកសារពើពន្ធ និងការថយចុះនៃអនុបាតបំណុលធៀបនឹងផ.ស.ស.។** ដោយសារការថយចុះនៃការចំណាយ និងការស្ទុះងើបឡើងវិញនៃការប្រមូលចំណូល សមតុល្យសារពើពន្ធមានអតិរេក ១,១% នៃផ.ស.ស. បន្ទាប់ពីមានឱនភាព

រយៈពេលពីរឆ្នាំជាប់ៗគ្នា ដោយសារការដាក់ចេញនូវកញ្ចប់អន្តរាគមន៍ជាច្រើន ដើម្បីកាត់បន្ថយផលប៉ះពាល់ពីវិបត្តិកូវីដ-១៩។ បំណុលសាធារណៈបានកើនឡើង ៤,៩% ប៉ុន្តែនៅបន្តមាននិរន្តរភាព ខណៈដែលកម្រិតបំណុលធៀបនឹងផ.ស.ស. បានធ្លាក់ចុះមកត្រឹម ៣៣,៩%។

**ប្រព័ន្ធធនាគាររក្សាបានភាពធន់និងរឹងមាំ ដោយបានផ្តល់មូលនិធិចាំបាច់ ដើម្បីគាំទ្រការស្តារសេដ្ឋកិច្ចឡើងវិញពីវិបត្តិកូវីដ-១៩។** ទ្រព្យសកម្ម ឥណទាន និងប្រាក់បញ្ញើសរុប បានបន្តកើនឡើង ១២,៦% ១៦,៣% និង ៩,៥% រៀងគ្នា នៅឆ្នាំ២០២២ ទោះបីជាក្នុងល្បឿនយឺតជាងឆ្នាំមុនក្តី។ នៅក្នុងប្រព័ន្ធធនាគារ ទ្រព្យសកម្មធនាគារពាណិជ្ជមានសមាមាត្រ ៨៤,៥% នៃទ្រព្យសកម្មសរុប គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមាន ១១,៨% គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមាន ២,១% និងធនាគារឯកទេសមាន ០,៩%។

**ឥណទានរបស់ធនាគារពាណិជ្ជបានកើនឡើង ១៨,១% នៅឆ្នាំ២០២២ ដល់ ១៨៣,៥ ទ្រីលានរៀល (៤៤,៦ ប៊ីលានដុល្លារអាមេរិក) ដែលភាគច្រើនផ្តល់ទៅកាន់វិស័យឯកជន។** កំណើនឥណទានមានភាពទូលំទូលាយ ដោយឥណទានទៅកាន់វិស័យភាគច្រើនកំពុងកើនឡើងក្នុងកម្រិតពីរខ្ទង់ ទោះបីជាមានល្បឿនយឺតជាងឆ្នាំ២០២១។ ឥណទានទៅកាន់វិស័យការជួញដូរាយនិងដុំមានសមាមាត្រប្រមាណ ២៧% នៃឥណទានវិស័យធនាគារ ជាមួយនឹងចំណែកឥណទានវិស័យសំណង់ និងអចលនទ្រព្យកើនដល់ ២០%។ ចំណែកឥណទានអង្គភាពគ្រួសារបានធ្លាក់ចុះបន្តិចមកត្រឹម ២២,៦% ដោយសារការឱ្យខ្ចីជាបុគ្គលបានធ្លាក់ចុះ ដែលអាចបណ្តាលមកពីឥទ្ធិពលនៃការកើនឡើងអត្រាការប្រាក់ ខណៈដែលឥណទាននៃការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួននៅបន្តកើនឡើង។

**គុណភាពទ្រព្យសកម្មជារួមនៅបន្តមានសុខភាពល្អ ជាមួយនឹងស្ថានភាពសន្ទនីយភាព និងដើមទុនរឹងមាំ។** អនុបាតឥណទានមិនដំណើរការបានស្ថិតនៅកម្រិតដែលអាចគ្រប់គ្រងបាន ទោះបីជាបានកើនឡើងពី ១,៨% នៅឆ្នាំ២០២១ ដល់ ២,៩% នៅឆ្នាំ២០២២ ដោយសារវិធានការរៀបចំឥណទានឡើងវិញបានផុតកំណត់។ ស្របពេលជាមួយគ្នានេះ អនុបាតក្របខ័ណ្ឌសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារមានកម្រិត ១៤៣,៨% លើសពីកម្រិតអប្បបរមាតាមបទប្បញ្ញត្តិ ១០០% ដែលបង្ហាញពីសុខភាពល្អនៃកម្រិតសន្ទនីយភាព ដើម្បីឆ្លើយតបនឹងតម្រូវការសន្ទនីយភាព។ អនុបាតសាធនភាពរបស់គ្រឹះស្ថានធនាគារមានកម្រិត ២២% ខ្ពស់ជាងអត្រាអប្បបរមាកំណត់ដោយធនាគារជាតិនៃកម្ពុជា ១៥% ដែលឆ្លុះបញ្ចាំងពីសមត្ថភាពស្រូបយកការខាតបង់របស់គ្រឹះស្ថានធនាគារ ដើម្បីទប់ទល់នឹងការកើតមាននូវហានិភ័យដែលមិនរំពឹងទុកណាមួយ។ ចំណែកឯប្រាក់ចំណេញសុទ្ធរបស់គ្រឹះស្ថានធនាគារបន្ទាប់ពីបង់ពន្ធបានធ្លាក់ចុះ -១១% ដោយសារការកើនឡើងកម្រិតសំវិធានធន និងការចំណាយការប្រាក់កាន់តែច្រើន។

**វិស័យមីក្រូហិរញ្ញវត្ថុបានបន្តរីកចម្រើន និងបានគាំទ្រដល់តម្រូវការហិរញ្ញប្បទានរបស់សេដ្ឋកិច្ច ជាពិសេសចំពោះអាជីវកម្មខ្នាតតូច និងសហគមន៍ជនបទ។** ទ្រព្យសកម្មសរុបបានកើនឡើង ១៨,៥% ហើយឥណទានបានកើនឡើង ២១,៥% ដែលភាគច្រើនផ្តល់ទៅអង្គភាពគ្រួសារ វិស័យពាណិជ្ជកម្មនិងជំនួញ កសិកម្ម សេវាកម្ម និងផ្សេងៗទៀត។ គុណភាពឥណទាននៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុរក្សាបានភាពល្អប្រសើរ ដោយអត្រាការសងយឺតបន្តមានស្ថិរភាពក្នុងកម្រិត ១,៥% សម្រាប់

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ៩% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។ សន្ទនីយភាពមានកម្រិតខ្ពស់គ្រប់គ្រាន់ ដោយអនុបាតក្របខ័ណ្ឌសន្ទនីយភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានអត្រា ១៥៦,៧% ដែលលើសពីកម្រិតអប្បបរមាកំណត់ដោយបទប្បញ្ញត្តិ។ ប្រាក់ចំណេញរបស់វិស័យមីក្រូហិរញ្ញវត្ថុបន្តមាននិរន្តរភាព ដែលបានរួមចំណែកដល់ភាពរឹងមាំនៃអនុបាតសាធនភាពក្នុងអត្រា ១៨,៦% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ៣១,៦% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។

**ធនាគារឯកទេសបានបង្ហាញលទ្ធផលវិជ្ជមាន ស្របតាមភាពប្រសើរឡើងនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច។** ឥណទានគ្រឹះស្ថានធនាគារឯកទេសបានកើនឡើង ១៣% ដែលភាគច្រើនជាការឱ្យខ្ចីជាបុគ្គល និងទៅកាន់វិស័យកម្មន្តសាលនិងកសិកម្ម។ ជាមួយគ្នានេះ គុណភាពឥណទានស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ដោយអនុបាតឥណទានមិនដំណើរការមានអត្រា ៨,៥% ខណៈដែលអនុបាតសាធនភាពបន្តមានភាពរឹងមាំក្នុងកម្រិត ៣១,៤%។

**វិស័យហិរញ្ញវត្ថុមិនមែនធនាគារបានអភិវឌ្ឍជាលំដាប់ ជាមួយនឹងការចុះបញ្ជីក្រុមហ៊ុនថ្មីៗបន្ថែមទៀតនៅក្នុងទីផ្សារមូលបត្រកម្មសិទ្ធិនិងទីផ្សារមូលបត្របំណុល និងការកើនឡើងនៃបុព្វលាភធានារ៉ាប់រង។** បន្ទាប់ពីបានធ្លាក់ចុះនៅឆ្នាំ២០២១ សន្ទស្សន៍ផ្សារហ៊ុនកម្ពុជា (CSX) និងមូលធនូបនីយកម្មទីផ្សារបានកើនឡើងបន្តិចដល់ ៤៨៣,៧ សន្ទស្សន៍ និង ៧,៥ ទ្រីលានរៀល (១,៨ ប៊ីលានដុល្លារអាមេរិក) រៀងគ្នា។ ទីផ្សារមូលបត្របំណុលក៏បានបន្តរួមចំណែកក្នុងការផ្តល់នូវប្រភពហិរញ្ញប្បទានជារូបិយវត្ថុជាតិ ទាំងសម្រាប់វិស័យសាធារណៈនិងឯកជន។ ទំហំសញ្ញាបណ្ណសាជីវកម្មមិនទាន់ដល់ឥណប្រតិទានសរុបមានចំនួន ៥១៥ ប៊ីលានរៀល (១២៥,១ លានដុល្លារអាមេរិក) ដែលក្នុងនោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានសមាមាត្រ ៩០,៩%។ ជាមួយគ្នានេះ វិស័យធានារ៉ាប់រងបានបន្តកត់ត្រាកំណើនរឹងមាំ ដោយបុព្វលាភធានារ៉ាប់រងសរុបសម្រាប់អនុវិស័យទាំងអស់ រួមមាន ធានារ៉ាប់រងទូទៅ ធានារ៉ាប់រងអាយុជីវិត និងធានារ៉ាប់រងខ្នាតតូច បានកើនឡើងដល់ ១,៤ ទ្រីលានរៀល (៣៣១,៩ លានដុល្លារអាមេរិក)។

**ការអភិវឌ្ឍប្រព័ន្ធទូទាត់បានលើកកម្ពស់ប្រសិទ្ធភាព អន្តរប្រតិបត្តិការ និងបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។** ការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកបន្តកើនឡើងគួរឱ្យកត់សម្គាល់ ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានអភិវឌ្ឍសេវាកម្មទូទាត់ឌីជីថលប្រកបដោយភាពច្នៃប្រឌិត ដើម្បីគាំទ្រដល់កំណើនតម្រូវការនៅក្នុងប្រក្រតីកម្មថ្មី។ ជាក់ស្តែង ចំនួនគណនីកាបូបអេឡិចត្រូនិកបានកើនឡើងដល់ ១៩,៥ លានគណនី ហើយទំហំនៃការទូទាត់រាយតាមប្រព័ន្ធអេឡិចត្រូនិកបានកើនដល់ជាង ៩ ដង នៃផ.ស.ស.។ ទន្ទឹមនេះ ការប្រើប្រាស់សេវាធនាគារចល័តបានកើនឡើងជាលំដាប់ ស្របតាមនិន្នាការកើនឡើងនៃចំនួនទូរសព្ទឆ្លាតវៃ និងអត្រាប្រើប្រាស់អ៊ីនធឺណិត។ ចំណែកឯប្រតិបត្តិការទូទាត់តាមរយៈប្រព័ន្ធបាគង និងឃ្យូអរកូដ (QR Code) បានកើនឡើងខ្ពស់ដែលឆ្លុះបញ្ចាំងពីការកើនឡើងនៃការចាប់អារម្មណ៍ និងការប្រើប្រាស់របស់សាធារណជន។

## ទស្សនវិស័យ និងហានិភ័យ

**នៅឆ្នាំ២០២៣ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងបន្តងើបឡើងពីវិបត្តិកូវីដ-១៩។** សេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករថាមានកំណើន ២,៨% ក្នុងពេលដែលសេដ្ឋកិច្ចតំបន់អាស៊ានត្រូវបានរំពឹងថាកើនឡើង ៤,៩%។ អតិផរណាពិភពលោកត្រូវបានព្យាករថានឹងថយចុះមកត្រឹម ៧% ពី ៨,៧% នៅឆ្នាំ២០២២ ខណៈដែលអតិផរណាក្នុងតំបន់មានកម្រិតត្រឹម ៥,៧%។ ស្របតាមទស្សនវិស័យសេដ្ឋកិច្ចពិភពលោកនិងតំបន់ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងកើនឡើង ៥,៦% នៅឆ្នាំ២០២៣ ជាមួយនឹងអត្រាអតិផរណាក្នុងរង្វង់ ៣%។ កំណើននេះគាំទ្រជាចម្បងដោយការនាំចេញផលិតផលកាត់ដេរនិងមិនមែនកាត់ដេរ ការងើបឡើងវិញយ៉ាងឆាប់រហ័សក្នុងវិស័យទេសចរណ៍និងវិស័យពាក់ព័ន្ធ និងកំណើនរឹងមាំនៃការដឹកជញ្ជូននិងទូរគមនាគមន៍ ខណៈដែលវិស័យកសិកម្ម បើទោះបីជាមានកំណើនទាបក៏ដោយ ក៏នៅតែបន្តគាំទ្រដល់កំណើនសេដ្ឋកិច្ច។ លើសពីនេះ ការអនុវត្តកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី (FTAs) ត្រូវបានរំពឹងថានឹងជួយទាក់ទាញលំហូរវិនិយោគបន្ថែមទៀតនៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ដែលនឹងជួយជំរុញផលិតភាព និងលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ច។

**ទោះយ៉ាងណា ប្រទេសកម្ពុជាបាននិងកំពុងប្រឈមនឹងហានិភ័យមួយចំនួន ដែលភាគច្រើនបណ្តាលមកពីកត្តាខាងក្រៅ។** ការអូសបន្លាយនៃភាពតានតឹងរវាងរុស្ស៊ីនិងអ៊ុយក្រែន និងភាពរឹតត្បិតនៃស្ថានភាពហិរញ្ញវត្ថុអន្តរជាតិ អាចបណ្តាលឱ្យសកម្មភាពសេដ្ឋកិច្ចពិភពលោកថយចុះបន្ថែមទៀត ជាពិសេសនៅសហរដ្ឋអាមេរិកនិងតំបន់អឺរ៉ុប ដែលអាចប៉ះពាល់ដល់ការនាំចេញ និងលំហូរមូលធនមកកម្ពុជា។ កម្រិតអតិផរណាពិភពលោកដែលបន្តស្ថិតក្នុងកម្រិតខ្ពស់ អាចដាក់សម្ពាធលើអតិផរណាកម្ពុជាតាមរយៈផលិតផលនាំចូល។ ទោះបីជាការបើកសេដ្ឋកិច្ចប្រទេសចិនឡើងវិញអាចផាត់ទាត់ហានិភ័យនៃការធ្លាក់ចុះសកម្មភាពសេដ្ឋកិច្ចក៏ដោយ បញ្ហាដែលអូសបន្លាយក្នុងទីផ្សារអចលនទ្រព្យនៅប្រទេសចិន អាចប៉ះពាល់ដល់ការវិនិយោគក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា ដែលមួយផ្នែកពឹងផ្អែកលើលំហូរវិនិយោគផ្ទាល់ពីប្រទេសចិន។ លើសពីនេះ ការប្រែប្រួលអាកាសធាតុបង្កជាហានិភ័យចម្បងមួយសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មនិងតំបន់ជនបទ ដែលអាចប៉ះពាល់ដល់គ្រួសារក្រីក្រនិងងាយរងគ្រោះ។

**ប្រព័ន្ធធនាគារនឹងរក្សាបានភាពរឹងមាំនិងមានភាពធន់ ហើយបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រសកម្មភាពសេដ្ឋកិច្ច។** នៅអំឡុងពេលមានការរាតត្បាតនៃជំងឺកូវីដ-១៩ និងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោកក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រព័ន្ធធនាគារកម្ពុជាបានបង្ហាញពីភាពរឹងមាំ តាមរយៈកម្រិតខ្ពស់នៃសន្ទនីយភាពនិងដើមទុន។ ឥណទានត្រូវបានបែងចែកប្រកបដោយនិរន្តរភាពដល់វិស័យចម្បងៗដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច ខណៈដែលការរៀបចំឥណទានឡើងវិញបានជួយសម្រាលបន្ទុកអង្គភាពគ្រួសារ និងក្រុមហ៊ុនសហគ្រាសជាច្រើនដែលបានរងផលប៉ះពាល់។ ស្របតាមការងើបឡើងវិញនៃសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រចាកចេញពីវិបត្តិដោយប្រុងប្រយ័ត្ន ដើម្បីធានាបាននូវស្ថិរភាព និងភាពធន់នៃប្រព័ន្ធធនាគារ។ ជាទិសដៅ ប្រព័ន្ធធនាគារនឹងបន្តគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការផ្តល់ឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងទៀត ក្នុងពេលដែលប្រព័ន្ធទូទាត់ត្រូវបានធ្វើទំនើបកម្មជាលំដាប់ ស្របតាម

តម្រូវការទីផ្សារ។ ទោះយ៉ាងណា ប្រព័ន្ធធនាគារក៏ប្រឈមនឹងហានិភ័យមួយចំនួនផងដែរ។ ការរឹតត្បិតស្ថានភាពហិរញ្ញវត្ថុអន្តរជាតិ អាចបង្កើនការចំណាយលើថ្លៃដើមមូលនិធិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ហើយអាចដាក់សម្ពាធលើអត្រាការប្រាក់ក្នុងស្រុក។ ក្នុងករណីដែលសកម្មភាពសេដ្ឋកិច្ចថយចុះដោយសារហានិភ័យខាងក្រៅដែលបានរៀបរាប់ខាងលើ ការណ៍នេះនឹងប៉ះពាល់ដល់ប្រាក់ចំណូលរបស់អង្គភាពគ្រួសារនិងក្រុមហ៊ុនសហគ្រាស ដែលនឹងជះឥទ្ធិពលដល់សមត្ថភាពសងបំណុលផងដែរ។ ទន្ទឹមនេះ ដោយសារសមាមាត្រធំនៃឥណទានទៅកាន់វិស័យសំណង់និងអចលនទ្រព្យ ការធ្លាក់ថ្លៃក្នុងវិស័យអចលនទ្រព្យអាចបង្កជាហានិភ័យដល់អ្នកខ្ចីប្រាក់ដែលមានកម្រិតបំណុលខ្ពស់។ ធនាគារជាតិនៃកម្ពុជានឹងបន្តតាមដានយ៉ាងជិតដល់នូវស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងហានិភ័យនានាដែលអាចកើតមានចំពោះស្ថិរភាពហិរញ្ញវត្ថុ ហើយនឹងដាក់ចេញនូវវិធានការបុរេសកម្ម ដើម្បីកាត់បន្ថយហានិភ័យ និងការពារភាពរឹងមាំនិងភាពធន់នៃប្រព័ន្ធធនាគារ។

**លើសពីនេះ ហានិភ័យក៏អាចកើតចេញពីគ្រឹះស្ថានធនាគារស្រមោល ដូចជា ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ ឬហាងបញ្ចាំ ជាដើម។** មិនដូចប្រព័ន្ធធនាគារដែលត្រូវបានត្រួតពិនិត្យយ៉ាងជិតដល់ដោយធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានទាំងនេះអាចមិនទាន់ត្រូវបានគ្រប់គ្រងតឹងរ៉ឹង (ហើយលើសពីដែនសមត្ថកិច្ចរបស់ធនាគារជាតិនៃកម្ពុជា)។ ជាលទ្ធផល មានព័ត៌មានតិចតួចអំពីប្រតិបត្តិការ ឬដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ និងហាងបញ្ចាំ ឬសមត្ថភាពសងបំណុលរបស់អតិថិជន។ ដូច្នេះ កិច្ចខិតខំប្រឹងប្រែងរួមគ្នាដោយអាជ្ញាធរពាក់ព័ន្ធជាការចាំបាច់ ដើម្បីពង្រឹងការប្រមូលទិន្នន័យ និងលើកកម្ពស់ការត្រួតពិនិត្យ ដើម្បីទប់ស្កាត់ហានិភ័យណាមួយពីធនាគារស្រមោលទៅលើប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងកិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីធានាបាននូវភាពរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា។

# I ស្ថានភាពនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច

*បន្ទាប់ពីការងើបឡើងលឿននៅក្នុងឆ្នាំ២០២១ កំណើនសេដ្ឋកិច្ចពិភពលោកបានថមថយនៅឆ្នាំ២០២២ ដោយសារភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយរវាងរុស្ស៊ីនិងអ៊ុយក្រែន អតិផរណាខ្ពស់ និងការរឹតបន្តឹងខ្លាំងនៃនយោបាយរូបិយវត្ថុ។ ទោះបីជាស្ថានភាពខាងក្រៅមិនអំណោយផលក៏ដោយ កំណើនសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាប្រទេសជាច្រើនទៀតនៅក្នុងតំបន់អាស៊ាន បានកើនឡើងខ្ពស់ជាងមុនដល់ ៥,២% នៅក្នុងឆ្នាំ២០២២ ធៀបនឹងអត្រាកំណើនត្រឹម ៣% នៅឆ្នាំ២០២១ ដោយសារភាពប្រសើរនៃការនាំចេញ ការងើបឡើងពេញលេញនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងការងើបឡើងឆាប់រហ័សនៃវិស័យទេសចរណ៍។ ក្នុងស្ថានភាពសេដ្ឋកិច្ចមានលក្ខណៈល្អប្រសើរជាងឆ្នាំមុន អតិរេកសមតុល្យជញ្ជីងទូទាត់កម្ពុជាបានកើនឡើង ហើយអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានស្ថិរភាព បើទោះជាតម្លៃប្រាក់ដុល្លារអាមេរិកបានកើនឡើងនៅលើទីផ្សារអន្តរជាតិក៏ដោយ ខណៈដែលទុនបម្រុងអន្តរជាតិនៅតែមានកម្រិតគ្រប់គ្រាន់ ដែលអាចធានាការនាំចូលទំនិញនិងសេវា សម្រាប់គ្រាបន្ទាប់បានរហូតដល់ ៧ខែ។ សមតុល្យសារពើពន្ធ មានភាពប្រសើរឡើងផងដែរ ជាមួយនឹងអតិរេកសារពើពន្ធ និងការធ្លាក់ចុះនៃអនុបាតបំណុលធៀបនឹងផ.ស.ស។ អត្រាអតិផរណាបានកើនឡើងពី ២,៩% នៅក្នុងឆ្នាំ២០២១ ដល់ ៥,៤% នៅក្នុងឆ្នាំ២០២២ ដោយសារការកើនឡើងថ្លៃប្រេងនិងម្ហូបអាហារពិភពលោក និងតម្រូវការក្នុងស្រុកខ្ពស់។ ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចកម្ពុជាមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលគឺជាការងារអាទិភាព ដើម្បីផ្តល់ជម្រើសឧបករណ៍នយោបាយកាន់តែសម្បូរបែប ក្នុងការអនុវត្តនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។*

## ១.១ ស្ថានភាពវិស័យខាងក្រៅ

### ក. សេដ្ឋកិច្ចពិភពលោក

**សេដ្ឋកិច្ចពិភពលោកមានកំណើនយឺត ដោយសារបញ្ហាជម្លោះរុស្ស៊ី-អ៊ុយក្រែន អតិផរណាខ្ពស់ និងការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុ។** កំណើនសេដ្ឋកិច្ចពិភពលោកបានថយចុះគួរឱ្យកត់សម្គាល់ពី ៦,២% ក្នុងឆ្នាំ២០២១ មកត្រឹម ៣,៤% នៅឆ្នាំ២០២២ ដោយសារកំណើនសេដ្ឋកិច្ចទាំងនៅប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ បានថយចុះមកត្រឹម ២,៧% និង ៤% រៀងគ្នា (ក្រាហ្វ ១.១)។ ទោះយ៉ាងណា កំណើនសេដ្ឋកិច្ចអាស៊ានបានកើនឡើងដល់ ៥,៦% ដែលត្រូវបានគាំទ្រដោយភាពប្រសើរឡើងនៃតម្រូវការប្រើប្រាស់ ការនាំចេញ និងវិស័យសេវាកម្មបន្ទាប់ពីការបើកប្រទេសពេញលេញឡើងវិញ។

**អតិផរណាបានកើនឡើងបន្ថែមទៀត ហើយបន្តស្ថិតក្នុងកម្រិតខ្ពស់ជាងគោលដៅកំណត់របស់ធនាគារកណ្តាលជាច្រើន។** ការកើនឡើងថ្លៃថាមពលនិងម្ហូប-

១.១ **កំណើនសេដ្ឋកិច្ចពិភពលោក**

(គិតជាភាគរយ, ឆ្នាំ២០២១-២០២៣ព)




ប្រភព៖ របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោករបស់ IMF និងរបាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចតំបន់របស់ AMRO ចេញផ្សាយក្នុងខែមេសា ឆ្នាំ២០២៣, *ប៖ ប៉ាន់ស្មាន, *ព៖ ព្យាករណ៍

អាហារ ការរាំងស្ទះខ្សែច្រវាក់ផ្គត់ផ្គង់ និងការងើបឡើងខ្លាំងនៃតម្រូវការប្រើប្រាស់បានរុញឱ្យអតិផរណាសកលកើនដល់ ៨,៧% ក្នុងឆ្នាំ២០២២។ អត្រាអតិផរណានៅក្នុងប្រទេសអភិវឌ្ឍន៍បានកើន ៧,៣% ខណៈដែលនៅប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ បានកើនដល់ ៩,៨%ក្នុងឆ្នាំ២០២២ (ក្រាហ្វ ១.២)។ នៅតំបន់អាស៊ានអត្រាអតិផរណាក៏បានកើនឡើងគួរឱ្យកត់សម្គាល់ពី ២,៥% ក្នុងឆ្នាំ២០២១ ដល់ ៧,៩%។ ទោះយ៉ាងណា អត្រាអតិផរណា ត្រូវបានរំពឹងថានឹងថយចុះវិញនៅឆ្នាំ២០២៣ ដោយសារការថយចុះថ្លៃប្រេងនិងវត្ថុធាតុដើមផ្សេងៗ ព្រមជាមួយការថមថយនៃតម្រូវការប្រើប្រាស់របស់ពិភពលោកដែលបណ្តាលមកពីការរឹតបន្តឹងនយោបាយរូបិយវត្ថុ។

**បើទោះមាននិន្នាការធ្លាក់ចុះ អត្រាអតិផរណានៅមានកម្រិតខ្ពស់នៅឡើយ ដូច្នេះការរឹតបន្តឹងនយោបាយរូបិយវត្ថុអាចបន្តយូរជាងការរំពឹងទុក។** ទោះបីកំណើនសេដ្ឋកិច្ចពិភពលោកកំពុងថមថយ ធនាគារកណ្តាលជាច្រើន ជាពិសេសនៅប្រទេសអភិវឌ្ឍន៍ ទំនងជានៅបន្តដំឡើងអត្រាការប្រាក់គោលដើម្បីធ្វើឱ្យអតិផរណាត្រឡប់ទៅរកគោលដៅកំណត់វិញ (ក្រាហ្វ ១.៣)។ ការណ៍នេះ នឹងបង្កបច្ច័យអវិជ្ជមានដល់ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក និងអាចប៉ះពាល់ដល់ប្រទេសកំពុងលូតលាស់ និងកំពុងអភិវឌ្ឍន៍ពាក់ព័ន្ធនឹងបន្ទុកបំណុលខ្ពស់ ការថមថយនៃការនាំចេញនិងការវិនិយោគ និងហានិភ័យនៃលំហូរមូលធនចេញ។ បញ្ហាប្រឈមទាំងនេះនឹងធ្វើឱ្យការងើបឡើងនៃសេដ្ឋកិច្ចពីវិបត្តិកូវីដ-១៩ មានភាពផុយស្រួយ និងអាចដាក់សម្ពាធលើទុនបម្រុងអន្តរជាតិ និងអត្រាប្តូរប្រាក់។ ទោះបីជាសេដ្ឋកិច្ចប្រឈមនឹងការប៉ះទង្គិចក៏ដោយ វិស័យធនាគាររបស់ពិភពលោកត្រូវបានរំពឹងថានៅមានភាពរឹងមាំដែលគាំទ្រដោយស្ថានភាពរឹងមាំនៃដើមទុន និងកម្រិតខ្ពស់នៃសន្ទនីយភាពដោយសារការដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិ និងឧបករណ៍ម៉ាក្រូប្រុងប្រយ័ត្ននានាក្នុងអំឡុងពេលក្រោយវិបត្តិហិរញ្ញវត្ថុសកល។

**១.២ អតិផរណាពិភពលោក**

(គិតជាភាគរយ, ឆ្នាំ២០១៧-២០២៣ព)




ប្រភព៖ របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោករបស់ IMF និងរបាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចតំបន់របស់ AMRO ចេញផ្សាយក្នុងខែមេសា ឆ្នាំ២០២៣, *ប៖ ប៉ាន់ស្មាន, *ព៖ ព្យាករណ៍

**១.៣ អត្រាការប្រាក់គោលនៃប្រទេសអភិវឌ្ឍន៍**

(គិតជាភាគរយ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ tradingeconomics.com

## ខ. ជញ្ជីងទូទាត់កម្ពុជា

**ទោះបីជាទទួលរងសម្ពាធពីកត្តាខាងក្រៅ សមតុល្យជញ្ជីងទូទាត់នៅតែមានអតិរេកក្នុងឆ្នាំ២០២២។** អតិរេកនេះ ត្រូវបានគាំទ្រដោយការបន្តទទួលបានលំហូរចូលគណនីហិរញ្ញវត្ថុ ខណៈឱនភាពគណនីចរន្ត និងដើមទុនបានថយចុះ (ក្រាហ្វ ១.៤)។ អតិរេកសមតុល្យរួមបានកើនឡើងពី ០,៣% ក្នុងឆ្នាំ២០២១ ដល់ ១,២% នៃ ផ.ស.ស. ក្នុងឆ្នាំ២០២២ ដែលគាំទ្រដោយលំហូរវិនិយោគផ្ទាល់បរទេស ការថយចុះល្បឿននៃឱនភាពពាណិជ្ជកម្មទំនិញ ការងើបឡើង ឆាប់រហ័សនៃវិស័យទេសចរណ៍ និងការកើនឡើងវិញនៃប្រាក់បង្វែរពលករពីក្រៅប្រទេស។

**១.៤ ជញ្ជីងទូទាត់កម្ពុជា**
(គិតជាភាគរយនៃផ.ស.ស, ឆ្នាំ២០១៧-២០២២)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

### ខ.១ គណនីចរន្ត

**ឱនភាពគណនីចរន្ត និងដើមទុនបានថយចុះដោយសារភាពរឹងមាំនៃការនាំចេញ។** ឱនភាពគណនីចរន្តនិងមូលធនបានថយចុះ មកត្រឹម -២៤,៩% នៃ ផ.ស.ស. (-៣៩,៦% នៃផ.ស.ស ក្នុងឆ្នាំ២០២១) បន្ទាប់ពីការថយចុះខ្លាំងនៃឱនភាពពាណិជ្ជកម្មទំនិញពី -៤១,៥% ទៅ -២៩.៨% នៃ ផ.ស.ស (ក្រាហ្វ ១.៥)។ ការថយចុះនៃឱនភាពពាណិជ្ជកម្មទំនិញ គឺដោយសារកំណើនការនាំចេញសរុបចំនួន ១៩% ដែលត្រូវបានគាំទ្រដោយការកើនឡើងគួរឱ្យកត់សម្គាល់នៃការនាំចេញសម្លៀកបំពាក់ (១៤.១%) គ្រឿងបង្គុំអេឡិចត្រូនិក (២៧,៤%) កង់ (៥៣,៣%) ខណៈការនាំចេញអង្ករ និងកៅស៊ូ បានថយចុះ -១,៧% និង -០,២% រៀងគ្នា។ ទន្ទឹមនេះ ការនាំចូលបានកើនឡើង ៤,២% ដោយសារការកើនឡើងការនាំចូលប្រេងឥន្ធនៈ (៥៣,៦%) យានយន្ត (២១,៨%) និងម្ហូបអាហារនិងភេសជ្ជៈ (១៦,២%)។ បើមិនរាប់បញ្ចូលមាស សមតុល្យពាណិជ្ជកម្មទំនិញរបស់កម្ពុជាថយចុះមកត្រឹម -១៥,៥% នៃផ.ស.ស. ក្នុងឆ្នាំ២០២២ (-២០% ក្នុងឆ្នាំ២០២១)។

**១.៥ ការនាំចេញ-នាំចូល និងសមតុល្យពាណិជ្ជកម្មទំនិញ**
(ភាគរយនៃផ.ស.ស, ឆ្នាំ២០១៧-២០២២)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**កំណើនល្បឿននៃទេសចរអន្តរជាតិ និងការកើនឡើងប្រាក់បង្វែរពលករពីក្រៅប្រទេសក៏បានរួមចំណែកកាត់បន្ថយឱនភាពគណនីចរន្ត និងដើមទុនផងដែរ។** ទេសចរអន្តរជាតិបានស្ទុះឡើងដល់ ២,៣ លាននាក់

ក្នុងឆ្នាំ២០២២ ពី ០,២ លាននាក់ ក្នុងឆ្នាំ២០២១ ឬស្មើនឹងការកើនឡើង ១១,៦ ដង (ធៀបនឹងការធ្លាក់ចុះ -៨៥% ក្នុងឆ្នាំ២០២១) បន្ទាប់ពីការបើកច្រកអន្តរជាតិឡើងវិញ។ ទន្ទឹមនេះ ប្រាក់បង្ញើពលករពីក្រៅប្រទេសបានកើនឡើង ៣% ដល់ ២,៦ ប៊ីលានដុល្លារ (ក្រាហ្វ ១.៦) ដែលភាគច្រើនកើនឡើងពីប្រទេសកូរ៉េ (៣៦%) និងហុងកុង (១២%)។ ទោះយ៉ាងណា ទេសចរថៃនៅតែមានសមាមាត្រច្រើនជាងគេ គឺ ៧៧,៥% នៃចំនួនទេសចរសរុប ហើយបន្ទាប់មកគឺទេសចរកូរ៉េ (១២,៨%)។

### ខ.២ គណនីហិរញ្ញវត្ថុ

**ក្នុងឆ្នាំ២០២២ លំហូរវិនិយោគផ្ទាល់បរទេសក្នុងវិស័យមិនមែនហិរញ្ញវត្ថុបានងើបឡើងវិញ ប៉ុន្តែលំហូរក្នុងវិស័យហិរញ្ញវត្ថុនៅបន្តធ្លាក់ចុះ។** លំហូរវិនិយោគផ្ទាល់បរទេសសរុបមាន ៣,៦ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២២ ដោយបានកើនឡើង ២,៧% (ក្រាហ្វ ១.៧)។ លំហូរវិនិយោគផ្ទាល់បរទេសក្នុងវិស័យមិនមែនហិរញ្ញវត្ថុបានកើនឡើង ១៨,២% ដែលត្រូវបានគាំទ្រដោយវិស័យសំណង់និងអចលនទ្រព្យ (២៧,៧%) កម្មន្តសាល (១៥,៥%) ការស្នាក់នៅ[៩] (១,៨%) វារីអគ្គិសនី និងថាមពល (៥១%)។ ផ្ទុយទៅវិញ លំហូរវិនិយោគបរទេសទៅកាន់វិស័យហិរញ្ញវត្ថុបានធ្លាក់ចុះ -១៥,៧% ជាចម្បងដោយសារការថយចុះវិនិយោគក្នុងខ្ទង់ដើមទុន និងប្រាក់ចំណេញវិនិយោគឡើងវិញ។

**តំបន់អាស៊ីគឺជាប្រភពចម្បងនៃលំហូរវិនិយោគផ្ទាល់បរទេសមកកម្ពុជា ក្នុងនោះទំហំវិនិយោគនៃប្រទេសចិនមានចំនួនច្រើនជាងគេ។** នៅឆ្នាំ២០២២ ប្រមាណជាងពាក់កណ្តាលនៃលំហូរសរុប លំហូរវិនិយោគផ្ទាល់បរទេសមានប្រភពមកពីប្រទេសចិន (ក្រាហ្វ ១.៨)។ ការវិនិយោគរបស់ប្រទេសចិនភាគច្រើនទៅក្នុងវិស័យកម្មន្តសាល ហិរញ្ញវត្ថុ សំណង់ អចលនទ្រព្យ និងការស្នាក់នៅ។ ទន្ទឹមនេះ វិនិយោគពីប្រទេសផ្សេងទៀត រួមមាន កូរ៉េ

**១.៦ ប្រាក់បង្ញើរបស់ពលករតាមប្រទេស**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា
សម្គាល់៖ ទិន្នន័យប្រាក់បង្ញើពលករក្រៅប្រទេសត្រូវបានធ្វើការកែតម្រូវពីឆ្នាំ២០១៩

**១.៧ លំហូរវិនិយោគផ្ទាល់បរទេសតាមវិស័យ**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**១.៨ លំហូរវិនិយោគផ្ទាល់បរទេសតាមប្រទេស**
(គិតជាភាគរយ, ឆ្នាំ២០២២)




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

[៩] វិស័យនេះរួមមាន សណ្ឋាគារ ភោជនីយដ្ឋាន និងកាស៊ីណូ។

(១១,៩%) ជប៉ុន (៨,៩%) សិង្ហបុរី (៧,៣%) ម៉ាឡេស៊ី (៣,១%) និងចក្រភពអង់គ្លេស (២,៧%)។

**បំណុលក្រៅប្រទេសៈបន្តកើនឡើង។** បំណុលក្រៅប្រទេសរបស់កម្ពុជាបានកើនឡើង ១១,៥% ដល់ ២២,៤ ប៊ីលានដុល្លារអាមេរិក (៧៥,៦% នៃផ.ស.ស.) ក្នុងនោះ ១៧,៨ ប៊ីលានដុល្លារជាបំណុលរយៈពេលវែង (ក្រាហ្វ ១.៩)។ បំណុលក្រៅប្រទេសរបស់រាជរដ្ឋាភិបាលដែលសុទ្ធតែជាកម្ចីរយៈពេលវែង មានចំនួន ៩,៩៧ ប៊ីលានដុល្លារអាមេរិក ដោយបានកើនឡើង ៤,៩%។ ទន្ទឹមនេះ បំណុលខាងក្រៅរបស់គ្រឹះស្ថានទទួលប្រាក់បញ្ញើបានកើនឡើងដល់ ១២,១ ប៊ីលានដុល្លារ ក្នុងនោះ ចំនួន ៧,៥ ប៊ីលានដុល្លារជាកម្ចីរយៈពេលវែង ដោយបានកើនឡើង ១៨,២%។

១.៩ **សមាសធាតុនៃបំណុលក្រៅប្រទេសដុល**

(គិតជាភាគរយនៃផ.ស.ស., ឆ្នាំ២០១៧-២០២២)




ប្រភពៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា

## គ. អត្រាប្តូរប្រាក់ និងទុនបម្រុងអន្តរជាតិ

**អត្រាប្តូរប្រាក់បានថយចុះបន្តិច ប៉ុន្តែមិនបានដាក់សម្ពាធលើស្ថិរភាពតម្លៃប្រាក់រៀលនោះទេ។** ដោយសារការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក តម្រូវការប្រាក់រៀលបានកើនឡើង ដែលធ្វើឱ្យអត្រាប្តូរប្រាក់មានស្ថិរភាពក្នុងអត្រាមធ្យម ៤.១០២ រៀលក្នុងមួយដុល្លារអាមេរិក ក្នុងឆ្នាំ២០២២ ដោយបានធ្លាក់ថ្លៃត្រឹម ១% ធៀបនឹងឆ្នាំ២០២១ ទោះបីជាប្រាក់ដុល្លារអាមេរិកបានឡើងថ្លៃខ្លាំងនៅលើទីផ្សារអន្តរជាតិធៀបនឹងរូបិយប័ណ្ណផ្សេងទៀតក៏ដោយ។ ជាមួយនឹងការធ្លាក់ថ្លៃតែបន្តិចនេះ និងកម្រិតគ្រប់គ្រាន់នៃទុនបម្រុងអន្តរជាតិ សន្ទស្សន៍សម្ពាធទីផ្សារប្តូរប្រាក់[៣] (EMP) នៅតែស្ថិតនៅក្នុងគន្លងប្រក្រតីនៅក្នុងគម្លាតស្តង់ដារ[៤] (ក្រាហ្វ ១.១០)។

១.១០ **សម្ពាធទីផ្សារប្តូរប្រាក់ (EMP)**

(ឆ្នាំ២០១៧-២០២២)




ប្រភពៈ ធនាគារជាតិនៃកម្ពុជា

---

[២] បំណុលក្រៅប្រទេសគ្របដណ្តប់លើកម្ចីក្រៅប្រទេសរបស់វិស័យសាធារណៈ (រាជរដ្ឋាភិបាល និងធនាគារកណ្តាល) និងគ្រឹះស្ថានទទួលប្រាក់បញ្ញើតែប៉ុណ្ណោះ។

[៣] សន្ទស្សន៍សម្ពាធទីផ្សារប្តូរប្រាក់ (EMP) ត្រូវបានប្រើដើម្បីវិភាគសម្ពាធអត្រាប្តូរប្រាក់ក្នុងទីផ្សារដែលឆ្លុះបញ្ចាំងពីការប្រែប្រួលប្រចាំខែនៃអត្រាប្តូរប្រាក់ និងទុនបម្រុងអន្តរជាតិ (តំណាងឱ្យសមត្ថភាពរបស់ធនាគារកណ្តាលក្នុងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់ក្នុងករណីចាំបាច់)។ នៅក្នុងបរិការណ៍សេដ្ឋកិច្ចដែលមានដុល្លារូបនីយកម្មខ្ពស់ នៅពេលដែល EMP ឡើងហួសដែនកំណត់ខាងលើ មិនមានន័យថាកម្ពុជាមានហានិភ័យវិបត្តិរូបិយវត្ថុនោះទេ។ នៅពេលដែល EMP ឡើងហួសដែនកំណត់ខាងលើមានន័យថាទុនបម្រុងអន្តរជាតិបានធ្លាក់ចុះ (និង/ឬ មានសម្ពាធនៃការធ្លាក់ថ្លៃប្រាក់រៀល) ឬការកើនឡើងនៃទុនបម្រុងអន្តរជាតិ (និង/ឬ មានសម្ពាធនៃការឡើងថ្លៃប្រាក់រៀល) នៅពេលដែលចុះហួសដែនកំណត់ខាងក្រោម។

[៤] ដែនកំណត់គម្លាតស្តង់ដារត្រូវបានកំណត់ដោយ μEMP+/-φσEMP ដែល μEMP៖ មធ្យមនៃ EMP; σEMP៖ គម្លាតស្តង់ដារនៃ EMP; φ៖ មេគុណនៃ σEMP (ដែនកំណត់ខាងក្រោម និងខាងលើ គណនាចេញពីភាគរយនៃ EMP) ។ ព្រំដែនខាងក្រោមគឺ -២,២៤ នៃគម្លាតស្តង់ដារ ហើយព្រំដែនខាងលើ គឺ ១,៦៦ នៃគម្លាតស្តង់ដារ។

**ទោះយ៉ាងណា ស្ថិរភាពនៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបានធ្វើឱ្យអត្រាប្តូរប្រាក់ប្រសិទ្ធភាពឡើងថ្លៃធៀបនឹងរូបិយប័ណ្ណនៃដៃគូពាណិជ្ជកម្មសំខាន់ៗ។** ក្នុងឆ្នាំ ២០២២ រូបិយប័ណ្ណជាច្រើនបានធ្លាក់ថ្លៃធៀបនឹងប្រាក់ដុល្លារអាមេរិក បន្ទាប់ពីសហរដ្ឋអាមេរិករឹតបន្តឹងខ្លាំងនូវនយោបាយរូបិយវត្ថុ។ ឧទាហរណ៍ ប្រាក់អឺរ៉ូបានធ្លាក់ថ្លៃជាមធ្យម -១២,៤% ធៀបនឹងឆ្នាំ២០២១ ប្រាក់ផោនអង់គ្លេសធ្លាក់ថ្លៃ -១២% ប្រាក់យេនជប៉ុន -១៩,៦% ប្រាក់យ៉ន់ចិន -៤,៩% និងប្រាក់បាតថៃ -៩,៤%។ ជាលទ្ធផល អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាម (NEER) របស់កម្ពុជាធៀបនឹងដៃគូពាណិជ្ជកម្មសំខាន់ៗ បានឡើងថ្លៃ ៣,៣% ស្របពេលដែលអត្រាប្តូរប្រាក់ប្រសិទ្ធភាពពិត (REER) បានឡើងថ្លៃ ៣,៤% (ក្រាហ្វ ១.១១) ដែលបានកាត់បន្ថយភាពប្រកួតប្រជែងនៃពាណិជ្ជកម្មកម្ពុជា។

**១.១១ អត្រាប្តូរប្រាក់**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ទុនបម្រុងអន្តរជាតិបានថយចុះ ប៉ុន្តែនៅតែមានកម្រិតគ្រប់គ្រាន់ក្នុងការរក្សាទំនុកចិត្តទីផ្សារ។** ទុនបម្រុងអន្តរជាតិមានចំនួន ១៧,៨ ប៊ីលានដុល្លារអាមេរិក នៅចុងឆ្នាំ២០២២ ដោយបានថយចុះ -១២% ធៀបនឹងឆ្នាំ២០២១ និងអាចធានាការនាំចូលទំនិញ និងសេវាសម្រាប់គ្រាបន្ទាប់បាន ៧ ខែ (ក្រាហ្វ ១.១២) ខ្ពស់ជាងកម្រិតអប្បបរមា ៣ខែដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។ បើធៀបនឹងរូបិយវត្ថុទូទៅ (M2) ទុនបម្រុងអន្តរជាតិមាន ៤២% ដែលខ្ពស់ជាងកម្រិតគោល ២០%។ ទោះយ៉ាងណា នៅក្នុងបរិការណ៍នៃសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់ (ទុនបម្រុងអន្តរជាតិមានសមាមាត្រ ៥២% ធៀបនឹងប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស) ការគរពូនទុនបម្រុងអន្តរជាតិបន្ថែមនៅតែមានភាពចាំបាច់ដើម្បីពង្រឹងភាពធន់នៃសេដ្ឋកិច្ចទល់នឹងការប៉ះទង្គិចនានា។

**១.១២ ទុនបម្រុងអន្តរជាតិ**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ១.២ ស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក

### ក. កំណើនសេដ្ឋកិច្ច

**បើទោះជាមានបញ្ហាប្រឈមពីខាងក្រៅក៏ដោយ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើន ៥,២% ក្នុងឆ្នាំ២០២២** (ក្រាហ្វ ១.១៣)។ កំណើននេះត្រូវបានគាំទ្រដោយភាពរឹងមាំនៃការនាំចេញសម្លៀកបំពាក់និងផលិតផលមិនមែនកាត់ដេរផ្សេងទៀត ការងើបឡើងឆាប់រហ័សនៃវិស័យ ទេសចរណ៍ និងការជួញដូរដុំនិងរាយ។ វិស័យកសិកម្មមានកំណើនទាប ដោយសារបញ្ហាអាកាសធាតុមិនអំណោយផល និងថ្លៃដើមផលិតកម្មកើនឡើង ខណៈវិស័យសំណង់បន្តងើបឡើងបណ្តើរៗ បន្ទាប់ពីវិបត្តិកូវីដ-១៩។

**វិស័យកម្មន្តសាលបន្តរក្សាបានកំណើនរឹងមាំ បើទោះជាបានថមថយនៅក្នុងត្រីមាសចុងក្រោយ។** ការនាំចេញសម្លៀកបំពាក់ (សមាមាត្រ ៦៣,១% នៃការនាំចេញសរុប) កើនឡើង ១៨,១% ខណៈការនាំចេញផលិតផលមិនមែនកាត់ដេរបានកើន ២១,៦% (មិនរាប់បញ្ចូលមាស) ជាពិសេស កង់ គ្រឿងបន្លាស់រថយន្ត និងគ្រឿងបង្គុំអេឡិចត្រូនិក។ យ៉ាងណាមិញ ក្នុងត្រីមាសទី៤ ឆ្នាំ២០២២ ការនាំចេញបានថយចុះមកត្រឹម ១,៤% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន បន្ទាប់ពីការថមថយកំណើនសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិកនិងបណ្តាប្រទេសនៅអឺរ៉ុប ដែលសុទ្ធសឹងជាទីផ្សារនាំចេញដ៏សំខាន់របស់កម្ពុជា។

**ទិន្នផលកសិកម្មមានកំណើនទាបក្នុងអត្រា ០,៣%។** ការធ្លាក់ភ្លៀងច្រើនបានបណ្តាលឱ្យមានទឹកជំនន់ដែលបង្កការរាំងស្ទះដល់ផលិតកម្មស្រូវរដូវវស្សា។ លើសពីនេះ ការកើនឡើងនៃថ្លៃដើមផលិតកម្ម (ប្រេងឥន្ធនៈ និងជីកសិកម្ម) បានប៉ះពាល់ដល់សក្តានុពលនៃវិស័យនេះក្នុងឆ្នាំ២០២២។ នៅរដូវប្រាំង ផលិតផលស្រូវសម្រេចបាននូវអត្រាកំណើន ០,៣% ខណៈស្រូវរដូវវស្សាបានធ្លាក់ចុះ -២០,៧%។ យ៉ាងណាមិញ ផលិតផលកៅស៊ូទទួលបានកំណើនល្អ ៣,៨% ដោយសារការកើនឡើងនៃតម្រូវការខាងក្រៅ។

**១.១៣ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ**

(គិតជាភាគរយ, ឆ្នាំ២០១៧-២០២២ប)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**វិស័យទេសចរណ៍បានងើបឡើងលឿន និងលើសពីការរំពឹងទុក ប៉ុន្តែវិស័យនេះនៅត្រូវការពេលវេលាដើម្បីត្រឡប់ទៅដូចស្ថានភាពមុនគ្រាមានវិបត្តិជំងឺកូវីដ-១៩។** ការងើបឡើងលឿននេះគឺដោយសារគោលនយោបាយបើកប្រទេសឡើងវិញរបស់រាជរដ្ឋាភិបាល ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២១ ក៏ដូចជាកំណើនទេសចរក្នុងតំបន់ និងការចាប់ផ្តើមតភ្ជាប់ជើងហោះហើរនានាមកកាន់កម្ពុជាឡើងវិញ។ ទេសចរអន្តរជាតិមានចំនួន ២,៣ លាននាក់ ដោយបានកើនឡើង ១១,៦ ដងពីកម្រិតទាបបំផុតក្នុងឆ្នាំ២០២១ (ក្រាហ្វ ១.១៤)។ ទោះយ៉ាងណា តួលេខនេះស្មើនឹងមួយភាគបីនៃចំនួនទេសចរអន្តរជាតិសរុបមុនពេលការរាលដាលនៃជំងឺកូវីដ-១៩ ហើយ ត្រូវការរយៈពេលពីរឬបីឆ្នាំទៀត ដើម្បីឈានដល់កម្រិតដូចដើមវិញ។

**ទេសចរថៃមានចំនួនច្រើនជាងគេក្នុងចំណោមទេសចរអន្តរជាតិមកកាន់ប្រទេសកម្ពុជា ដោយបានឡើងលើសទេសចរចិនកាលពីឆ្នាំ២០២១។** បន្ទាប់ពីការបើកច្រកព្រំដែនកម្ពុជា-ថៃឡើងវិញ នៅដើមឆ្នាំ២០២២ ទេសចរថៃមានប្រមាណ ៣៧,៥% នៃទេសចរអន្តរជាតិសរុបដែលបានមកកម្ពុជាក្នុងឆ្នាំ២០២២ (ក្រាហ្វ ១.១៥)។ ទេសចរចិន ដែលមានចំនួនច្រើនជាងគេនៅមុនវិបត្តិកូវីដ-១៩ បានធ្លាក់ចុះមកនៅត្រឹមចំណាត់ថ្នាក់ទី៤ ដោយសារតែគោលនយោបាយគ្មានកូវីដ ដែលបានរឹតបន្តឹងការធ្វើដំណើររបស់ប្រជាជនចិនទៅក្រៅប្រទេស។

**យ៉ាងណាមិញ វិស័យទេសចរណ៍ក្នុងស្រុកបានវិលទៅរកនិន្នាការមុនវិបត្តិកូវីដ-១៩ ដោយចំនួនទេសចរក្នុងស្រុកកើនឡើងប្រមាណ ៣ ដង ដល់ ១៣,៩ លាននាក់។** ទេសចរក្នុងស្រុកភាគច្រើន (សមាមាត្រ៥០,៦% នៃទេសចរសរុប) បានទៅទស្សនាតំបន់ឆ្នេរ (កើនឡើង ២,១%) ដោយសារតែការដាក់ឱ្យដំណើរការនៃផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ និងការរីកចម្រើនផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតនៅក្នុងតំបន់ (ក្រាហ្វ ១.១៦)។

**១.១៤ ចំនួនទេសចរអន្តរជាតិបែងចែកតាមគោលបំណង**

(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ក្រសួងទេសចរណ៍

**១.១៥ សមាមាត្រនៃទេសចរតាមប្រទេស**

(គិតជាភាគរយ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ ក្រសួងទេសចរណ៍ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**១.១៦ ទេសចរក្នុងស្រុក**

(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ក្រសួងទេសចរណ៍

**វិស័យសំណង់និងអចលនទ្រព្យបានបន្តងើបឡើងសន្សឹមៗក្នុងអត្រាកំណើន ០,៥% និង០,២% រៀងគ្នា** (ក្រាហ្វ ១.១៧)។ កំណើនទាំងនេះត្រូវបានជំរុញជាចម្បង ដោយតម្រូវការក្នុងស្រុក ជាពិសេសសម្រាប់លំនៅដ្ឋានកម្រិតមធ្យមនិងតម្លៃសមរម្យ។ ទន្ទឹមនេះ ការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យសំណង់និងអចលនទ្រព្យបានកើនឡើង ១២,២% បើទោះបីជាស្ថានភាព សេដ្ឋកិច្ចពិភពលោកមានភាពមិនច្បាស់លាស់ដែលការណ៍នេះ បានបង្ហាញពីសុទិដ្ឋិនិយមរបស់វិនិយោគិន មកលើវិស័យសំណង់និងអចលនទ្រព្យនៅកម្ពុជា។

**ក្រោយពីធ្លាក់ចុះនៅដើមឆ្នាំ២០២២ តម្លៃលំនៅ-ដ្ឋានបានងើបឡើងវិញនៅឆមាសទី២ ប៉ុន្តែក្នុងល្បឿនយឺតជាងកំណើនក្នុងឆ្នាំ២០២១។** នៅដើមឆ្នាំ២០២២ តម្លៃលំនៅដ្ឋានបានថមថយកំណើននិងបានធ្លាក់ចុះរហូតដល់ចុងឆមាសទី១ ឆ្នាំ២០២២ ដែលបណ្តាលមកពីការកើនឡើងនៃករណីឆ្លងជំងឺកូវីដ-១៩ ប្រភេទអូមីក្រុងនៅកម្ពុជា និងភាពមិនច្បាស់លាស់នៃកត្តាខាងក្រៅដែលរួមមានបញ្ហាអចលនទ្រព្យនៅក្នុងប្រទេសចិន និងជម្លោះនៅអ៊ុយក្រែន (ក្រាហ្វ ១.១៨)។ តម្លៃលំនៅដ្ឋានបានងើបឡើងវិញក្នុងឆមាសទី២ និងបានកើន ៣,៥% (ឆ្នាំលើឆ្នាំ) នៅខែធ្នូ ឆ្នាំ២០២២ ដែលក្នុងនោះតម្លៃនៅរាជធានីភ្នំពេញ និងខេត្តផ្សេងទៀតបានកើន ៣,៣% និង ៦% រៀងគ្នា។ ការកើនឡើងនេះ ជាចម្បងបណ្តាលមកពីកំណើនតម្រូវការក្នុងស្រុក និងភាពងាយស្រួលក្នុងការទទួលបានឥណទាន។ ទោះយ៉ាងណា ធនាគារជាតិនៃកម្ពុជានឹងបន្តសហការជាមួយភាគីពាក់ព័ន្ធដើម្បីពង្រឹងការប្រមូលទិន្នន័យនិងការវិភាគលើវឌ្ឍនភាពនៃវិស័យអចលនទ្រព្យកម្ពុជាបន្ថែមទៀត ដោយសារសន្ទស្សន៍ថ្លៃលំនៅដ្ឋាន (RPPI) ឆ្លុះបញ្ចាំងតែមួយផ្នែកនៃទីផ្សារអចលនទ្រព្យ ហើយពឹងផ្អែកលើប្រតិបត្តិការឥណទានទិញផ្ទះរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**១.១៧ កំណើនវិស័យសំណង់និងអចលនទ្រព្យ**

(គិតជាភាគរយ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**១.១៨ សន្ទស្សន៍ថ្លៃលំនៅដ្ឋាន**

(ការប្រែប្រួលប្រចាំឆ្នាំ, ឆ្នាំ២០២១-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ.ស្ថានភាពអតិផរណា និងរូបិយវត្ថុ

**អត្រាអតិផរណានៅកម្ពុជាបានកើនដល់ ៥,៤% ដែលជាអត្រាខ្ពស់បំផុតក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ដោយសារការកើនឡើងនៃថ្លៃប្រេងនិងម្ហូបអាហារពិភពលោក និងតម្រូវការក្នុងស្រុក។** សង្គ្រាមរុស្ស៊ី-អ៊ុយក្រែនបានបង្កឱ្យមានការកើនឡើងខ្លាំងនៃតម្លៃថាមពលនិងម្ហូបអាហារលើទីផ្សារអន្តរជាតិ ដែលបណ្តាលឱ្យអតិផរណាកើនឡើងខ្ពស់តាមបណ្តាប្រទេសជាច្រើន រួមទាំងប្រទេសកម្ពុជាផងដែរ។ ក្នុងឆមាសទី១ តម្លៃប្រេង និងម្ហូបអាហារនៅកម្ពុជាបានកើន ១៨,៤% និង ៥,៦% រៀងគ្នា។ ទន្ទឹមនេះ ការងើបឡើងវិញយ៉ាងរឹងមាំនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកក៏បានដាក់សម្ពាធលើអតិផរណាស្នូល ដែលបានកើនដល់ ៥% ក្នុងគ្រាដូចគ្នា។ កត្តាទាំងអស់នេះ បានបណ្តាលឱ្យអតិផរណារួមកើនដល់អត្រាខ្ពស់បំផុតក្នុងខែមិថុនា ឆ្នាំ២០២២ (៧,៨%)។ យ៉ាងណាមិញ ចាប់ពីខែកក្កដាមក អត្រាអតិផរណាបានធ្លាក់ចុះជាបន្តបន្ទាប់ ដោយសារតែកំណើនយឺតនៃតម្លៃប្រេងនិងម្ហូបអាហារ និងការកើនឡើងនៃអត្រាការប្រាក់គោល ដើម្បីទប់ទល់នឹងអតិផរណាតាមបណ្តាប្រទេសនានា។ ជាលទ្ធផល អតិផរណាជាមធ្យមនៅកម្ពុជាមានកម្រិត ៥,៤% ក្នុងឆ្នាំ២០២២ (ក្រាហ្វ ១.១៩) ដែលជាអត្រាខ្ពស់បំផុតចាប់តាំងពីឆ្នាំ២០១១ មក (៥,៥%) ប៉ុន្តែទាបជាងអត្រាមធ្យមក្នុងតំបន់អាស៊ាន (៧,៩%)។

**១.១៩ ការរួមចំណែកក្នុងអតិផរណា**
(គិតជាភាគរយ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**រូបិយវត្ថុទូទៅ (M2) បានកើនឡើង ៨,២% យឺតជាងឆ្នាំមុន (កើន ១៦,៤%) (ក្រាហ្វ ១.២០)។** កំណើនយឺតនៃ M2 គឺដោយសារតែការថយចុះនៃកំណើនប្រាក់បញ្ញើសរុប ៩,៣% (ធៀបនឹងកំណើន ១៧,៣% ក្នុងឆ្នាំ២០២១)។ ជាមួយគ្នានេះ រូបិយវត្ថុក្នុងចរាចរណ៍បានធ្លាក់ចុះ -៣% ធៀបនឹងកំណើន ៨,២% នៅឆ្នាំ២០២១។

**១.២០ រូបិយវត្ថុទូទៅ M2**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**បើទោះបីជាកម្រិតដុល្លារូបនីយកម្មបានថមថយ ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលត្រូវបានពង្រឹងបន្ថែមទៀត។** សេដ្ឋកិច្ចពឹងផ្អែកលើប្រាក់រៀលនឹងផ្តល់លទ្ធភាពដល់ធនាគារជាតិនៃកម្ពុជាក្នុងការគ្រប់គ្រងនយោបាយរូបិយវត្ថុកាន់តែមានប្រសិទ្ធភាពតាមរយៈ

ការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ និងការផ្លាស់ប្តូរអត្រាការប្រាក់គោល ដែលមានឥទ្ធិពលទៅលើសកម្មភាពសេដ្ឋកិច្ច។ កន្លងមក ធនាគារជាតិនៃកម្ពុជាបានខិតខំប្រឹងប្រែងឥតឈប់ឈរ ក្នុងការលើកទឹកចិត្តដល់ការប្រើប្រាស់ប្រាក់រៀល ខណៈដែលកម្រិតដុល្លាររូបនីយកម្មក្នុងប្រាក់បញ្ញើសរុបបានថយចុះបន្តិចពី ៩១,៥% ក្នុងឆ្នាំ ២០២១ មកត្រឹម ៩០,៥% នៅឆ្នាំ២០២២ ស្របពេលដែលរូបិយប័ណ្ណបរទេសធៀបនឹង M2 មានស្ថិរភាពក្នុងអត្រា ៨៣% (ក្រាហ្វ ១.២១)។ បច្ចុប្បន្នគឺជាពេលវេលាដែលត្រូវពន្លឿនកិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់ប្រាក់រៀល ដែលទាមទារឱ្យមានការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធ ទាំងវិស័យសាធារណៈនិងឯកជន។ គួររំលេចផងដែរថា ការបោះផ្សាយមូលបត្ររដ្ឋរបស់រាជរដ្ឋាភិបាលជាប្រាក់រៀលឡើងវិញ នឹងក្លាយជាឧបករណ៍គោលនយោបាយរូបិយវត្ថុមួយទៀតនាពេលអនាគត ដើម្បីពង្រឹងការប្រើប្រាស់ប្រាក់រៀលក្នុងវិស័យហិរញ្ញវត្ថុ។

**១.២១ ដុល្លាររូបនីយកម្ម**

(គិតជាភាគរយ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ប្រអប់ ១.១**

## កត្តាជំរុញអតិផរណានៅកម្ពុជាក្នុងឆ្នាំ២០២២ និងតួនាទីនៃស្ថិរភាពអត្រាប្តូរប្រាក់នៅក្នុងសេដ្ឋកិច្ចដុល្លារូបនីយកម្ម

អតិផរណានៅកម្ពុជាមានកម្រិតទាប និងស្ថិរភាព នៅក្នុងរយៈពេលទសវត្សរ៍ចុងក្រោយជាមួយនឹងអត្រាមធ្យម ២,៧%។ ប៉ុន្តែ ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០២១ អតិផរណាក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបានកើន ដោយសារតែការកើនឡើងថ្លៃប្រេងអន្តរជាតិស្របតាមការងើបឡើងនៃសេដ្ឋកិច្ចពិភពលោក (ក្រាហ្វ ១.២២)។ ការកើនឡើងថ្លៃប្រេងបានចាប់ផ្តើមមានឥទ្ធិពលទៅលើអតិផរណាក្រុមទំនិញផ្សេងទៀត នៅចុងឆ្នាំ២០២១ ដែលបន្ទាប់មក បានកើនឡើងកាន់តែខ្លាំង ដោយសារកំណើនថ្លៃប្រេងនិងម្ហូបអាហារអន្តរជាតិ ក្រោយការផ្ទុះឡើងនៃភាពតានតឹងភូមិសាស្ត្រនយោបាយរវាងរុស្ស៊ី-អ៊ុយក្រែន ចាប់ពីខែកុម្ភៈ ឆ្នាំ២០២២ មក។




១.២២ អតិផរណានៅកម្ពុជា (ភាគរយ, ២០១៨-២០២២)

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

អតិផរណាបានកើនដល់កម្រិតខ្ពស់បំផុតនាខែមិថុនា ឆ្នាំ២០២២ និងបានថយចុះក្នុងឆមាសទី២ ដោយសារតម្លៃប្រេងបានធ្លាក់ចុះ (ក្រាហ្វ ១.២៣) បន្ទាប់ពីការរឹតបន្តឹងខ្លាំងនៃយោបាយរូបិយវត្ថុនៅតាមបណ្តាប្រទេសអភិវឌ្ឍន៍ ជាពិសេសសហរដ្ឋអាមេរិក ដែលនាំឱ្យកំណើនសេដ្ឋកិច្ចពិភពលោកថមថយ និងការព្រួយបារម្ភអំពីការអាចកើតមាននូវវិបត្តិសេដ្ឋកិច្ច។ ការធ្លាក់ចុះយ៉ាងឆាប់រហ័សនៃអត្រាអតិផរណានៅក្នុងឆមាសទី២ ក៏បណ្តាលមកពីកត្តាតម្រូវការក្នុងស្រុកដែលហាក់បានថមថយ ដូចដែលបានឆ្លុះបញ្ចាំងតាមរយៈកំណើនឥណទានយឺតជាងមុន (ក្រាហ្វ ១.២៤)។




១.២៣ អតិផរណានៅកម្ពុជា និងតម្លៃប្រេងនៅអន្តរជាតិ (ឆ្នាំ២០១៨-២០២២)

ប្រភព៖ ធនាគារជាតិនៃកម្ពុជា




១.២៤ កំណើនឥណទានរបស់គ្រឹះស្ថានធនាគារ (ភាគរយ, ២០១៨-២០២២)

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រឈមនឹងការកើនឡើងឆាប់រហ័សនៃអតិផរណាក្នុងបរិការណ៍នៃកម្រិតដុល្លារូបនីយកម្មខ្ពស់ ធនាគារជាតិនៃកម្ពុជាបានរក្សាស្ថិរភាពថ្លៃតាមរយៈការគ្រប់គ្រងសន្ទនីយភាពយ៉ាងប្រុងប្រយ័ត្ន ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់។ ដូចដែលបានបង្ហាញក្នុង ក្រាហ្វ ១.២៥ អត្រាប្តូរប្រាក់រៀលមានស្ថិរភាពល្អនៅក្នុងឆ្នាំ២០២២ បើធៀបទៅនឹងរូបិយប័ណ្ណរបស់ប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗមួយចំនួន ដែលមាននិន្នាការថយថ្លៃធៀបនឹងប្រាក់ដុល្លារអាមេរិក។ ស្ថិរភាពអត្រាប្តូរប្រាក់ បានជួយបន្ថយសម្ពាធថ្លៃទំនិញនាំចូល និងហានិភ័យនៃអត្រាប្តូរប្រាក់ដែលអាចជំរុញឱ្យអាជីវករបង្កើនថ្លៃលក់ដើម្បីការពារហានិភ័យខាតបង់ដោយសារការប្រែប្រួលនៃអត្រាប្តូរប្រាក់។

**១.២៥** **ស្ថិរភាពអត្រាប្តូរប្រាក់**

(សន្ទស្សន៍ក្នុងឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

កំណត់ចំណាំ៖ សន្ទស្សន៍មូលដ្ឋាន (១០០) គឺជាអត្រាប្តូរប្រាក់មធ្យមក្នុងឆ្នាំ២០១៩

## គ. វិស័យសារពើពន្ធ

**វិចារណកម្មចំណាយនៃការចំណាយ និងការកើនឡើងវិញនៃចំណូលបានធ្វើឱ្យសារពើពន្ធរួមរបស់រាជរដ្ឋាភិបាលមានអតិរេក។** សមតុល្យសារពើពន្ធរួមរបស់រាជរដ្ឋាភិបាល មានអតិរេក ១,១% នៃផ.ស.ស. ធៀបនឹងឱនភាព ប្រមាណ -៧% ក្នុងឆ្នាំ២០២១ និង -៣,៧% នៅឆ្នាំ២០២០ (ក្រាហ្វ ១.២៦)។

**ចំណូលបានកើនឡើង ស្របតាមការងើបឡើងវិញនៃសេដ្ឋកិច្ច និងការធ្លាក់ចុះនៃករណីឆ្លងជំងឺកូវីដ-១៩។** ក្នុងឆ្នាំ២០២២ ចំណូលរបស់រាជរដ្ឋាភិបាលកម្ពុជា មានចំនួន ២៥ ទ្រីលានរៀល (៦,១ ប៊ីលានដុល្លារអាមេរិក) បានកើនឡើង ១៥% (ក្រាហ្វ ១.២៧) ធៀបនឹងឆ្នាំ២០២១ (ធ្លាក់ចុះ -៦%)។ ការកើនឡើងនេះ ជាចម្បងបណ្តាលមកពីកំណើននៃការប្រមូលពន្ធ (២២,១%) ក្នុងនោះ ពន្ធលើទំនិញនិងសេវាកម្មបានកើនឡើង ២២,៣% ពន្ធលើពាណិជ្ជកម្មអន្តរជាតិ ១៩,៦% និងពន្ធលើប្រាក់ចំណូល ២២,៨%។ ដោយឡែក អំណោយបានថយចុះ -៥២,២%។

**បន្ទាប់ពីការចំណាយលើអន្តរាគមន៍ច្រើនកាលពីឆ្នាំ២០២០-២០២១ ដើម្បីទប់ស្កាត់និងកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើសុខុមាលភាពសង្គម និងសេដ្ឋកិច្ច ការចំណាយរបស់រាជរដ្ឋាភិបាលបានធ្លាក់ចុះក្នុងឆ្នាំ២០២២នេះ។** ការចំណាយសរុបមានចំនួន ២៣,៧ ទ្រីលានរៀល (៥,៨ប៊ីលានដុល្លារអាមេរិក) បានធ្លាក់ចុះគួរឱ្យកត់សម្គាល់ ប្រមាណ -១៩,៧% (ក្រាហ្វ ១.២៨) ជាចម្បងដោយសារវិចារណកម្មចំណាយនៃចំណាយចរន្ត និងការធ្លាក់ចុះនៃចំណាយមូលធន។ ចំណាយចរន្តបានថយចុះ -១២,១% ដោយសារការកាត់បន្ថយចំណាយលើការប្រើប្រាស់ទំនិញ និងសេវាកម្ម (-១៣,៧%) និងប្រាក់ឈ្នួល (-១,៧%)។ ខណៈដែលការចំណាយលើអត្ថប្រយោជន៍សង្គមបានកើនឡើង ៧,២% ពី ៣,៤ ទ្រីលានរៀលក្នុងឆ្នាំ២០២១ ដល់ ៣,៦ ទ្រីលានរៀល ដោយសារការបន្តជួយឧបត្ថម្ភរបស់រាជរដ្ឋាភិបាលដល់គ្រួសារដែលងាយរងគ្រោះដោយ

**១.២៦ សមតុល្យសារពើពន្ធ**
(ភាគរយនៃផ.ស.ស., ឆ្នាំ២០១៧-២០២២)




ប្រភព៖ ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**១.២៧ ការរួមចំណែកក្នុងកំណើនប្រាក់ចំណូល**
(ជាភាគរយ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**១.២៨ ការរួមចំណែកក្នុងកំណើនចំណាយ**
(ជាភាគរយ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

វិបត្តិកូវីដ-១៩ និងការកើនឡើងខ្ពស់នៃអតិផរណា។ ដោយឡែក ចំណាយមូលធនមានចំនួន ៥,៨ ទ្រីលានរៀល បានធ្លាក់ចុះ -៣៦,៤% ធៀបនឹងឆ្នាំមុន។

**បំណុលក្រៅប្រទេសរបស់រាជរដ្ឋាភិបាលធៀបនឹងផ.ស.ស. បានថយចុះវិញ ក្រោយកើនដល់ចំណុចខ្ពស់បំផុតនៅឆ្នាំ២០២១។** បំណុលក្រៅប្រទេសរបស់រាជរដ្ឋាភិបាលបានកើនឡើងខ្លាំងក្នុងអំឡុងពេលនៃវិបត្តិកូវីដ-១៩ ដោយបានកើនឡើងពី ២៨,១% នៃផ.ស.ស. ក្នុងឆ្នាំ២០១៩ ដល់ ៣៣,៩% ក្នុងឆ្នាំ២០២០ និងឈានដល់កម្រិតខ្ពស់បំផុត ៣៥,២% នៅឆ្នាំ២០២១។ គិតត្រឹមចុងឆ្នាំ២០២២ បំណុលក្រៅប្រទេសរបស់រាជរដ្ឋាភិបាលបានថយចុះបន្តិចមកត្រឹម ៣៣,៩% នៃផ.ស.ស. ដែលជាចម្បងបណ្តាល មកពីកំណើន ផ.ស.ស. ខ្ពស់ជាងកំណើនបំណុលក្រៅប្រទេស ការបោះផ្សាយមូលបត្ររដ្ឋរបស់រាជរដ្ឋាភិបាល ការថយចុះនៃករណីឆ្លងជំងឺកូវីដ-១៩ និងការកើនឡើងនៃការប្រមូលចំណូល (ក្រាហ្វ ១.២៩)។ ចិនជាប្រទេសផ្តល់ប្រាក់កម្ចីធំជាងគេ ដែលមានសមាមាត្រ ៤០% នៃបំណុលក្រៅប្រទេសសរុបរបស់រាជរដ្ឋាភិបាល បន្ទាប់មក គឺកម្ចីពហុភាគី (៣២%) ប្រទេសជប៉ុន (១១%) និងប្រទេសកូរ៉េ (៥%) (ក្រាហ្វ ១.៣០)។ យោងតាមការវិភាគចីរភាពបំណុលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បំណុលរបស់រាជរដ្ឋាភិបាល នៅមានកម្រិតហានិភ័យទាបនៅឡើយ។ អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលរាជរដ្ឋាភិបាលក្រៅប្រទេសធៀបនឹងផ.ស.ស. ស្ថិតក្នុងកម្រិត ២៤,៩% ដែលទាបជាងកម្រិតអនុបាតគោល ៤០%។

## ១.៣ សន្និដ្ឋាន

នៅឆ្នាំ២០២២ សេដ្ឋកិច្ចកម្ពុជាបានដើបឡើងប្រកបដោយ ភាពរឹងមាំជាងមុន ដោយសារភាពប្រសើរនៃការនាំចេញ ការដើបឡើងពេញលេញនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងការដើបឡើងឆាប់រហ័សនៃវិស័យទេសចរណ៍។ វិស័យសំណង់ និងអចលនទ្រព្យបានបន្តដើបឡើងយឺត ស្របពេលដែលវិស័យកសិកម្មបានកើនឡើងយឺតជាងឆ្នាំ២០២១។ ភាពប្រសើរឡើងនៃស្ថានភាព

**១.២៩ បំណុលក្រៅប្រទេសរបស់រដ្ឋាភិបាល**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**១.៣០ សមាមាត្របំណុលរដ្ឋាភិបាលក្រៅប្រទេស បែងចែកតាមប្រទេសចម្បងៗ**
(ភាគរយ, គិតត្រឹមឆ្នាំ២០២២)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សេដ្ឋកិច្ចក្នុងស្រុកបានធ្វើឱ្យសមតុល្យសារពើពន្ធមានអតិរេក បន្ទាប់ពីឱនភាព ២ឆ្នាំជាប់គ្នា និងជាកត្តាចម្បងមួយក្នុងការទាក់ទាញលំហូរវិនិយោគផ្ទាល់ពីបរទេសឱ្យកើនឡើង។ ទោះយ៉ាងណា ទុនបម្រុងអន្តរជាតិបានថយចុះដោយសារសម្ពាធពីកត្តាខាងក្រៅ ប៉ុន្តែ នៅតែមានកម្រិតគ្រប់គ្រាន់ក្នុងការរក្សាជំនឿទុកចិត្តរបស់សាធារណជនមកលើសេដ្ឋកិច្ចកម្ពុជា។ កត្តាខាងក្រៅពាក់ព័ន្ធនឹងការកើនឡើងថ្លៃប្រេងនិងម្ហូបអាហារពិភពលោក ក៏បានជះឥទ្ធិពលមកលើអតិផរណាកម្ពុជាដែលបានកើនដល់អត្រាខ្ពស់បំផុតគិតចាប់តាំងពីឆ្នាំ២០១១មក។ ប្រឈមនឹងកំណើនថ្លៃទូទៅ អត្រាប្តូរប្រាក់ប្រាក់រៀលត្រូវបានរក្សាឱ្យមានស្ថិរភាពធៀបនឹងប្រាក់ដុល្លារអាមេរិក ដែលបានការពារអំណាចទិញនៃប្រាក់រៀល និងរួមចំណែកដល់ការកាត់បន្ថយសម្ពាធអតិផរណា។ បញ្ហាប្រឈមនេះ បានបង្ហាញពីសារៈសំខាន់នៃការជំរុញការប្រើប្រាស់ប្រាក់រៀល ដើម្បីផ្តល់ជម្រើសឧបករណ៍នយោបាយរូបិយវត្ថុកាន់តែទូលំទូលាយដល់ធនាគារជាតិនៃកម្ពុជាក្នុងការគ្រប់គ្រងស្ថិរភាពថ្លៃ។

# II ប្រព័ន្ធធនាគារៈ ប្រតិបត្តិការ និងស្ថិរភាព

*ប្រព័ន្ធធនាគារបន្តរក្សាបានភាពធន់និងមានភាពរឹងមាំ ដោយបានផ្តល់មូលនិធិចាំបាច់សម្រាប់គាំទ្រការងើបឡើងវិញនៃសេដ្ឋកិច្ចពីវិបត្តិកូវីដ-១៩។ ក្នុងប្រព័ន្ធធនាគារ គ្រឹះស្ថានធនាគារពាណិជ្ជមានសមាមាត្រធំជាងគេប្រមាណ ៨៥% នៃទ្រព្យសកម្មសរុប បន្ទាប់មក គឺគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDI) និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (MFI)។ កំណើនទ្រព្យសកម្ម ឥណទាន និងប្រាក់បញ្ញើ បានថមថយមក ១២,៦% ១៦,៣% និង ៩,៥% រៀងគ្នា នៅឆ្នាំ២០២២។ ឥណទានរបស់ធនាគារពាណិជ្ជបានកើនឡើង ១៨,១% នៅឆ្នាំ២០២២ ធៀបនឹង ២៦,៤% នៅឆ្នាំ២០២១ ដល់ ១៨៣,៥ ទ្រីលានរៀល (៤៤,៦ ប៊ីលានដុល្លារអាមេរិក) ដែលភាគច្រើនត្រូវបានផ្តល់ទៅកាន់វិស័យឯកជន។ ឥណទានបានកើនឡើងទៅគ្រប់វិស័យ ដោយភាគច្រើនមានកំណើនពីរខ្ទង់ទោះបីជាបានថមថយបន្តិចធៀបនឹងឆ្នាំ២០២១។ ឥណទានគ្រឹះស្ថានធនាគារទៅកាន់វិស័យជួញដូរដុំនិងរាយមានសមាមាត្រ ២៧% នៃឥណទានសរុប ស្របពេលដែលឥណទានទៅកាន់វិស័យសំណង់និងអចលនទ្រព្យមានសមាមាត្រ ២០%។ ទន្ទឹមនេះ សមាមាត្រនៃឥណទានទៅកាន់អង្គភាពគ្រួសារបានថយចុះបន្តិចមក ២២,៦% ដោយកំណើនឥណទានបុគ្គលធ្លាក់ចុះ ដែលអាចបណ្តាលមកពីការកើនឡើងអត្រាការប្រាក់។ ទោះយ៉ាងណា កំណើនឥណទានទិញផ្ទះបន្តមានភាពរឹងមាំ។ ទោះបីជាអនុបាតឥណទានមិនដំណើរការបានកើនពី ១,៨% នៅឆ្នាំ២០២១ ដល់ ២,៩% នៅឆ្នាំ២០២២ ដោយសារការបញ្ចប់វិធានការអនុគ្រោះបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជាក្តី ក៏គុណភាពទ្រព្យសកម្មធនាគារបន្តមានភាពរឹងមាំ។ សម្រាប់ស្ថានភាពសន្ទនីយភាព អនុបាតគ្របខ័ណ្ឌសន្ទនីយភាព (LCR) របស់គ្រឹះស្ថានធនាគារមានកម្រិតខ្ពស់ជាងបទប្បញ្ញត្តិ ១០០% ប៉ុន្តែសូចនាករសន្ទនីយភាពមួយចំនួន បានបង្ហាញពីការថយចុះក្នុងឆ្នាំ២០២២។ ប្រាក់ចំណេញសុទ្ធបន្ទាប់ពីកាត់ពន្ធរួចរបស់គ្រឹះស្ថានធនាគារបានថយចុះ ១១% ដោយសារចំណាយសំវិធានធន និងចំណាយការប្រាក់។ រីឯអនុបាតសាធនភាពរបស់គ្រឹះស្ថានធនាគារវិញ មានកម្រិត ២២% ខ្ពស់ជាងបទប្បញ្ញត្តិតម្រូវដោយធនាគារជាតិនៃកម្ពុជា (១៥%) ដែលឆ្លុះបញ្ចាំងពីលទ្ធភាពរបស់គ្រឹះស្ថានធនាគារក្នុងការស្រូបយកការខាតបង់ ដើម្បីទប់ទល់នឹងវិបត្តិដែលអាចកើតមានឡើង។ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ទ្រព្យសកម្មនិងឥណទានបានកើនឡើងនិងបន្តគាំទ្រដល់តម្រូវការហិរញ្ញប្បទានក្នុងសេដ្ឋកិច្ច។ ទ្រព្យសកម្មសរុបកើនឡើង ១៨,៥% ហើយឥណទានមានកំណើន ២១,៥% ដែលជាចម្បងត្រូវបានផ្តល់ទៅកាន់អង្គភាពគ្រួសារ ពាណិជ្ជកម្ម កសិកម្ម សេវាកម្ម និងវិស័យផ្សេងៗទៀត។ គុណភាពឥណទានក្នុងវិស័យមីក្រូហិរញ្ញវត្ថុបន្តមានភាពរឹងមាំ ជាមួយនឹងអនុបាតឥណទានមិនដំណើរការមានស្ថិរភាព និងមានសន្ទនីយភាពគ្រប់គ្រាន់ ដែលឆ្លុះបញ្ចាំងតាមរយៈអនុបាត LCR លើសពីកម្រិតបទប្បញ្ញត្តិ។ លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់វិស័យមីក្រូហិរញ្ញវត្ថុមានចីរភាព ដែលបានរួមចំណែកដល់ការរក្សាបានអនុបាតសាធនភាពរឹងមាំនៅកម្រិត ១៨,៦% សម្រាប់ MDI និង ៣១,៦% សម្រាប់ MFI។ កំណើនឥណទានរបស់គ្រឹះស្ថានធនាគារឯកទេសបានកើនឡើងដល់ ១៣% ដែលភាគច្រើនជាឥណទានបុគ្គល និងឥណទានទៅកាន់វិស័យកម្មន្តសាលនិងកសិកម្ម។ បន្ថែមលើនេះ គុណភាពឥណទានរបស់គ្រឹះស្ថាននេះស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ជាមួយនឹងអនុបាតឥណទានមិនដំណើរការ ៨,៥% ស្របពេលដែលអនុបាតសាធនភាពមានកម្រិត ៣១,៤%។*

# ២.១ និន្នាការប្រព័ន្ធធនាគារ

**ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា បន្តគ្របដណ្តប់ដោយគ្រឹះស្ថានធនាគារ និងមានទំហំធំធៀបនឹងផ.ស.ស.។** ប្រព័ន្ធធនាគារកម្ពុជា មានទ្រព្យសកម្មភាគច្រើនជារបស់គ្រឹះស្ថានធនាគារពាណិជ្ជចំនួន ៥៩ និងទ្រព្យសកម្មប្រមាណ ២៧០ ទ្រីលានរៀល (៦៥,៧ ប៊ីលានដុល្លារអាមេរិក) គិតត្រឹមខែធ្នូ ឆ្នាំ២០២២ និងមានសមាមាត្រ ៨៤,៥% នៃទ្រព្យសកម្មប្រព័ន្ធធនាគារ[៥]។ MDI ជាគ្រឹះស្ថានមានសមាមាត្រទ្រព្យសកម្មធំបន្ទាប់ដែលមានសមាមាត្រ ១១,៨%។ MFI ចំនួន ៨២ និងគ្រឹះស្ថានធនាគារឯកទេសចំនួន ៩ មានសមាមាត្រទ្រព្យសកម្ម ២,១% និង ០,៩% រៀងគ្នា។ សមាមាត្រ ០,៧% ទៀត គឺ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុចំនួន ១៦ និងគ្រឹះស្ថានឥណទានជនបទចំនួន ២២៣។

| តារាង ២.១៖ រចនាសម្ព័ន្ធប្រព័ន្ធធនាគារកម្ពុជា (ខែធ្នូ ឆ្នាំ២០២២) | | | |
|---|---|---|---|
| គ្រឹះស្ថាន | ចំនួន | ទ្រព្យសកម្ម (ទ្រីលានរៀល) | សមាមាត្រ (% នៃទ្រព្យសកម្មសរុប) |
| ធនាគារពាណិជ្ជ | ៥៩ | ២៧០ | ៨៤,៥% |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ៥ | ៣៧,៨ | ១១,៨% |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ | ៨២ | ៦,៦ | ២,១% |
| ធនាគារឯកទេស | ៩ | ២,៧ | ០,៩% |
| គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ | ១៦ | ២,០៣ | ០,៦% |
| គ្រឹះស្ថានឥណទានជនបទ | ២២៣ | ០,២៧ | ០,១% |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

គិតត្រឹមចុងឆ្នាំ២០២២ ទ្រព្យសកម្មសរុបក្នុងប្រព័ន្ធធនាគារ[៦] មានចំនួន ៣១៧ ទ្រីលានរៀល (៧៧ លានដុល្លារអាមេរិក) ជាមួយនឹងកំណើន ១២,៦% (ឆ្នាំលើឆ្នាំ)។ ទ្រព្យសកម្មប្រព័ន្ធធនាគារមានទំហំប្រមាណ ២៦៤% ធៀបនឹងផ.ស.ស. ឆ្នាំ២០២២។ ទន្ទឹមនេះ ឥណទាន និងប្រាក់បញ្ញើប្រព័ន្ធធនាគារមានកម្រិត ១៨៣% និង ១៤៦% នៃផ.ស.ស. រៀងគ្នា (ក្រាហ្វ ២.១)។ អនុបាតអន្តរការិយកម្ម ដែលវាស់ដោយសូចនាករធនាគារចម្បងៗធៀបនឹងផ.ស.ស. បន្តកើនឡើង ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនទ្រព្យសកម្ម ឥណទាន និងប្រាក់បញ្ញើប្រព័ន្ធធនាគារធៀបនឹងផ.ស.ស.[៧]។ លើសពីនេះ ដោយឥណទានមានកំណើនលឿនជាងប្រាក់បញ្ញើ គម្លាតរវាងឥណទាននិងប្រាក់បញ្ញើបានរីកកាន់តែធំឡើង។

២.១ ប្រព័ន្ធធនាគារនៅកម្ពុជា
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៥] ប្រព័ន្ធធនាគារត្រូវបានកំណត់ដោយរាប់បញ្ចូលគ្រឹះស្ថានធនាគារពាណិជ្ជ គ្រឹះស្ថានធនាគារឯកទេស MDI MFI គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ ស្របតាមដែនច្បាប់និងបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។ ដូចដែលនឹងបង្ហាញនៅក្នុងជំពូកទី៣ខាងមុខ សមាមាត្រនៃវិស័យមិនមែនធនាគារ (ជាចម្បង ក្រុមហ៊ុនធានារ៉ាប់រង) មានការរួមចំណែកតិចតួច ហើយផ្សារមូលបត្រកម្មសិទ្ធិនិងសញ្ញាប័ណ្ណ ក៏ស្ថិតក្នុងដំណាក់អភិវឌ្ឍន៍ដំបូងផងដែរ។ ខណៈដែលការផ្តល់កម្ចីពីធនាគារស្រមោល (shadow banks ឬអ្នកអភិវឌ្ឍន៍អចលនទ្រព្យ) ប្រហែលជាមានទំហំធំគួរឱ្យកត់សម្គាល់ ទិន្នន័យសម្រាប់វិស័យនេះមិនមានគ្រប់គ្រាន់សម្រាប់ការកំណត់ទំហំដែលប៉ះពាល់ជាក់លាក់នោះទេ។
[៦] សម្រាប់ក្រាហ្វ ២.១ ដល់ ២.៣ ប្រព័ន្ធធនាគាររាប់បញ្ចូលតែគ្រឹះស្ថានធនាគារពាណិជ្ជ គ្រឹះស្ថានធនាគារឯកទេស MDI និង MFI តែប៉ុណ្ណោះ (លើកលែងតែទិន្នន័យប្រាក់បញ្ញើដែលរាប់បញ្ចូលត្រឹមគ្រឹះស្ថានធនាគារពាណិជ្ជ និង MDI)។ គ្រឹះស្ថានផ្សេងៗទៀតដូចជា គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទមិនត្រូវបានដាក់បញ្ចូលទេ ដោយសារទិន្នន័យមានកម្រិត ប៉ុន្តែសមាមាត្រនៃគ្រឹះស្ថានទាំងពីរប្រភេទនេះនៅមានទំហំតូច ដូចដែលបានបង្ហាញក្នុងតារាង ២.១។
[៧] ផ.ស.ស.មានកំណើនយឺតក្នុងអំឡុងពេលការរាលដាលនៃជំងឺកូវីដ-១៩ ហើយជាក់ស្តែងមានកំណើនអវិជ្ជមាន -៣,១% នៅឆ្នាំ២០២០។

ការកើនឡើងនៃអន្តរការិយកម្មហិរញ្ញវត្ថុដោយគ្រឹះស្ថានធនាគារ បានជួយដល់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។ ការប៉ាន់ស្មានថ្មីនេះ[៨] បង្ហាញថា ប្រមាណ ៦៧% នៃប្រជាជនកម្ពុជា បានប្រើប្រាស់សេវាហិរញ្ញវត្ថុ និង ទទួលបានប្រយោជន៍ពីសេវាកម្មហិរញ្ញវត្ថុមួយចំនួន ឬ ទាំងបួនប្រភេទ ដែលរួមមាន ឥណទាន ប្រាក់បញ្ញើ បង្វែរប្រាក់ និងសេវាទូទាត់សងប្រាក់អេឡិចត្រូនិក។

**កំណើនទ្រព្យសកម្មនិងប្រាក់បញ្ញើប្រព័ន្ធធនាគារបានថមថយនៅឆ្នាំ២០២២ ដោយប្រាក់បញ្ញើមានកំណើនទន់ខ្សោយជាងឆ្នាំកន្លងមក។** ទ្រព្យសកម្ម ប្រាក់បញ្ញើ និងឥណទាន នៃប្រព័ន្ធធនាគារ មានកំណើនឆ្នាំលើឆ្នាំ ១២,៦% ៩,៥% និង ១៦,៣% រៀងគ្នានៅឆ្នាំ២០២២ (ក្រាហ្វ ២.២)។ គួរកត់សម្គាល់ថា កំណើនប្រាក់បញ្ញើមានការថមថយខ្លាំងធៀបនឹងនិន្នាការប៉ុន្មានឆ្នាំចុងក្រោយ ដែលអាចបណ្ដាលមកពីកម្រិតខ្ពស់នៃអតិផរណាប៉ះពាល់ដល់លទ្ធភាពសន្សំនៃអ្នកដាក់ប្រាក់បញ្ញើ។

**២.២** **ប្រព័ន្ធធនាគារនៅកម្ពុជា**

(កំណើនឆ្នាំលើឆ្នាំ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

កំណើនឥណទាន[៩]ប្រកបដោយចីរភាព បាននាំឱ្យអនុបាតឥណទានធៀបនឹងផ.ស.ស. កើនឡើងដល់ ១៨៩% ដែលកម្រិតខ្ពស់ក្នុងប្រវត្តិសាស្ត្រ (ក្រាហ្វ ២.៣)។ ជាលទ្ធផល គម្លាតឥណទានធៀបនឹងផ.ស.ស.[១០] បានកើនដល់ ៣៩,៥%[១១]។ ល្បឿនកំណើនឥណទានប្រកបដោយចីរភាពនេះ អាចមកពីកំណើនភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ ដោយការបន្តការពង្រីកវិសាលភាពប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលនាំឱ្យមានការបញ្ចេញឥណទានកាន់តែច្រើន។ ការវាយតម្លៃលើទំហំឥណទាននិងល្បឿនកំណើន ក៏ទាមទារឱ្យមានការពិនិត្យគុណភាពនៃទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារផងដែរ ដែលបន្តមានភាពរឹងមាំ (ដូចដែលនឹងពិភាក្សានៅផ្នែកខាងក្រោម) ទោះបីទទួលរងផលប៉ះពាល់ពីវិបត្តិកូវីដ-១៩ ក្តី។

**២.៣** **អនុបាតឥណទានធៀបនឹង ផ.ស.ស. និងកំណើនឥណទាន**

(គិតជាភាគរយ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

---

[៨] របាយការណ៍មូលនិធិអភិវឌ្ឍន៍ទុនរបស់អង្គការសហប្រជាជាតិក្រោមចំណងជើង "ស្ថានភាពបរិយាបន្នហិរញ្ញវត្ថុកម្ពុជាឆ្នាំ២០២១"។

[៩] ឥណទាននៅទីនេះរាប់បញ្ចូលឥណទានរបស់ធនាគារពាណិជ្ជ MDI និង MFI។

[១០] គម្លាតនេះ គឺស្មើនឹងភាពខុសគ្នារវាងអនុបាតឥណទានធៀបនឹងផ.ស.ស. និងនិន្នាការរយៈពេលវែងរបស់អនុបាតនេះ ដែលវាស់ដោយ one-sided HP filter ជាមួយនឹងបារ៉ាម៉ែត្រ ៤០០.០០០។

[១១] ទោះយ៉ាងណា ប្រសិនបើប្រើផ.ស.ស.ដែលត្រូវបានប្តូរមូលដ្ឋានគណនា (ដែលត្រូវបានប៉ាន់ស្មានថានឹងមានចំនួនខ្ពស់ជាងមុន ៣០%) អនុបាតឥណទានធៀបនឹងផ.ស.ស. រួមទាំងគម្លាតផងដែរ នឹងធ្លាក់ចុះដល់ ១៤១% និង ២៨,២% រៀងគ្នា។

## ២.២ គ្រឹះស្ថានធនាគារពាណិជ្ជ

### ក. អន្តរការិយកម្មឥណទាន និងហានិភ័យឥណទាន

គ្រឹះស្ថានធនាគារពាណិជ្ជបានផ្តល់ឥណទានសឹងតែទាំងស្រុងដល់វិស័យឯកជន ក្នុងនោះឥណទានភាគច្រើនសម្រាប់សាជីវកម្ម និងបន្ទាប់មក អង្គភាពគ្រួសារ។ ខណៈដែលកំណើនឥណទានធនាគារទៅកាន់វិស័យឯកជនបន្តមានអត្រាពីរខ្ទង់ កំណើននេះបានថមថយពី ២៦,៤% (ឆ្នាំលើឆ្នាំ) នៅឆ្នាំ២០២១ មក ១៨% នៅឆ្នាំ២០២២ (ក្រាហ្វ ២.៤)។ ការបែងចែកឥណទានទៅតាមវិស័យឯកជន និងវិស័យសាធារណៈ បានបង្ហាញថា ឥណទានសឹងតែទាំងអស់ ត្រូវបានផ្តល់ទៅកាន់វិស័យឯកជន ដោយសមាមាត្រឥណទានទៅកាន់វិស័យសាធារណៈមានកម្រិតត្រឹម ០,៧%ប៉ុណ្ណោះ នៅឆ្នាំ២០២២។ ក្នុងវិស័យសាធារណៈនេះ ហិរញ្ញប្បទានភាគច្រើនត្រូវបានផ្តល់ទៅកាន់សហគ្រាសរដ្ឋ (SOE)។ ការណ៍នេះបង្ហាញថា វិស័យឯកជននៅតែជាវិស័យចម្បងដែលទទួលបានឥណទានពីគ្រឹះស្ថានធនាគារ ដែលបន្តដើរតួនាទីក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច។

ក្នុងវិស័យឯកជន ឥណទានភាគច្រើនត្រូវបានផ្តល់ទៅកាន់សាជីវកម្ម បន្ទាប់មក អង្គភាពគ្រួសារ។ ជាក់ស្តែង ឥណទានសាជីវកម្ម (រាប់បញ្ចូលធុរកិច្ចគ្រប់ប្រភេទនិងទំហំ) ដែលមានចំនួន ១៤២ ទ្រីលានរៀល (៧៧,៤% នៃឥណទានទៅកាន់វិស័យឯកជន) កើនឡើង ១៩,២%។ រីឯឥណទានទៅកាន់អង្គភាពគ្រួសារដែលមានចំនួន ៤១,៥ ទ្រីលានរៀល នៅឆ្នាំ២០២២ មានសមាមាត្រ ២២,៦% នៃឥណទានទៅកាន់វិស័យឯកជន។ សមាមាត្រឥណទានទៅកាន់អង្គភាពគ្រួសារបានថយចុះបន្តិចនៅឆ្នាំ២០២២ បន្ទាប់ពីបានកើនឡើងជាសន្សឹមៗ ពី ១៤,៧% កាលពីឆ្នាំ២០១៦ មក (ក្រាហ្វ ២.៥)។

**ខណៈដែលឥណទានជាប្រាក់រៀលមានកម្រិតខ្ពស់ជាងកម្រិតបទប្បញ្ញត្តិ ១០% ឥណទានភាគច្រើនបន្តត្រូវបានផ្តល់ជាប្រាក់ដុល្លារអាមេរិក។** ការបែងចែកឥណទានទៅតាមប្រភេទរូបិយប័ណ្ណបង្ហាញថា ប្រមាណ

២.៤ ឥណទានផ្តល់ដោយធនាគារពាណិជ្ជ
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

២.៥ ឥណទានទៅកាន់វិស័យឯកជន
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

៨៩% នៃឥណទានសរុបក្នុងឆ្នាំ២០២២ ត្រូវបានផ្តល់ជាប្រាក់ដុល្លារអាមេរិក ជាមួយនឹងសមាមាត្រឥណទានជាប្រាក់រៀលប្រមាណ ១១% (ក្រាហ្វ ២.៦)។ ក្នុងគោលដៅលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចដែលមានកម្រិតដុល្លាររូបនីយកម្មខ្ពស់ ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយប្រកាសមួយនៅឆ្នាំ២០១៦ ដែលតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានឥណទានជារូបិយវត្ថុជាតិយ៉ាងតិច ១០% នៃសំពៀតឥណទានសរុប។ ជាលទ្ធផល សមាមាត្រឥណទានជាប្រាក់រៀលបានកើនឡើងជាលំដាប់ ពី ១,៥% នៅឆ្នាំ២០១៦ ដល់ ១១% នៅឆ្នាំ២០២២ បើទោះបីជាបានថយចុះបន្តិចនៅរយៈពេលពីរឆ្នាំចុងក្រោយនេះក៏ដោយ។

**ការបែងចែកឥណទានតាមវិស័យសេដ្ឋកិច្ចជារួម មានលក្ខណៈពិពិធកម្ម ប៉ុន្តែឥណទានធនាគារពាក់កណ្តាលត្រូវបានផ្តល់ទៅវិស័យធំៗពីរ គឺ វិស័យឥណទានទិញផ្ទះ សំណង់ និងអចលនទ្រព្យ និងវិស័យជួញដូរដុំនិងរាយ។** ឥណទានធនាគារទៅកាន់វិស័យជួញដូររាយបន្តមានទំហំធំជាងគេ ដោយមានចំនួន ៣០,៨ ទ្រីលានរៀល សមាមាត្រ ១៦,៨% នៃឥណទានធនាគារសរុប (ក្រាហ្វ ២.៧)។ គួរបញ្ជាក់ថា គ្រឹះស្ថានធនាគារផ្តល់ហិរញ្ញប្បទានត្រឹមមួយផ្នែកតែប៉ុណ្ណោះសម្រាប់សកម្មភាពអចលនទ្រព្យនិងសំណង់ ដោយហិរញ្ញប្បទានភាគច្រើនបានមកពីវិនិយោគផ្ទាល់បរទេស។

ឥណទានទិញផ្ទះរបស់អង្គភាពគ្រួសារ ដែលមានចំនួន ២៧,៤ ទ្រីលានរៀល គឺជាវិស័យទីពីរដែលទទួលបានឥណទានច្រើនជាងគេ ដោយមានសមាមាត្រប្រមាណ ១៥%។ ឥណទានទៅកាន់វិស័យបន្ទាប់ទាំងបី (ការជួញដូរដុំ សំណង់ និងសកម្មភាពអចលនទ្រព្យ) មានសមាមាត្រប្រហាក់ប្រហែលគ្នានៅកម្រិតប្រមាណ ១០%។ ឥណទានធនាគារទៅកាន់សណ្ឋាគារនិងភោជនីយដ្ឋានដែលជាវិស័យទទួលរងផលប៉ះពាល់ខ្លាំងក្នុងអំឡុងការរាលដាលនៃជំងឺកូវីដ-១៩ពីការបិទខ្ទប់និងការថយចុះនៃចំនួនភ្ញៀវទេសចរ មានសមាមាត្រ ៤,៦%។

២.៦ **ឥណទានតាមប្រភេទរូបិយប័ណ្ណ**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

២.៧ **ឥណទានធនាគារទៅតាមវិស័យ តម្លៃនិងសមាមាត្រ**
(ឆ្នាំ២០២១-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ល្បឿននៃកំណើនឥណទានទៅគ្រប់វិស័យបានថមថយ។** បន្ទាប់ពីមានកំណើនរឹងមាំនៅឆ្នាំ២០២១ ឥណទានទៅកាន់វិស័យចម្បងៗនៅឆ្នាំ២០២២ មានកំណើនយឺតជាងមុន ជាពិសេសកំណើនឥណទានបុគ្គល (១,២%) ដែលតំណាងឱ្យឥណទានទៅកាន់អង្គភាពគ្រួសារ (មិនរាប់បញ្ចូលឥណទានទិញផ្ទះ តែរាប់បញ្ចូលការប្រើប្រាស់ប័ណ្ណឥណទាន) (ក្រាហ្វ ២.៨)។ ការកើនឡើងអត្រាការប្រាក់ក្នុងអំឡុងឆ្នាំ២០២២ បានកាត់បន្ថយតម្រូវការឥណទានរបស់អង្គភាពគ្រួសារសម្រាប់ការខ្ចីយកទៅប្រើប្រាស់ ប៉ុន្តែឥណទានទិញផ្ទះបន្តមានកំណើនរឹងមាំ។ ដូចគ្នានេះដែរ ឥណទានទៅកាន់វិស័យអចលនទ្រព្យមានកំណើនរឹងមាំ ២៨% ស្របពេលដែលវិស័យកម្មន្តសាលមានកំណើនឥណទាន ២៨,៣% ខ្ពស់ជាងគេក្នុងចំណោមវិស័យផ្សេងៗទៀត ដែលបានកើនពីមូលដ្ឋានទាប។

**សមាមាត្រឥណទានទិញផ្ទះ និងឥណទានទៅកាន់វិស័យពាក់ព័ន្ធនឹងអចលនទ្រព្យ បានកើនឡើងជាបន្តបន្ទាប់។** ដោយសារភាពខុសគ្នារវាងល្បឿននិងទំហំឥណទានទៅកាន់វិស័យផ្សេងៗ និន្នាការជារួមក្នុងរយៈពេលវែងនៃការផ្តល់ឥណទានបានបង្ហាញថាមានការផ្លាស់ប្តូរការបែងចែកឥណទាន ជាមួយនឹងវិស័យមួយចំនួនទទួលបានសមាមាត្របន្ថែម (ក្រាហ្វ ២.៩)។ បើធៀបនឹងឆ្នាំ២០២១ សមាមាត្រនៃឥណទានទៅកាន់វិស័យសាជីវកម្មចម្បងៗមានភាពល្អប្រសើរនៅឆ្នាំ២០២២។ សម្រាប់ឥណទានទៅកាន់អង្គភាពគ្រួសារ សមាមាត្រឥណទានបុគ្គលបានថយចុះ ខណៈសមាមាត្រឥណទានទិញផ្ទះកើនឡើង។

**ការប្រមូលផ្តុំនៃឥណទាន បើពិនិត្យលើធនាគារប្រាំធំជាងគេ បានបន្តថយចុះក្នុងពេលកន្លងមក។** សមាមាត្រឥណទានរបស់ធនាគារប្រាំធំជាងគេ នៅឆ្នាំ២០២២ មានកម្រិត ៤៨,៩% ក្នុងនោះធនាគារបីធំជាងគេមានកម្រិត ៣៩,២% (ក្រាហ្វ ២.១០)។ ធនាគារធំជាងគេលេខ៦ ដល់ ១៥ ដែលត្រូវបានរៀបតាមទំហំឥណទានមានសមាមាត្រ ២៣,១% ខណៈធនាគារ ៤៤ ទៀតមាន

**២.៨ កំណើនឥណទានធនាគារតាមវិស័យ**

(ឆ្នាំលើឆ្នាំ, ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៩ ឥណទានធនាគារតាមវិស័យសំខាន់ៗ**

(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.១០ សមាមាត្រឥណទានតាមធនាគារ**

(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សមាមាត្រ ២៨,៥%។[១២] សមាមាត្រនៃធនាគារប្រាំធំជាងគេបានថយចុះជាបន្តបន្ទាប់ ដោយធនាគារតូចៗចាប់ផ្តើមទទួលបានសមាមាត្របន្ថែម ដែលមួយផ្នែកជាលទ្ធផលនៃកំណើនចំនួនគ្រឹះស្ថានធនាគារក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។ លើសពីនេះ ការផ្លាស់ប្តូររចនាសម្ព័ន្ធដែលបានកើតមានឡើងក្នុងវិស័យធនាគារ ដោយសារការកើនឡើងឌីជីថលូបនីយកម្មហិរញ្ញវត្ថុ បានដាក់សម្ពាធលើការប្រកួតប្រជែងក្នុងវិស័យនេះ។

**កំណើនឥណទានទៅកាន់អង្គភាពគ្រួសារត្រូវបានជំរុញជាចម្បងដោយឥណទានទិញផ្ទះ។** ឥណទានទៅកាន់អង្គភាពគ្រួសារមានកំណើន ១៤,៣% នៅឆ្នាំ២០២២ ដែលកំណើននេះ ទោះបីរក្សាបានពីរខ្ទង់មានភាពយឺតជាងគេក្នុងរយៈពេលពីរទៅបីឆ្នាំចុងក្រោយ ដោយសារភាពទន់ខ្សោយនៃកំណើនឥណទានបុគ្គល (រាប់បញ្ចូលប័ណ្ណឥណទាន) (ក្រាហ្វ ២.១១)។ ឥណទានទៅកាន់អង្គភាពគ្រួសារមានចំនួន ៤១,៥ ទ្រីលានរៀល ដែលនាំឱ្យអង្គភាពគ្រួសារជាវិស័យចម្បងដែលមានសមាមាត្រឥណទាន ២២,៦% នៃឥណទានសរុប។ ការបែងចែកឥណទានទៅកាន់អង្គភាពគ្រួសារបានបង្ហាញថាប្រមាណ ៦៦% ជាឥណទានទិញផ្ទះ ហើយក្រៅពីនេះគឺ ឥណទានបុគ្គលរាប់បញ្ចូលទាំងប័ណ្ណឥណទាន (៣៤%)។

**២.១១ ឥណទានធនាគារទៅកាន់អង្គភាពគ្រួសារ**
(ឆ្នាំ២០១៧-២០២២)



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ឥណទានទៅកាន់វិស័យអចលនទ្រព្យ និងសំណង់ មានសមាមាត្រមួយភាគប្រាំនៃឥណទានសរុប។** ឥណទានទៅកាន់វិស័យអចលនទ្រព្យនិងសំណង់កើនឡើង ២៨% និង ១៨,៨% រៀងគ្នានៅឆ្នាំ២០២២ (ក្រាហ្វ ២.១២)។ ចាប់តាំងពីឆ្នាំ២០១៧ កំណើនឥណទានទៅកាន់វិស័យអចលនទ្រព្យ ជារួមមានកំណើនខ្ពស់ជាងកំណើនឥណទានទៅកាន់វិស័យសំណង់។ ជាលទ្ធផល ឥណទានទៅកាន់វិស័យអចលន-ទ្រព្យនិងសំណង់មានសមាមាត្រប្រមាណ ១០% ក្នុងវិស័យនីមួយៗ ធៀបនឹងឥណទានសរុប។

**២.១២ ឥណទានទៅកាន់វិស័យអចលនទ្រព្យនិងសំណង់**
(ឆ្នាំ២០១៧-២០២២)



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

---

[១២] ដោយចំនួនធនាគារមានការប្រែប្រួល ធនាគារផ្សេងៗទៀតដែលដាក់បង្ហាញក្នុងក្រាហ្វក៏មានចំនួនធនាគារខុសៗគ្នាជារៀងរាល់ឆ្នាំផងដែរ។ នៅឆ្នាំ២០២២ ធនាគារសរុបមានចំនួន ៥៩ ហើយធនាគារផ្សេងៗទៀតមានចំនួន ៥៤។

វិធីសាស្ត្រមួយក្នុងការវាយតម្លៃកម្រិតពាក់ព័ន្ធរបស់ធនាគារទៅនឹងវិស័យអចលនទ្រព្យ គឺដោយដាក់បញ្ចូលគ្នានូវឥណទានទៅកាន់ i/-វិស័យអចលនទ្រព្យ ii/-វិស័យសំណង់ និង iii/-ឥណទានទិញផ្ទះរបស់អង្គភាពគ្រួសារ។ តាមរយៈការបូកឥណទានទៅកាន់វិស័យទាំងបីនេះបញ្ចូលគ្នា កម្រិតពាក់ព័ន្ធរបស់ធនាគារទៅនឹងវិស័យអចលនទ្រព្យ មានសមាមាត្រប្រមាណមួយភាគបីនៃសំពៀតឥណទានសរុប (ក្រាហ្វ ២.១៣)។

**២.១៣ ឥណទានទៅកាន់វិស័យពាក់ព័ន្ធនឹងអចលនទ្រព្យ**

(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ទោះបីធនាគារបានផ្តល់ឥណទានច្រើនដល់វិស័យពាក់ព័ន្ធនឹងអចលនទ្រព្យក្តី ក៏ហានិភ័យឥណទានក្នុងវិស័យទាំងបីនៅតែអាចគ្រប់គ្រងបាន។ ម៉្យាងទៀត ហានិភ័យនៃឥណទានទិញផ្ទះមានលក្ខណៈខុសគ្នាពីការផ្តល់ឥណទានដោយផ្ទាល់ទៅកាន់វិស័យសំណង់ និងអចលនទ្រព្យ ដោយសំពៀតឥណទានទិញផ្ទះមានឥណទានតូចៗ ដែលផ្តល់ទៅកាន់អង្គភាពគ្រួសារច្រើន ហើយដូច្នេះមានលក្ខណៈពិពិធកម្ម។ មិនតែប៉ុណ្ណោះ ទីផ្សារអចលនទ្រព្យផ្នែកលំនៅដ្ឋានក៏រក្សាបាននូវភាពធន់ផងដែរ ទោះបីស្ថិតក្នុងការរាលដាលនៃជំងឺកូវីដ-១៩ ជាមួយនឹងតម្លៃលំនៅដ្ឋានធ្លាក់ចុះបន្តិចនៅពាក់កណ្តាលឆ្នាំ២០២២ មុននឹងងើបឡើងវិញ (ក្រាហ្វ ១.១១ ក្នុងជំពូក១)។ ខណៈដែលទីផ្សារអចលនទ្រព្យសម្រាប់ពាណិជ្ជកម្ម បានទទួលរងផលប៉ះពាល់ខ្លាំងក្នុងវិបត្តិកូវីដ-១៩ កម្រិតពាក់ព័ន្ធរបស់ធនាគារទៅកាន់វិស័យនេះមានសមាមាត្រត្រឹម ១៥,៤% នៃឥណទានសរុបទៅកាន់វិស័យអចលនទ្រព្យប៉ុណ្ណោះ។[១៣] គួរបញ្ជាក់ថា ទីផ្សារអចលនទ្រព្យទទួលបានហិរញ្ញប្បទានតែមួយផ្នែកប៉ុណ្ណោះពីធនាគារ ខណៈហិរញ្ញប្បទានភាគច្រើនបានមកពីលំហូរវិនិយោគផ្ទាល់បរទេស។

**បញ្ហាប្រឈមដែលបន្សល់ពីការរាលដាលនៃជំងឺកូវីដ-១៩ និងការបញ្ចប់វិធានការគាំទ្រនិងអនុគ្រោះបទប្បញ្ញត្តិ បាននាំឱ្យគុណភាពទ្រព្យសកម្មថយចុះ។** អនុបាតឥណទានមិនដំណើរការ (NPLR) របស់

[១៣] ផ្នែកខ្លះនៃទីផ្សារអចលនទ្រព្យដូចជា ខុនដូ និងការិយាល័យជួល ជាដើម អាចទទួលរងសម្ពាធ ប្រសិនបើការផ្គត់ផ្គង់ដែលនៅបន្តកើនឡើងលើសពីតម្រូវការដែលមាន ក្នុងអំឡុងពេលដែលអត្រាជួលមានកម្រិតទាប។

គ្រឹះស្ថានធនាគារពាណិជ្ជ ដែលជាសូចនាករចម្បងសម្រាប់វាស់វែងគុណភាពទ្រព្យសកម្ម បានកើនពី ១,៨% នៅឆ្នាំ២០២១ ដល់ ២,៩% នៅឆ្នាំ២០២២ (ក្រាហ្វ ២.១៤)។ ការកើនឡើងនៃឥណទានមិនដំណើរការ (៨៨% ឆ្នាំលើឆ្នាំ) និងកំណើនយឺតជាងមុននៃឥណទាន បានធ្វើឱ្យអត្រាអនុបាតឥណទានមិនដំណើរការកើនឡើង។ ទោះយ៉ាងណា អនុបាត NPLR ២,៩% ស្ថិតនៅកម្រិតទាបដែលឆ្លុះបញ្ចាំងពីការគ្រប់គ្រងបានយ៉ាងល្អ របស់គ្រឹះស្ថានធនាគារក្នុងវិបត្តិកូវីដ-១៩ ដោយមិនមានផលប៉ះពាល់ធ្ងន់ធ្ងរមកលើគុណភាពទ្រព្យសកម្មរបស់ពួកគេ។

អនុបាត NPLR មានកម្រិតទាបក្នុងអំឡុងពេលការរាលដាលនៃជំងឺកូវីដ-១៩ ដោយវិធានការគាំទ្រនិងអនុគ្រោះបទប្បញ្ញត្តិដែលបានដាក់ចេញ បានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារអាចរៀបចំឥណទានឡើងវិញក្នុងអំឡុងឆ្នាំ២០២០-២០២១ ដោយពុំចាំបាច់ផ្លាស់ប្តូរចំណាត់ថ្នាក់ឥណទានដែលត្រូវបានរៀបចំ ហើយដូច្នេះពន្យារការកើនឡើងនៃឥណទានមិនដំណើរការ។[១៤] ទោះយ៉ាងណា ជាមួយនឹងការបញ្ចប់វិធានការគាំទ្រនិងអនុគ្រោះកាលពីខែធ្នូ ឆ្នាំ២០២១ ឥណទានមិនដំណើរការត្រូវបានរំពឹងថានឹងកើនឡើង។

ដោយយោងតាមសារាចរណែនាំរបស់ធនាគារជាតិនៃកម្ពុជា កាលពីខែធ្នូ ឆ្នាំ២០២១[១៥] គ្រឹះស្ថានធនាគារត្រូវធ្វើចំណាត់ថ្នាក់ឥណទានរៀបចំឡើងវិញដែលជាឥណទានដំណើរការ ដោយកំណត់ថាមានស្ថានភាពល្អ និងចាត់ថ្នាក់ជាឥណទានឃ្លាំមើល ជាមួយនឹងសំវិធានធន ៣% នៃចំនួនឥណទាននោះ។ នៅចុងខែធ្នូ ឆ្នាំ២០២២ គ្រឹះស្ថានធនាគារ (និង MDI) បានធ្វើចំណាត់ថ្នាក់ឥណទានរៀបចំឡើងវិញប្រមាណ ៨៥% នៃឥណទានរៀបចំឡើងវិញសរុប ជាឥណទានមានស្ថានភាពល្អ ដែលបង្ហាញថាផលប៉ះពាល់នៃការថមថយសកម្មភាព

**២.១៤ ឥណទានមិនដំណើរការ**

(ឆ្នាំ២០១៦-២០២២)



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[១៤] ឧទាហរណ៍ គ្រឹះស្ថានធនាគារ ជាមធ្យម រៀបចំ ១០,៤% នៃឥណទានសរុប គិតចាប់ពីខែមេសា ឆ្នាំ២០២០ ដល់ខែធ្នូ ឆ្នាំ២០២១។ នៅខែធ្នូ ឆ្នាំ២០២២ ឥណទានរៀបចំឡើងវិញមានសមាមាត្រ ៥,៧% នៃឥណទានសរុប។

[១៥] សម្រាប់ព័ត៌មានលម្អិត សូមមើលសារាចរណែនាំរបស់ធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ស្តីពី កាតព្វកិច្ចធ្វើចំណាត់ថ្នាក់ និងសំវិធានធនចំពោះឥណទានរៀបចំឡើងវិញ។

សេដ្ឋកិច្ចពីការរាលដាលជំងឺកូវីដ-១៩ មកលើគុណភាពទ្រព្យសកម្មធនាគារ នៅមានកម្រិត។

ឥណទានមិនដំណើរការតាមវិស័យនៅឆ្នាំ២០២២ បង្ហាញថា ឥណទានទៅកាន់វិស័យជួញដូរាយមានចំនួនឥណទានមិនដំណើរការច្រើនជាងគេ (៨៦៧ ប៊ីលានរៀល) បន្ទាប់មកវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន (៧២៩ ប៊ីលានរៀល) និងវិស័យសកម្មភាពអចលនទ្រព្យ (៥៧៣ ប៊ីលានរៀល) (ក្រាហ្វ ២.១៥)។ វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានឥណទានមិនដំណើរការច្រើនជាងគេកាលពីឆ្នាំ២០២១ ជាវិស័យតែមួយគត់ដែលមានការថយចុះឥណទានមិនដំណើរការនៅឆ្នាំ២០២២ ខណៈដែលវិស័យផ្សេងៗទៀតមានការកើនឡើងឥណទានមិនដំណើរការ។ ក្នុងរយៈពេលពីរឆ្នាំជាប់ៗគ្នា វិស័យសណ្ឋាគារនិងភោជនីយដ្ឋានមានកំណើនឥណទានមិនដំណើរការខ្ពស់ជាងគេ បន្ទាប់មកគឺ វិស័យជួញដូរាយ។

**អនុបាត NPLR បានកើនឡើងនៅគ្រប់វិស័យ។** អនុបាត NPLR សម្រាប់វិស័យសណ្ឋាគារ និភោជនីយដ្ឋាន បានកើនឡើងបីដងនៅឆ្នាំ២០២២ ដល់ ៩% ពី ៣,១% នៅឆ្នាំ២០២១ ដោយវិស័យនេះបន្តជួបបញ្ហាប្រឈមក្នុងឆ្នាំ២០២២ ស្របពេលដែលនៅមានផលប៉ះពាល់សេសសល់មួយចំនួនពីការរាលដាលជំងឺកូវីដ-១៩ និងការអនុវត្តគោលនយោបាយគ្មានកូវីដរបស់ចិន ដែលប្រជាជនចិនគឺជាភ្ញៀវទេសចរដ៏ចម្បងរបស់កម្ពុជា (ក្រាហ្វ ២.១៦)។ វិស័យសំណង់ និងជាពិសេសវិស័យអចលនទ្រព្យ មានការកើនឡើងគួរឱ្យកត់សម្គាល់នៃអនុបាត NPLR។ សម្រាប់អង្គភាពគ្រួសារ កំណើនអនុបាត NPLR របស់ឥណទានទិញផ្ទះនៅមានកម្រិតទាប បើធៀបនឹងឥណទានបុគ្គល។ ដោយឡែក អនុបាត NPLR របស់វិស័យកសិកម្ម និងរ៉ែ បានថយចុះ។ យ៉ាងណាមិញ អនុបាត NPLR បានកើនឡើងស្ទើរគ្រប់វិស័យ ដែលជារួម បានកើនពី ១,៨% នៅឆ្នាំ២០២១ ដល់ ២,៩% នៅឆ្នាំ២០២២។ គុណភាពទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារជារួម មានភាពរឹងមាំ ទោះបីជាអនុបាត NPLR បាន

**ក្រាហ្វ ២.១៥ ឥណទានមិនដំណើរការតាមវិស័យ**



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២.១៦ អនុបាតឥណទានមិនដំណើរការតាមវិស័យ (ឆ្នាំ២០១៧-២០២២)**



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

កើនឡើងដោយសារផលប៉ះពាល់ពីការរីករាលដាលជំងឺកូវីដ-១៩ ក៏ដោយ។

**សំវិធានធនជាក់លាក់បានកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងឆ្នាំ ដែលបានផ្តល់ឱ្យគ្រឹះស្ថានធនាគារនូវទ្រនាប់បន្ថែមសម្រាប់ទប់ទល់នឹងការថយចុះនៃគុណភាពឥណទាន។** នៅឆ្នាំ២០២២ សំវិធានធនជាក់លាក់បានកើនឡើង ១,៣ ទ្រីលានរៀល ដល់ ៣,១ ទ្រីលានរៀល ដែលជាកំណើនខ្ពស់ជាងគេក្នុងរយៈពេល៦ឆ្នាំចុងក្រោយ (ក្រាហ្វ ២.១៧)។ ទោះយ៉ាងណា អនុបាតសំវិធានធនជាក់លាក់ធៀបនឹងឥណទានមិនដំណើរការ បានថយចុះមក ៥៦% នៅឆ្នាំ២០២២ ដោយសារកំណើនលឿននៃឥណទានមិនដំណើរការ។ កម្រិតសមស្របនៃសំវិធានធនគួរតែអាចជួយគ្រឹះស្ថានធនាគារក្នុងការគ្រប់គ្រងគុណភាពទ្រព្យសកម្មបានប្រសើរជាងមុន។

## ខ. មូលនិធិ និងសន្ទនីយភាព

**ស្ថានភាពសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារបន្តមានភាពរឹងមាំ ទោះបីបានថយចុះបន្តិចក៏ដោយនៅឆ្នាំ២០២២។** កាលពីខែកញ្ញា ឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវអនុបាតគ្របខ័ណ្ឌសន្ទនីយភាព (LCR) ជាមួយនឹងអត្រាកំណត់អប្បបរមា ៦០% ដើម្បីវាស់វែងភាពគ្រប់គ្រាន់ទ្រព្យសកម្ម ដែលមានគុណភាពខ្ពស់ និងងាយបំប្លែងជាសាច់ប្រាក់របស់គ្រឹះស្ថានធនាគារក្នុងស្ថានភាពតានតឹងផ្នែកសន្ទនីយភាពរយៈពេល ៣០ថ្ងៃ។ អត្រាកំណត់អប្បបរមារបស់អនុបាត LCR ត្រូវបានដំឡើងជាបន្តបន្ទាប់ដល់ ១០០% នៅឆ្នាំ២០២០ ដែលត្រូវបានរក្សានៅអត្រានេះមកទល់សព្វថ្ងៃ ស្របតាមអនុសាសន៍នៃបាសែលបី។ ទោះបីជាបានថយចុះក្នុងរយៈពេលពីរឆ្នាំចុងក្រោយ អនុបាត LCR ជារួមរបស់គ្រឹះស្ថានធនាគារពាណិជ្ជ មានកម្រិត ១៤៣,៨% នៅឆ្នាំ២០២២ ខ្ពស់ជាងកម្រិតកំណត់បទប្បញ្ញត្តិ (១០០%) ដែលឆ្លុះបញ្ចាំងពីភាពគ្រប់គ្រាន់នៃសន្ទនីយភាពទប់ទល់នឹងភាពតានតឹងផ្នែកសន្ទនីយភាពរយៈពេលខ្លី (ក្រាហ្វ ២.១៨)។

២.១៧ **ឥណទានមិនដំណើរការ និងសំវិធានធន**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

២.១៨ **អនុបាតគ្របខ័ណ្ឌសន្ទនីយភាព**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ដូចទៅនឹងអនុបាត LCR សូចនាករសន្ទនីយភាពមួយចំនួនរបស់គ្រឹះស្ថានធនាគារក៏បានបង្ហាញពីការថយចុះផងដែរ។ ឧទាហរណ៍ អនុបាតទ្រព្យសកម្មដែលងាយបំប្លែងជាសាច់ប្រាក់ធៀបនឹងទ្រព្យសកម្មសរុបដែលជាសូចនាករបង្ហាញពីកម្រិតសន្ទនីយភាពដើម្បីបំពេញកាតព្វកិច្ចនៃលំហូរសាច់ប្រាក់រំពឹងទុកនិងមិនរំពឹងទុក បានថយចុះពី ១៦,២% នៅឆ្នាំ២០២១ ដល់ ១២,៦% នៅឆ្នាំ២០២២ (ក្រាហ្វ ២.១៩)។ ជាមួយគ្នានេះ អនុបាតទ្រព្យសកម្មងាយបំប្លែងជាសាច់ប្រាក់ធៀបនឹងបំណុលរយៈពេលខ្លី ដែលឆ្លុះបញ្ចាំងពីលទ្ធភាពក្នុងការសងបំណុលរយៈពេលខ្លីដោយប្រើប្រាស់ទ្រព្យសកម្មងាយបំប្លែងជាសាច់ប្រាក់ បានថយចុះពី ២៥,៣% មក ១៨,៩% ក្នុងរយៈពេលដូចគ្នា។ កំណើនលឿននៃការបញ្ចេញឥណទាន (១៨,១%) ធៀបនឹងកំណើនប្រាក់បញ្ញើ (៨,៥%) បាននាំឱ្យអនុបាតឥណទានធៀបនឹងប្រាក់បញ្ញើកើនឡើងដល់ ១២០% នៅឆ្នាំ២០២២។

**២.១៩ អនុបាតសន្ទនីយភាព**

(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សម្រាប់ប្រភពមូលនិធិរបស់គ្រឹះស្ថានធនាគារ ប្រាក់បញ្ញើអតិថិជនមានសមាមាត្រ ៦៨,១% មូលនិធិកម្ចី (ទាំងរយៈពេលវែងនិងខ្លី) មានសមាមាត្រ ១៩,៩% ហើយដើមទុនមានសមាមាត្រ ២១,៩% (ក្រាហ្វ ២.២០)។ ទោះបីសមាមាត្រប្រាក់បញ្ញើបានថយចុះបន្តិច (ដោយសមាមាត្រមូលនិធិកម្ចីកើនឡើង) ធៀបនឹងឆ្នាំ២០២១ ប្រាក់បញ្ញើអតិថិជនបន្តមានសមាមាត្រពីរភាគបីនៃប្រភពមូលនិធិសរុបរបស់គ្រឹះស្ថានធនាគារ។ ការបែងចែកតាមប្រភេទនៃប្រាក់បញ្ញើបង្ហាញថា ប្រាក់បញ្ញើមានកាលកំណត់មានសមាមាត្រខ្ពស់ជាងគេ (៥០,៩%) បន្ទាប់មកប្រាក់បញ្ញើសន្សំ (២៨%) និងប្រាក់បញ្ញើចរន្ត (២០,២%)។ ជាក់ស្តែង សមាមាត្រប្រាក់បញ្ញើមានកាលកំណត់បានកើនឡើងក្នុងពេលដែលអត្រាការប្រាក់មានកម្រិតខ្ពស់ជាងមុន។ ជារួម ប្រាក់បញ្ញើអតិថិជនមានចំនួន ១៥៥ ទ្រីលានរៀល នៅឆ្នាំ២០២២ មានកំណើន (៨,៥%) យឺតជាងកំណើន ១៥,១% កាលពីឆ្នាំ២០២១។

**២.២០ សមាមាត្រប្រភពមូលនិធិធនាគារ**

(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ខណៈដែលប្រាក់បញ្ញើ និងឥណទានភាគច្រើនជាប្រាក់ដុល្លារអាមេរិក សមាមាត្រប្រាក់បញ្ញើជារៀលបានរីកធំជាងមុន។** ប្រាក់បញ្ញើជាដុល្លារអាមេរិកបន្តជាជម្រើសទីមួយសម្រាប់អតិថិជន ដោយមានសមាមាត្រ ៨៨,៨% នៃប្រាក់បញ្ញើសរុបនៅឆ្នាំ២០២២។ ទោះបីដុល្លារូបនីយកម្មនៅមានកម្រិតខ្ពស់ សមាមាត្រប្រាក់បញ្ញើជារៀលបានកើនពី ៩,៦% នៅឆ្នាំ២០២១ ដល់ ១១,២% នៅឆ្នាំ២០២២ (ក្រាហ្វ ២.២១)។ បទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជាដែលតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់ឥណទានជារៀលឱ្យបានយ៉ាងតិចណាស់ ១០% នៃសំពៀតឥណទានសរុប បានជំរុញឱ្យគ្រឹះស្ថានធនាគារបង្កើនការប្រមូលប្រាក់បញ្ញើជារៀល។ ជាមួយនឹងឥណទានជារៀលចំនួន ២០,៧ ទ្រីលានរៀល និងប្រាក់បញ្ញើជារៀល ១៩,៥ ទ្រីលានរៀល នៅឆ្នាំ២០២២ គម្លាតរវាងឥណទាននិងប្រាក់បញ្ញើជារៀលបានថយចុះគួរឱ្យកត់សម្គាល់ធៀបនឹងឆ្នាំមុន។

២.២១ **ប្រាក់បញ្ញើអតិថិជន**
(ឆ្នាំ២០១៧-២០២២)



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ឥណប្រតិទាននៃឥណទាននិងប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារនៅឆ្នាំ២០២២ បានបង្ហាញថាប្រាក់បញ្ញើជារួមមានកម្រិតខ្ពស់ជាងឥណទានរយៈពេលខ្លី ខណៈឥណទានមានកម្រិតខ្ពស់ជាងប្រាក់បញ្ញើចំពោះឥណប្រតិទានចាប់ពីពីរឆ្នាំឡើងទៅ (ក្រាហ្វ ២.២២)។ ជាក់ស្តែងភាពមិនស៊ីគ្នានៃឥណប្រតិទានរវាងឥណទាននិងប្រាក់បញ្ញើ នៅរក្សាបានភាពប្រក្រតី ដោយសារមុខងាររបស់គ្រឹះស្ថានធនាគារក្នុងការបំប្លែងបំណុលរយៈពេលខ្លីឱ្យក្លាយទៅជាទ្រព្យសកម្មរយៈពេលវែង។ ទោះយ៉ាងណាប្រសិនបើភាពមិនស៊ីគ្នានេះមានកម្រិតខ្ពស់ពេក គ្រឹះស្ថានធនាគារអាចនឹងជួបហានិភ័យសន្ទនីយភាព ជាពិសេសនៅពេលដែលធនាគារទាំងនោះពឹងផ្អែកខ្លាំងទៅលើមូលនិធិដែលមានរយៈពេលខ្លី និងមិនសូវមានស្ថិរភាព។

២.២២ **ឥណទាន និងប្រាក់បញ្ញើតាមឥណប្រតិទាន**
(ឆ្នាំ២០២២)



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## គ. លទ្ធភាពស្វែងរកប្រាក់ចំណេញ និងសាធនភាព

**ជាមួយនឹងការកើនឡើងនៃចំណាយសំវិធានធន ប្រាក់ចំណេញសុទ្ធរបស់គ្រឹះស្ថានធនាគារបានថយចុះក្នុងឆ្នាំ២០២២ បន្ទាប់ពីមានកំណើនរឹងមាំក្នុងឆ្នាំ២០២១។** លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់គ្រឹះស្ថានធនាគារ

ពាណិជ្ជបានថយចុះក្នុងឆ្នាំ២០២២ ដោយប្រាក់ចំណេញ-សុទ្ធក្រោយកាត់ពន្ធរួចបានថយចុះ -១១% (ធៀបនឹងកំណើន ២៥% មួយឆ្នាំមុន) មក ៣,៦ ទ្រីលានរៀល (ក្រាហ្វ ២.២៣)។ ការថយចុះនៃប្រាក់ចំណេញសុទ្ធនេះ គឺដោយសារការកើនឡើងនៃចំណាយការប្រាក់ និងចំណាយសំវិធានធននៅពេលដែលធនាគារជាតិនៃកម្ពុជាបានបញ្ចប់វិធានការគាំទ្រនិងអនុគ្រោះបទប្បញ្ញត្តិ ដែលទាមទារឱ្យគ្រឹះស្ថានធនាគារធ្វើចំណាត់ថ្នាក់ឥណទានរៀបចំឡើងវិញ ព្រមទាំងរៀបចំសំវិធានធនឱ្យបានគ្រប់គ្រាន់។ សម្រាប់ផ្នែកចំណូល ខណៈដែលចំណូលការប្រាក់មានកំណើនរឹងមាំ ២៣% ក្នុងឆ្នាំ២០២២ កំណើនចំណូលមិនមែនការប្រាក់បានថមថយមក ១២,៥% ទាបជាងកំណើនក្នុងឆ្នាំ២០២១ (៣៧,២%)។

ប្រាក់ចំណេញសុទ្ធទាបជាងមុនរបស់គ្រឹះស្ថានធនាគារពាណិជ្ជ បាននាំឱ្យមានការថយចុះនៃអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) និងអនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក (ROE) ក្នុងឆ្នាំ២០២២ (ក្រាហ្វ ២.២៤)។ អនុបាត ROE បានថយចុះពី ៩% ក្នុងឆ្នាំ២០២១ មក ៧% ក្នុងឆ្នាំ២០២២។ ដូចគ្នានេះដែរ អនុបាត ROA បានថយចុះ ០,៣៤% មក ១,៣៦% ក្នុងឆ្នាំ២០២២។ ការថយចុះនៃអនុបាតទាំងពីររបស់គ្រឹះស្ថានធនាគារពាណិជ្ជ គឺដោយសារការកើនឡើងនៃទ្រព្យសកម្ម (១១,៧%) និងមូលនិធិភាគទុនិក (១២,៨%) ខណៈប្រាក់ចំណេញសុទ្ធបានថយចុះ (-១១%)។

អនុបាតប្រសិទ្ធភាពប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារពាណិជ្ជ ដែលត្រូវបានវាស់ដោយចំណាយប្រតិបត្តិការធៀបនឹងចំណូលប្រតិបត្តិការដុល បានថយចុះបន្តិចក្នុងឆ្នាំ២០២២ មក ៤៦,៨% (ក្រាហ្វ ២.២៥)។ ការថយចុះនេះបង្ហាញពីភាពប្រសើរឡើង[១៦]នៃប្រសិទ្ធភាពប្រតិបត្តិការ ទោះបីជាចំណាយប្រតិបត្តិការបានកើនឡើង ២០% ខណៈចំណូលប្រតិបត្តិការដុលកើនឡើងត្រឹម ១៦%

**២.២៣ លទ្ធភាពស្វែងរកប្រាក់ចំណេញ**

(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.២៤ ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និងមូលនិធិភាគទុនិកនៃធនាគារ**

(ឆ្នាំ២០១៦-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.២៥ អនុបាតប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយនៃធនាគារ**

(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[១៦] អនុបាតប្រសិទ្ធភាពប្រតិបត្តិការកាន់តែទាប គឺកាន់តែប្រសើរ ដែលបង្ហាញថាគ្រឹះស្ថានធនាគារប្រើប្រាស់ចំណាយប្រតិបត្តិការតិចជាងមុនដើម្បីបង្កើនចំណូល។

ដោយសារចំណូលប្រតិបត្តិការដុលមានមូលដ្ឋានធំជាងចំណាយប្រតិបត្តិការ។

**អនុបាតសាធនភាពរបស់គ្រឹះស្ថានធនាគារបន្តមានកម្រិតខ្ពស់ជាងបទប្បញ្ញត្តិតម្រូវដោយធនាគារជាតិនៃកម្ពុជា។** គ្រឹះស្ថានធនាគារពាណិជ្ជបន្តរក្សាបានកម្រិតខ្ពស់នៃអនុបាតសាធនភាព ២២,២% ប៉ុន្តែបានថយចុះបន្តិចពី ២៣% នៅឆ្នាំ២០២១ (ក្រាហ្វ ២.២៦)។ ការថយចុះបន្តិចនៃអនុបាតសាធនភាពនេះ គឺដោយសារកំណើនលឿននៃទ្រព្យសកម្មថ្លឹងដោយទម្ងន់ហានិភ័យ (១៧,៣%) ធៀបនឹងកំណើនដើមទុន (១៣,២%)។ ទោះយ៉ាងណា អនុបាតសាធនភាពដែលជាសូចនាករបង្ហាញពីលទ្ធភាពក្នុងការស្រូបយកការខាតបង់របស់គ្រឹះស្ថានធនាគារ មានកម្រិតខ្ពស់ជាងបទប្បញ្ញត្តិ ១៥%។ ជាក់ស្តែង សូម្បីតែអនុបាតដើមទុនថ្នាក់ទីមួយ ក៏មានកម្រិត ១៩,៤% ខ្ពស់ជាងកម្រិតបទប្បញ្ញត្តិនេះផងដែរ។ ក្នុងឆ្នាំ២០២២ គ្រឹះស្ថានធនាគារត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ទ្រនាប់ដើមទុនខនសើវេសិន (CCB) ដែលជាផ្នែកមួយនៃវិធានការឆ្លើយតបរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីជួយគ្រឹះស្ថានធនាគារទប់ទល់នឹងវិបត្តិកូវីដ១៩។

ការបែងចែកប្រភេទដើមទុនបានបង្ហាញថា ដើមទុនថ្នាក់ទីមួយ និងដើមទុនថ្នាក់ទីពីរ មានកំណើនវិជ្ជមាន ហើយដើមទុនថ្នាក់ទីមួយមានកំណើនខ្ពស់ជាង (១៣,៨% និង ៩,៦% រៀងគ្នា)។ ជាលទ្ធផល សមាមាត្រដើមទុនថ្នាក់ទីមួយបានកើនដល់ ៨៧,៤% នៃដើមទុនសរុប។ ភាពរឹងមាំនៃអនុបាតសាធនភាពរបស់គ្រឹះស្ថានធនាគារ គាំទ្រដោយដើមទុនថ្នាក់ទីមួយដ៏មានគុណភាពខ្ពស់ បន្តរួមចំណែកដល់ការរក្សាបានភាពធន់ក្នុងប្រព័ន្ធធនាគារ ទោះបីស្ថិតក្រោមស្ថានភាពមានវិបត្តិ ដូចជាក្នុងអំឡុងពេលវិបត្តិកូវីដ-១៩ ដែលប្រព័ន្ធធនាគាររក្សាបានភាពរឹងមាំ។

ការធ្វើស្ត្រេសតេស្តរបស់ធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងសាកល្បងភាពធន់របស់ធនាគារក្រោមសេណារីយ៉ូស្ត្រេសដែលអាចកើតមានឡើង បានបង្ហាញថា គ្រឹះស្ថានធនាគារមានដើមទុនគ្រប់គ្រាន់។

២.២៦ **ភាពគ្រប់គ្រាន់នៃដើមទុន**
(ឆ្នាំ២០១៧-២០២២)




ប្រភពៈ ធនាគារជាតិនៃកម្ពុជា

ឧទាហរណ៍ ទោះបីស្ថិតក្រោមសេណារីយ៉ូស្រ្តេសខ្លាំង ដែលអនុបាត NPLR របស់គ្រឹះស្ថានធនាគារនីមួយៗបានកើនឡើង ៣%[១៧] គ្រឹះស្ថានធនាគារទាំងអស់ លើកលែងធនាគារមួយ[១៨] អាចរក្សាបានអនុបាតសាធនភាពលើស ១៥% ឆ្លុះបញ្ចាំងពីទ្រនាប់ដើមទុនដែលគ្រឹះស្ថានទាំងនោះមានសម្រាប់ទប់ទល់នឹងការថយចុះគុណភាពទ្រព្យសកម្មដែលអាចកើតមានឡើង។

អនុបាតដើមទុនធៀបនឹងឥណទានសុទ្ធបានកើនឡើងដល់ ២៨% នៅឆ្នាំ២០២២ ដែលឆ្លុះបញ្ចាំងពីកម្រិតទ្រនាប់ដើមទុនដែលគ្រឹះស្ថានធនាគារអាចប្រើប្រាស់បាន ក្នុងករណីដែលឥណទានមួយចំនួនប្រែក្លាយជាឥណទានមិនដំណើរការ។ ដោយឡែក អនុបាតឥណទានមិនដំណើរការធៀបនឹងដើមទុន ដែលជាសូចនាករបង្ហាញពីកម្រិតដើមទុនដែលអាចត្រូវបានប្រើប្រាស់អស់ដោយសារឥណទានបាត់បង់ បានកើនឡើងជិតពីរដង នៅឆ្នាំ២០២២ ដោយសារកំណើនខ្ពស់ជាងមុននៃឥណទានមិនដំណើរការ (ក្រាហ្វ ២.២៧)។ ទោះបីជាឥណទានមិនដំណើរការបានកើនឡើងបន្ទាប់ពីវិបត្តិកូវីដ-១៩ អនុបាតសាធនភាពជារួមរបស់គ្រឹះស្ថានធនាគារបន្តមានភាពរឹងមាំ និងខ្ពស់ជាងកម្រិតបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។

**២.២៧ ភាពគ្រប់គ្រាន់នៃដើមទុន**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[១៧] គិតត្រឹមខែធ្នូ ឆ្នាំ២០២២ អនុបាត NPLR មានកម្រិត ២,៩%។
[១៨] គ្រឹះស្ថានធនាគារតែមួយប៉ុណ្ណោះដែលមានអនុបាតសាធនភាព ១៤,៥% ក្រោមកម្រិតបទប្បញ្ញត្តិ (១៥%) នៅពេលស្ថិតក្រោមសេណារីយ៉ូស្រ្តេសនេះ។

**ប្រអប់ ២.១**

## យុទ្ធសាស្ត្រចាកចេញពីវិបត្តិរបស់ធនាគារជាតិនៃកម្ពុជា៖ ការធ្វើប្រក្រតីកម្មវិធានការគាំទ្រដែលដាក់ចេញក្នុងវិបត្តិកូវីដ-១៩

ការរាលដាលនៃជំងឺកូវីដ-១៩ បានជំរុញឱ្យធនាគារជាតិនៃកម្ពុជាដាក់ចេញវិធានការគាំទ្រជាបន្តបន្ទាប់ ដើម្បីគាំទ្រប្រព័ន្ធធនាគារ សម្រាលបន្ទុកដល់អ្នកខ្ចីប្រាក់ និងជួយដល់ដំណើរការងើបឡើងវិញនៃសេដ្ឋកិច្ច។ តារាងខាងក្រោមនេះបង្ហាញពីវិធានការគាំទ្រដែលបានដាក់ចេញកន្លងមកដោយធនាគារជាតិនៃកម្ពុជា ក្នុងអំឡុងឆ្នាំ២០២០ និងឆ្នាំ២០២១។

**តារាង ២.២ វិធានការគាំទ្ររបស់ធនាគារជាតិនៃកម្ពុជាក្នុងអំឡុងវិបត្តិកូវីដ-១៩**

| វិធានការក្នុងឆ្នាំ២០២០ | វិធានការក្នុងឆ្នាំ២០២១ |
|---|---|
| i/-បន្តការអនុវត្តទ្រនាប់ដើមទុនអនុរក្សន៍ (CCB) នៅកម្រិត ១,២៥% ចាប់ពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០<br>ii/-កាត់បន្ថយអត្រាការប្រាក់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ដោយ ០,៥០% សម្រាប់គ្រប់ឥណប្រតិទាន ចាប់ពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០<br>iii/-កាត់បន្ថយអត្រាការប្រាក់មូលបត្រអាចជួញដូរបាន (NCD) ជារៀលនិងដុល្លារអាមេរិក មកកម្រិតសមស្រប<br>iv/-កាត់បន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ចពី ៨% ជារៀល និង ១២,៥% ជារូបិយប័ណ្ណបរទេស មក ៧% សម្រាប់រូបិយប័ណ្ណទាំងអស់ សម្រាប់រយៈពេល ៦ខែ ចាប់ពីខែមេសា ឆ្នាំ២០២០តទៅ<br>v/-ចេញសារាចរណែនាំទៅកាន់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្តីពី ការរៀបចំឥណទានឡើងវិញជូនអ្នកខ្ចីប្រាក់ដែលជួបបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុ (ប៉ុន្តែនៅមានលទ្ធភាពសងបំណុលដោយមិនប្រែក្លាយជាឥណទានមិនដំណើរការ) ក្នុងវិស័យអាទិភាពនិងវិស័យផ្សេងៗទៀត នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០<br>vi/-ទទួលស្គាល់ប្រាក់ចំណេញសុទ្ធដែលធ្វើសវនកម្មរួច ប្រចាំត្រីមាស ដើម្បីដាក់បញ្ចូលក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធ ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ និង<br>vii/-ហាមឃាត់ការបែងចែកភាគលាភដល់ភាគទុនិក សម្រាប់ប្រាក់ចំណេញ ដែលធ្វើសវនកម្មរួចក្នុងឆ្នាំ២០២០។ | i/-តម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធ្វើសំវិធានធនផ្អែកលើការវាយតម្លៃលើឥណទានរៀបចំឡើងវិញទាំងអស់ ស្របតាមសារាចរណែនាំចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១<br>ii/-អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញ សម្រាប់ឥណទានថ្មីដែលទទួលរងផលប៉ះពាល់ពីការរាលដាលជំងឺកូវីដ-១៩ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ហើយការអនុវត្តនេះមិនរាប់បញ្ចូលអតិថិជនដែលធ្លាប់បានស្នើសុំរៀបចំឥណទានឡើងវិញរួចហើយចាប់ពីខែមីនា ឆ្នាំ២០២០ នោះឡើយ<br>iii/-អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រើប្រាស់ទ្រនាប់ដើមទុន CCB ទាំងស្រុង<br>iv/-ហាមឃាត់ការបែងចែកភាគលាភដល់ភាគទុនិក សម្រាប់ប្រាក់ចំណេញដែលធ្វើសវនកម្មរួចក្នុងឆ្នាំ២០២១ លុះត្រាតែទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា និង<br>v/-រក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ចនៅ ៧% រហូតដល់មានការជូនដំណឹងពេលក្រោយ។ |

ស្របពេលដែលនយោបាយវិត្ថារកម្ម និងវិធានការគាំទ្រនិងអនុគ្រោះបទប្បញ្ញត្តិត្រូវបានអនុវត្ត ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំប្រកបដោយភាពប្រុងប្រយ័ត្ននូវយុទ្ធសាស្ត្រចាកចេញពីវិបត្តិ ដើម្បីធានាថាវិធានការគាំទ្រដែលបានដាក់ចេញកន្លងមក អាចត្រូវបានបញ្ចប់ដោយមិនមានផលប៉ះពាល់ពីហានិភ័យចិត្តសាស្ត្រ (Moral Hazard)។ ស្របតាមដំណើរការនៃការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា ធនាគារជាតិនៃកម្ពុជាបានចាប់ផ្តើមធ្វើប្រក្រតីកម្មវិធានការគាំទ្រជាសន្សឹមៗ តាមរយៈការតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធ្វើសំវិធានធនដំបូង សម្រាប់ឥណទានរៀបចំឡើងវិញមុនឆ្នាំ២០២២ និងបន្ទាប់មកសម្រាប់ឥណទានរៀបចំឡើងវិញទាំងអស់ នៅពេលដែលវិធានការអនុគ្រោះបទប្បញ្ញត្តិបានបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជាបានដំឡើងអត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណបរទេសពី ៧% ដល់ ៩% នៅខែមករា ឆ្នាំ២០២៣ និងពី ៩% ដល់ ១២,៥% នៅឆ្នាំ២០២៤ ខណៈដែលរក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀលនៅដដែល ៧% (ក្រាហ្វ ២.២៨)។ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ចេញសេចក្តីណែនាំចំនួនពីរផងដែរសម្រាប់ការត្រួតពិនិត្យធនាគារ ដែលរួមមាន៖ i/-សេចក្តីណែនាំលើការអនុវត្តប្រកាសស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ឹមភែរមិន និង ii/-សេចក្តីណែនាំលើការប្រើប្រាស់វិធីសាស្ត្រស្រេបសម្រាប់អនុវត្តការត្រួតពិនិត្យផ្អែកលើហានិភ័យប្រកបដោយប្រសិទ្ធភាព។ CCB ត្រូវបានអនុវត្តឡើងវិញដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបំពេញទ្រនាប់ដើមទុន CCB ឱ្យបាន ១,២៥% នៃទ្រព្យសកម្មថ្លឹងដោយទម្ងន់ហានិភ័យ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ និងឱ្យបាន ២,៥% នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ (ក្រាហ្វ ២.២៨)។ មិនតែប៉ុណ្ណោះ ក្របខ័ណ្ឌបទប្បញ្ញត្តិនៃសាធនភាពក៏កំពុងត្រូវបានធ្វើបច្ចុប្បន្នកម្មផ្អែកតាមស្តង់ដាបាសែលបី ដែលជាផ្នែកមួយនៃការអនុវត្តផែនការត្រួតពិនិត្យផ្អែកលើហានិភ័យ។ ជារួម នយោបាយម៉ាក្រូប្រុងប្រយ័ត្ននឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ និងប្រព័ន្ធធនាគាររឹងមាំ។

២.២៨ **អត្រាប្រាក់បម្រុងកាតព្វកិច្ច និងទ្រនាប់ដើមទុន**

(ឆ្នាំ២០១៩-២០២៤)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**វិស័យមីក្រូហិរញ្ញវត្ថុបន្តមានកំណើនរឹងមាំ ដោយសារកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការជំរុញការចាក់វ៉ាក់សាំង និងការដាក់ចេញគោលនយោបាយគាំទ្រ ដើម្បីកាត់បន្ថយផលប៉ះពាល់ពីការរាលដាលជំងឺកូវីដ-១៩។** គិតត្រឹមចុងឆ្នាំ២០២២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDI) មានចំនួន ៥ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (MFI) មានចំនួន ៨២ ដែលមានសាខាសរុបចំនួន ១.១០៩ កំពុងដំណើរការនៅទូទាំងប្រទេស។ ទ្រព្យសកម្មសរុបក្នុងវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើង ១៨,៥% ដល់ ៤៤,៤ ទ្រីលានរៀល (១០,៨ ប៊ីលានដុល្លារអាមេរិក) ធៀបនឹង ៧,៣% ក្នុងឆ្នាំ២០២១។ ទ្រព្យសកម្មរបស់ MDI បានបន្តកើនឡើង ១៧,៣% ដល់ ៣៧,៨ ទ្រីលានរៀល (៩,២ ប៊ីលានដុល្លារអាមេរិក) ហើយទ្រព្យសកម្មរបស់ MFI បានកើនឡើង ២៦,៥% ដល់ ៦,៦ ទ្រីលានរៀល (១,៦ ប៊ីលានដុល្លារអាមេរិក) (ក្រាហ្វ ២.២៩)។

២.២៩ **ទ្រព្យសកម្មក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ក. ប្រតិបត្តិការឥណទាន

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់លទ្ធភាពដើម្បីទទួលបានសេវាហិរញ្ញវត្ថុដល់អាជីវកម្មខ្នាតតូចនិងសហគមន៍តាមជនបទ ស្របតាមកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូចនិងមធ្យម។** សម្រាប់ MDI ឥណទានទៅកាន់អង្គភាពគ្រួសារមានសមាមាត្រធំជាងគេ ៣៣,២% នៃឥណទានសរុប បន្ទាប់មកគឺ ពាណិជ្ជកម្មនិងការជួញដូរ (២៤,៦%) កសិកម្ម (១៩,៦%) សេវាកម្មនិងផ្សេងៗ (១៣,៣%)។ គួររំលេចថា សមាមាត្រឥណទានទៅកាន់ពាណិជ្ជកម្មនិងការជួញដូរ និងសេវាកម្ម មានការកើនឡើង ខណៈដែលសមាមាត្រឥណទានទៅកាន់កសិកម្មមានការថយចុះបន្តិច (ក្រាហ្វ ២.៣០)។

២.៣០ **ចំណែកឥណទានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើតាមវិស័យ**
(គិតជាភាគរយ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ដូចគ្នានេះដែរ ឥណទានទៅកាន់អង្គភាពគ្រួសាររបស់ MFI មានសមាមាត្រធំជាងគេ ៣៣,១% នៃឥណទានសរុប បន្ទាប់មកពាណិជ្ជកម្មនិងការជួញដូរ

(១៦,១%) សេវាកម្ម (១៥,២%) សំណង់ (១៣%) និងកសិកម្មនិងផ្សេងៗ (៧,៥%)។ ឥណទានទៅកាន់វិស័យសេវាកម្ម កម្មន្តសាល និងសំណង់ មានសមាមាត្រច្រើនជាងមុន ខណៈដែលសមាមាត្រឥណទានទៅកាន់អង្គភាពគ្រួសារ កសិកម្ម និងពាណិជ្ជកម្មនិងការជួញដូរបានថយចុះបន្តិច (ក្រាហ្វ ២.៣១)។

**កំណើនឥណទានដ៏រឹងមាំនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុត្រូវបានគាំទ្រដោយការបង្កើនឥណទានពី MDI និង MFI។** កំណើនឥណទានសរុបក្នុងវិស័យមីក្រូហិរញ្ញវត្ថុក្នុងឆ្នាំ២០២២ មានអត្រា ២១,៥% ទាបជាងឆ្នាំ២០២១ (២៦%) បន្ទាប់ពីមានការថមថយសន្ទុះកំណើនជាបណ្ដោះអាសន្ននៃឥណទានប្រុងប្រយ័ត្នទុកមុន (Precautionary Loan) របស់អាជីវកម្មក្នុងអំឡុងពេលការរាលដាលនៃជំងឺកូវីដ-១៩។ ដោយឡែក កំណើនឥណទានបានកើនឡើងដល់ ១៩,៧% សម្រាប់ MDI ធៀបនឹង ១២,៨% ក្នុងឆ្នាំ២០២១ ជាចម្បងរួមចំណែកដោយឥណទានទៅកាន់អង្គភាពគ្រួសារ (៧,៩%) ពាណិជ្ជ-កម្មនិងការជួញដូរ (៥,៦%) កសិកម្ម (៤,១%) និងសេវាកម្មនិងផ្សេងៗ (១,៦%) (ក្រាហ្វ ២.៣២)។

ឥណទានរបស់ MFI បានកើនឡើង ៣២,៨% ខ្ពស់ជាងកំណើនឆ្នាំមុន ២៥,៨% ដែលជាចម្បងរួមចំណែកដោយឥណទានទៅកាន់អង្គភាពគ្រួសារ (១១,៦%) សេវាកម្ម (៤,៧%) ពាណិជ្ជកម្មនិងការជួញដូរ (៣,៩%) សំណង់ (៣,៩%) កម្មន្តសាល (៣,៤%) និងកសិកម្មនិងផ្សេងៗ (១,៥%)។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដើរតួជាអ្នកផ្ដល់ហិរញ្ញប្បទានដ៏សំខាន់ទៅកាន់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) និងសហគមន៍នៅតាមទីជនបទ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងគម្រោងហិរញ្ញប្បទានរបស់សហគ្រាសធុនតូចនិងមធ្យមសម្រាប់ការស្ដារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩ (ក្រាហ្វ ២.៣៣)។

២.៣១ ចំណែកឥណទានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើតាមវិស័យ

(គិតជាភាគរយ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

២.៣២ ការរួមចំណែករបស់មីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើតាមវិស័យ

(គិតជាភាគរយ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

២.៣៣ ការរួមចំណែករបស់មីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើតាមវិស័យ

(គិតជាភាគរយ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ. គុណភាពឥណទាន

**សម្រាប់គុណភាពឥណទាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រក្សាអនុបាតឥណទានមិនដំណើរការនៅកម្រិតអាចគ្រប់គ្រងបាន នៅឆ្នាំ២០២២ ជាមួយនឹងការធ្វើសំវិធានធនគ្រប់គ្រាន់។** ខណៈដែលឥណទានហួសកាលកំណត់ទូទាត់សងរយៈពេល ៣០ថ្ងៃ របស់ MDI បានកើនឡើងពី ៣៨២ ប៊ីលានរៀល ក្នុងឆ្នាំ២០២១ ដល់ ៤៦០ ប៊ីលានរៀល ក្នុងឆ្នាំ២០២២ ជាមួយនឹងកំណើន ១៩,១% អនុបាតឥណទានមិនដំណើរការបន្តរក្សាបានក្នុងកម្រិតប្រហាក់ប្រហែលនឹងឆ្នាំមុនដដែលគឺ ១,៣៨% ដោយសារតែការកើនឡើងនៃសំពៀតឥណទាន។ MDI បន្តរក្សាកម្រិតសំវិធានធនគ្រប់គ្រាន់សម្រាប់ទប់ទល់នឹងការធ្លាក់ចុះគុណភាពឥណទាន។ អនុបាតសំវិធានធនជាក់លាក់ធៀបនឹងឥណទានមិនដំណើរការរបស់ MDI បន្តមានស្ថិរភាពក្នុងកម្រិត ៧៥% ក្នុងឆ្នាំ២០២២ (ក្រាហ្វ ២.៣៤)។ ជាមួយគ្នានេះ ឥណទានហួសកាលកំណត់ទូទាត់សងរយៈពេល ៣០ថ្ងៃ របស់ MFI បានកើនឡើង ៣៥,៦% ដល់ ៥២០ ប៊ីលានរៀល ថមថយល្បឿនកំណើនធៀបនឹងឆ្នាំ២០២១ (៦៩,៧%) ដោយសារតែអនុបាតឥណទានមិនដំណើរការបន្តមានស្ថិរភាពក្នុងកម្រិត ៩% ក្នុងពេលដែលស្ថានភាពធុរកិច្ចមានភាពប្រសើរឡើង និងការបញ្ចប់វិធានការអនុគ្រោះបទប្បញ្ញត្តិ។ ទោះបីជាអតិថិជនភាគច្រើនមានលទ្ធភាពក្នុងការសងត្រលប់ឥណទានរបស់ខ្លួន អតិថិជនមួយចំនួនតូចបន្តប្រឈមនឹងបញ្ហាក្នុងការសងត្រលប់ ដែលជំរុញឱ្យ MFI ត្រូវបន្តតាមដានលទ្ធភាពក្នុងការសងត្រលប់របស់អតិថិជនទាំងនេះនាពេលអនាគត (ក្រាហ្វ ២.៣៥)។

ផ្អែកលើទិន្នន័យរបស់ក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (ខេមបូឌា) អតិថិជនខ្ចីប្រាក់ពី MFI ៥,៧% បានខកខានសងប្រាក់រយៈពេល ៣០ថ្ងៃ។ ជាមួយនឹងតួនាទីដ៏សំខាន់របស់ MFI សម្រាប់ MSMEs និងសហគមន៍ជនបទ ធនាគារជាតិនៃកម្ពុជា នៅតែបន្តពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ ដើម្បីការពារអតិថិជន និងចីរភាពនៃវិស័យមីក្រូហិរញ្ញវត្ថុ។

**២.៣៤ គុណភាពឥណទានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**
(ឆ្នាំ២០១៧-ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៣៥ គុណភាពឥណទានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ**
(ឆ្នាំ២០១៧-ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## គ. ស្ថានភាពសន្ទនីយភាព និងមូលនិធិ

**ស្ថានភាពមូលនិធិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបន្តមានភាពរឹងមាំនិងងាយបំប្លែងជាសាច់ប្រាក់ ដែលអាចរក្សាបាននូវភាពធន់នឹងភាពរអាក់រអួលផ្នែកសន្ទនីយភាព ស្របពេលដែលសេដ្ឋកិច្ចកំពុងងើបឡើងវិញ។** ស្ថានភាពសន្ទនីយភាពរបស់ MDI ដែលវាស់ដោយអនុបាតគ្របខណ្ឌសន្ទនីយភាពយោងតាមគោលការណ៍បាសែលបី បានថយចុះបន្តិចមក ១៥៦,៧% នៅចុងឆ្នាំ២០២២ (១៦០% នៅចុងឆ្នាំ២០២១) ដោយសារការធ្លាក់ចុះនៃទ្រព្យសកម្មងាយបំប្លែងជាសាច់ប្រាក់ក្នុងកម្រិត -១០,៩% (ឆ្នាំលើឆ្នាំ) និងលំហូរចេញនៃសាច់ប្រាក់សុទ្ធ -៨,៥% ប៉ុន្តែបន្តស្ថិតក្នុងកម្រិតខ្ពស់ជាងកម្រិតអប្បបរមាបទប្បញ្ញត្តិ (១០០%) (ក្រាហ្វ ២.៣៦)។




**២.៣៦ អនុបាតគ្របខណ្ឌសន្ទនីយភាព គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ** (ឆ្នាំ២០១៧-២០២២)

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សមាមាត្រប្រាក់បញ្ញើអតិថិជនធៀបនឹងប្រភពមូលនិធិសរុបបានធ្លាក់ចុះបន្តិចមក ៥៦% (៥៧% ក្នុងឆ្នាំមុន) ហើយដើមទុនមានសមាមាត្រ ២៦% និងមូលនិធិកម្ចីមានសមាមាត្រ ១៨%។ ទោះបីសមាមាត្របានថយចុះបន្តិច ប្រាក់បញ្ញើអតិថិជនបន្តជាប្រភពមូលនិធិចម្បងសម្រាប់ MDI ដែលឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធមូលនិធិប្រកបដោយស្ថិរភាព (ក្រាហ្វ ២.៣៧)។ ប្រាក់បញ្ញើអតិថិជនបានកើនឡើង ១៧,១% ដល់ ១៩,៩ ទ្រីលានរៀល (៤,៨ ប៊ីលានដុល្លារអាមេរិក)។




**២.៣៧ រចនាសម្ព័ន្ធមូលនិធិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ** (ឆ្នាំ២០១៧-២០២២)

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

គិតត្រឹមឆ្នាំ២០២២ មូលនិធិកម្ចីសរុបរបស់ MDI បានកើនឡើង ១៨,១% ដល់ ៩,២ ទ្រីលានរៀល (២,៥ ប៊ីលានដុល្លារអាមេរិក) បើធៀបនឹងឆ្នាំ២០២១ (-៨%)។ មូលនិធិកម្ចីភាគច្រើនរបស់ MDI ជាកម្ចីរយៈពេលវែងដែលមានសមាមាត្រ ៨១% ខណៈសមាមាត្រមូលនិធិកម្ចីរយៈពេលខ្លីបានកើនឡើងបន្តិចធៀបនឹងឆ្នាំមុន ពី ៧% នៃមូលនិធិកម្ចីសរុប ដល់ ៨% ក្នុងឆ្នាំ២០២២ (ក្រាហ្វ ២.៣៨)។




**២.៣៨ មូលនិធិប្រាក់កម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ** (ឆ្នាំ២០១៧-២០២២)

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

មូលនិធិចម្បងរបស់ MFI មានប្រភពមកពីអង្គការក្រៅរដ្ឋាភិបាលទាំងនៅក្នុងស្រុកនិងបរទេស ម្ចាស់ជំនួយ ធនាគារអភិវឌ្ឍន៍ពហុភាគី និងឧបត្ថម្ភធនរបស់រាជ-

រដ្ឋាភិបាល។ ការពឹងផ្អែកលើប្រភពមូលនិធិបែបប្រពៃណីនេះ បានបង្កើតជាបញ្ហាប្រឈមដល់ការលូតលាស់នៃវិស័យនេះ ដែលជំរុញឱ្យ MFI ងាកទៅរកប្រភពមូលនិធិផ្សេងទៀត ដូចជាដើមទុន និងមូលនិធិកម្ចីសម្រាប់ការអភិវឌ្ឍ។ គិតត្រឹមឆ្នាំ២០២២ មូលនិធិកម្ចីរបស់ MFI មានសមាមាត្រ ៦៥,៦% នៃប្រភពមូលនិធិសរុប បន្ទាប់មកដើមទុនដែលមានសមាមាត្រ ៣៤,៤% (ក្រាហ្វ ២.៣៩)។

មូលនិធិកម្ចីរយៈពេលវែងបានកើនដល់ ៤,១ ទ្រីលានរៀល (៩៩៨ លានដុល្លារអាមេរិក) ជាមួយនឹងអត្រាកំណើន ៣៦,៨% ធៀបនឹង ២៤,២% ក្នុងឆ្នាំមុន។ ទោះយ៉ាងណា សមាមាត្រមូលនិធិកម្ចីរយៈពេលខ្លីបានធ្លាក់ចុះបន្តិចពី ៣០,៦% មក ២៨,៩% ក្នុងឆ្នាំ២០២២ ខណៈមូលនិធិកម្ចីរយៈពេលវែងមានសមាមាត្រ ៧០% នៃមូលនិធិកម្ចីសរុបរបស់ MFI ដែលកើនឡើងពី ៦៧% ក្នុងឆ្នាំមុន ដែលបង្ហាញថាគ្រឹះស្ថានកំពុងស្វែងរកមូលនិធិដែលមានស្ថិរភាពបន្ថែមទៀត (ក្រាហ្វ ២.៤០)។

## ឃ. លទ្ធភាពស្វែងរកប្រាក់ចំណេញ

**វិស័យមីក្រូហិរញ្ញវត្ថុបានបង្ហាញអំពីការកើនឡើងយ៉ាងខ្លាំងនៃប្រាក់ចំណេញសុទ្ធ។** MDI សម្រេចបានប្រាក់ចំណេញសុទ្ធចំនួន ១,២ ទ្រីលានរៀល (២៩៨ លានដុល្លារអាមេរិក) ក្នុងឆ្នាំ២០២២ កើនឡើង ២៥,៥% ធៀបនឹងឆ្នាំមុន។ កំណើននេះសម្រេចបានដោយសារកម្រិតខ្ពស់ជាងមុននៃចំណូលពីការប្រាក់សុទ្ធ និងកម្រិតទាបជាងមុននៃចំណាយលើសំវិធានធន ដោយ MDI បានរៀបចំសំវិធានធនទុករួចរាល់កាលពីឆ្នាំមុន គួបផ្សំនឹង ការគ្រប់គ្រងចំណាយប្រតិបត្តិការបានល្អប្រសើរជាងមុន (ក្រាហ្វ ២.៤១)។

ទោះបីជាសំវិធានធន និងចំណាយប្រតិបត្តិការមានកម្រិតខ្ពស់ជាងមុន MFI បន្តទទួលបានប្រាក់ចំណេញសុទ្ធខ្ពស់ ចំនួន ១០៧ ប៊ីលានរៀល (២៦ លានដុល្លារអាមេរិក) ជាមួយនឹងកំណើន ៧៣% ធៀបនឹងឆ្នាំ២០២១ ដោយសារកម្រិតខ្ពស់ជាងមុននៃចំណូលពីការប្រាក់សុទ្ធ (ក្រាហ្វ ២.៤២)។ ទោះបីជាការងើបឡើង

**២.៣៩ រចនាសម្ព័ន្ធមូលនិធិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៤០ មូលនិធិប្រាក់កម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៤១ រចនាសម្ព័ន្ធប្រាក់ចំណេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

វិញនៃប្រាក់ចំណូលរបស់វិស័យមីក្រូហិរញ្ញវត្ថុរក្សាបានចីរភាព ប្រាក់ចំណូលរបស់វិស័យនេះអាចប្រឈមនឹងភាពមិនប្រាកដប្រជានៃវិស័យខាងក្រៅនិងក្នុងស្រុកផងដែរ។ ប្រសិនបើភាពមិនប្រាកដប្រជាទាំងនេះនៅតែបន្តនិងនាំឱ្យមានការថមថយគួរឱ្យកត់សម្គាល់នៃតម្រូវការឥណទាននិងគុណភាពឥណទាន ប្រាក់ចំណេញរបស់វិស័យមីក្រូហិរញ្ញវត្ថុអាចនឹងទទួលរងផលប៉ះពាល់។

សូចនាករជាទូទៅដែលត្រូវបានប្រើដើម្បីវាយតម្លៃប្រាក់ចំណេញ គឺអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) និងអនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក (ROE)។ ROA ជាមធ្យមសម្រាប់ MDI និង MFI បានកើនឡើងពី ៣% និង ១,២% នៅក្នុងឆ្នាំ២០២១ ដល់ ៣,៤% និង ១,៦% រៀងគ្នា។ ទន្ទឹមនេះ ROE ជាមធ្យមសម្រាប់ MDI និង MFI បានកើនឡើងដល់ ១៦,២% និង ៤,៨% ក្នុងឆ្នាំ២០២២ ពី ១៦% និង ៣,១% រៀងគ្នានៅឆ្នាំ២០២១ (ក្រាហ្វ ២.៤៣)។

លទ្ធភាពរបស់ MDI និង MFI ក្នុងការប្រើប្រាស់ធនធានមានភាពប្រសើរឡើងប្រកបដោយប្រសិទ្ធភាព ដែលឆ្លុះបញ្ចាំងតាមរយៈកម្រិតទាបនៃអនុបាតប្រសិទ្ធភាពជាមធ្យមពី ៤២,៦% និង ៦៤,៧% នៅឆ្នាំ២០២១ មក ៤០,៧% និង ៦១,៦% រៀងគ្នា នៅឆ្នាំ២០២២ ជាចម្បងដោយសារប្រតិបត្តិការរបស់ MDI និង MFI បានប្រើប្រាស់បច្ចេកវិទ្យាច្រើនជាងមុន ប្រកបដោយបរិយាបន្ននិងមានភាពរលូន (ក្រាហ្វ ២.៤៤)។

## ង. ស្ថានភាពដើមទុន

**ស្ថានភាពដើមទុនរបស់វិស័យមីក្រូហិរញ្ញវត្ថុបន្តមានភាពរឹងមាំ ទោះបីជាស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់។** ដើមទុនបទប្បញ្ញត្តិរបស់ MDI បានកើនឡើង ២៤,៨% ធៀបនឹងឆ្នាំមុន ដល់ ៦,៣ ទ្រីលានរៀល (១,៥ ប៊ីលានដុល្លារអាមេរិក) ខណៈទ្រព្យសកម្មថ្លឹងដោយទម្ងន់ហានិភ័យកើនឡើង ២៤,៨%។ ការប្រែប្រួលទាំងនេះបាននាំឱ្យអនុបាតសាធនភាពកើនឡើងបន្តិចពី ១៨,១% នៅឆ្នាំ២០២១ ដល់ ១៨,៦% នៅឆ្នាំ២០២២

**២.៤២ រចនាសម្ព័ន្ធប្រាក់ចំណេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៤៣ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និងមូលនិធិភាគទុនិក**
(គិតជាភាគរយ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៤៤ អនុបាតប្រសិទ្ធភាពប្រតិបត្តិការ**
(គិតជាភាគរយ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ដែលមានកម្រិតខ្ពស់ជាងមុនពេលវិបត្តិកូវីដ-១៩ (ក្រាហ្វ ២.៤៥)។

សម្រាប់ MFI ដើមទុនបទប្បញ្ញត្តិបានធ្លាក់ចុះ -០,៣% មក ២ ទ្រីលានរៀល (៤៨៦ លានដុល្លារអាមេរិក) ខណៈដែលទ្រព្យសកម្មថ្លឹងដោយទម្ងន់ហានិភ័យបានកើនឡើង ២៨,១%។ ជាលទ្ធផល អនុបាតសាធនភាពបានថយចុះពី ៤០,៧% មក ៣១,៦% (ក្រាហ្វ ២.៤៦) ប៉ុន្តែបន្តស្ថិតនៅលើកម្រិតដែលកំណត់ដោយបទប្បញ្ញត្តិ។ ភាពរឹងមាំនៃទ្រនាប់ដើមទុន ដែលបន្ថែមដោយសំវិធានធនគ្រប់គ្រាន់ នឹងធានាថាវិស័យនេះអាចទប់ទល់នឹងវិបត្តិដែលអាចកើតឡើងដោយមិនបានគ្រោងទុក។

## ២.៤ គ្រឹះស្ថានធនាគារឯកទេស

ស្របពេលស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានភាពប្រសើរឡើង **គ្រឹះស្ថានធនាគារឯកទេសបានបង្ហាញអំពីដំណើរការជាវិជ្ជមាន។** គិតត្រឹមចុងឆ្នាំ២០២២ ធនាគារឯកទេសមានសមាមាត្រ ០,៨៥% នៃទ្រព្យសកម្មសរុបនៅក្នុងប្រព័ន្ធធនាគារ។ ធនាគារឯកទេសមានចំនួន ៩ គ្រឹះស្ថាន ដែលកំពុងដំណើរការជាមួយនឹងទ្រព្យសកម្មសរុប ២,៧ ទ្រីលានរៀល (៦៦១,៧ លានដុល្លារអាមេរិក) កើនឡើង ៣,៣% ធៀបនឹង ២,៦ ទ្រីលានរៀលនៅឆ្នាំ២០២១ (ក្រាហ្វ ២.៤៧)។

**ការផ្តល់ឥណទានរបស់ធនាគារឯកទេសបន្តកើនឡើង ដើម្បីបំពេញតម្រូវការឥណទានថ្មី ដោយសារភាពប្រសើរឡើងនៃទស្សនវិស័យសេដ្ឋកិច្ចក្រោយពេលវិបត្តិកូវីដ-១៩។** សមាមាត្រឥណទានទៅកាន់តម្រូវការផ្ទាល់ខ្លួន (មិនរាប់បញ្ចូលឥណទានទិញផ្ទះ) បានកើនដល់ ៨៤% នៃឥណទានសរុប បន្ទាប់មកការជួញដូររាយ (៤%) ការជួញដូរដុំ (២%) សណ្ឋាគារនិងភោជនីយដ្ឋាន (២%) សំណង់ (២%) អចលនទ្រព្យ (២%) និងផ្សេងៗ (២%) (ក្រាហ្វ ២.៤៨)។

ឥណទានសរុបបានកើនឡើង ១៣% ដល់ ២,២ ទ្រីលានរៀល (៥៣២,៨ លានដុល្លារអាមេរិក) ពីកំណើនអវិជ្ជមាន -២៤,៨% ក្នុងឆ្នាំ២០២១ ប៉ុន្តែនៅតែមានកំណើន

**២.៤៥ ស្ថានភាពដើមទុនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៤៦ ស្ថានភាពដើមទុនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២.៤៧ ទ្រព្យសកម្មសរុប**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ទាបជាងមុនពេលមានវិបត្តិកូវីដ-១៩។ កំណើនឥណទានភាគច្រើនត្រូវបានរួមចំណែកដោយឥណទានបុគ្គល (កំណើន ១៥,៨%) កម្មន្តសាល (០,៨%) កសិកម្ម (០,៦%) ខណៈដែលឥណទានទៅកាន់វិស័យមួយចំនួនទៀតមានការធ្លាក់ចុះ (ក្រាហ្វ ២.៤៩)។

**ទោះបីជាមានការកើនឡើងនៃការផ្តល់ឥណទាន គុណភាពនៃសំពៀតឥណទានបន្តមានកម្រិតអាចគ្រប់គ្រងបាន។** អនុបាតឥណទានមិនដំណើរការបានថយចុះមកត្រឹម ៨,៥% នៅចុងឆ្នាំ២០២២ ដែលមានភាពប្រសើរជាង ៩,១% នៅចុងឆ្នាំ២០២១។

**ស្ថានភាពដើមទុនរបស់ធនាគារឯកទេសបន្តមានភាពរឹងមាំ ដែលអាចជួយធនាគារទប់ទល់នឹងវិបត្តិដែលអាចកើតឡើងដោយមិនបានគ្រោងទុក។** នៅចុងឆ្នាំ២០២២ អនុបាតសាធនភាពជាមធ្យមរបស់ធនាគារឯកទេសមានកម្រិត ៣១,៨% ដែលមានកម្រិតទាបជាងឆ្នាំមុនបន្តិច ដោយសារការកើនឡើងនៃទ្រព្យសកម្មថ្លឹងដោយទម្ងន់ហានិភ័យ ប៉ុន្តែអនុបាតនេះបន្តស្ថិតនៅកម្រិតខ្ពស់ជាងកម្រិតបទប្បញ្ញត្តិអប្បបរមា ១៥% (ក្រាហ្វ ២.៥០)។

២.៤៨ **ចំណែកឥណទានតាមវិស័យ**
(ឆ្នាំ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

២.៤៩ **ការរួមចំណែកកំណើនឥណទានតាមវិស័យ**
(គិតជាភាគរយ, ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.៥ សន្និដ្ឋាន

ការវិភាគផ្អែកលើទិន្នន័យគិតត្រឹមខែធ្នូ ឆ្នាំ២០២២ បង្ហាញថា ប្រព័ន្ធធនាគារបន្តមានភាពរឹងមាំនិងស្ថិរភាព ដោយបានផ្តល់ហិរញ្ញប្បទានចាំបាច់ដើម្បីគាំទ្រដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចពីវិបត្តិជំងឺកូវីដ-១៩។ ខណៈកំណើនឥណទាននៅតែបន្តមានភាពរឹងមាំ កំណើនឥណទានក្នុងឆ្នាំ២០២២ បានថមថយបើធៀបទៅនឹងគ្រាដូចគ្នាឆ្នាំមុន ដោយឥណទានបុគ្គលតាមរយៈធនាគារពាណិជ្ជមានការថមថយ។ ទន្ទឹមនេះ សំវិធានធនខ្ពស់និងការកើនឡើងចំណាយការប្រាក់ បាននាំឱ្យមានការធ្លាក់ចុះនៃប្រាក់ចំណេញរបស់ធនាគារ។ ទោះយ៉ាងណា អនុបាតសាធនភាពបន្តមានកម្រិតខ្ពស់ ហើយទ្រព្យសកម្មមានគុណភាពល្អ ទោះបីជាឥណទានមិនដំណើរការបានកើនឡើង ដែលការណ៍នេះត្រូវបានរំពឹងទុកបន្ទាប់ពី

២.៥០ **អនុបាតសាធនភាព និងអនុបាតឥណទានមិនដំណើរការ**
(ឆ្នាំ២០១៧-២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការបញ្ចប់វិធានការអនុគ្រោះបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។ លើសពីនេះ ការធ្វើស្រ្តេសតេស្តបានបង្ហាញថាគ្រឹះស្ថានធនាគារនៅតែមានលទ្ធភាពគ្រប់គ្រាន់ដើម្បីទប់ទល់នឹងការថយចុះនៃគុណភាពទ្រព្យសកម្មក្រោមសេណារីយ៉ូស្រ្តេសផ្សេងៗ។ ខណៈដែលអនុបាត NPLR របស់ MFI និងធនាគារឯកទេសមានកម្រិតខ្ពស់ជាងធនាគារពាណិជ្ជ អនុបាតសាធនភាពរបស់គ្រឹះស្ថានទាំងនេះ ជារួម បន្តបង្ហាញពីភាពគ្រប់គ្រាន់នៃដើមទុន។

ខណៈដែលធនាគារជាតិនៃកម្ពុជាបន្តគ្រប់គ្រងប្រព័ន្ធធនាគារប្រកបដោយប្រសិទ្ធភាព ហានិភ័យអាចនឹងកើតមានឡើងពីគ្រឹះស្ថានដែលផ្តល់សេវាស្រដៀងគ្នាទៅនឹងធនាគារ ដូចជា អ្នកអភិវឌ្ឍន៍អចលនទ្រព្យ ឬហាងបញ្ចាំជាដើម។ បើធៀបទៅនឹងប្រព័ន្ធធនាគារដែលត្រូវបានត្រួតពិនិត្យយ៉ាងជិតដល់ដោយធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានដែលមានផ្តល់សេវាស្រដៀងគ្នាទៅនឹងធនាគារទាំងនេះ មិនស្ថិតក្រោមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជានោះទេ។ ជាលទ្ធផល មានព័ត៌មានតិចតួចអំពីប្រតិបត្តិការ ឬស្ថានភាពហិរញ្ញវត្ថុរបស់អ្នកអភិវឌ្ឍន៍អចលនទ្រព្យ និងហាងបញ្ចាំ ឬលទ្ធភាពសងបំណុលរបស់អតិថិជនគ្រឹះស្ថានទាំងនោះ។ ដូចនេះ ការខិតខំប្រឹងប្រែងរួមគ្នាដោយអាជ្ញាធរនិយតកម្មពាក់ព័ន្ធគឺសំខាន់ណាស់ដើម្បីពង្រឹងការប្រមូលទិន្នន័យ និងធ្វើឱ្យប្រសើរឡើងនូវការត្រួតពិនិត្យបទប្បញ្ញត្តិរបស់ពួកគេ សំដៅគ្រប់គ្រងហានិភ័យមិនឱ្យជះឥទ្ធិពលដល់ប្រព័ន្ធហិរញ្ញវត្ថុ។

# III វិស័យហិរញ្ញវត្ថុមិនមែនធនាគារ

*ទីផ្សារមូលបត្របានបន្តអភិវឌ្ឍជាមួយនឹងការចុះបញ្ជីក្រុមហ៊ុនថ្មីៗបន្ថែមទៀត ទាំងនៅក្នុងទីផ្សារមូលបត្រកម្មសិទ្ធិ និងទីផ្សារមូលបត្របំណុល។ បន្ទាប់ពីបានធ្លាក់ចុះនៅឆ្នាំ២០២១ សន្ទស្សន៍ផ្សារមូលបត្រកម្ពុជា (ផ.ម.ក) និងមូលធនូបនីយកម្មទីផ្សារ បានកើនឡើងបន្តិចនៅឆ្នាំ២០២២ ជាមួយនឹងការកើនឡើងគួរឱ្យកត់សម្គាល់នៃតម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃដល់ជាង ២,១ ប៊ីលានរៀល (០,៥ លានដុល្លារអាមេរិក)។ ទន្ទឹមនេះ ទីផ្សារមូលបត្របំណុលបានរួមចំណែកក្នុងការផ្តល់នូវប្រភពហិរញ្ញប្បទានបន្ថែមទៀត ទាំងសម្រាប់វិស័យសាធារណៈនិងឯកជន។ នៅចុងឆ្នាំ២០២២ សញ្ញាបណ្ណសាជីវកម្មសរុបមានចំនួន ៥១៥ ប៊ីលានរៀល (១២៥,១ លានដុល្លារអាមេរិក) ក្នុងនោះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានសមាមាត្រ ៨០,៩%។ វិស័យធានារ៉ាប់រងបន្តមានកំណើនរឹងមាំ ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃបុព្វលាភសរុបសម្រាប់អនុវិស័យទាំងអស់ រួមមាន ធានារ៉ាប់រងទូទៅ ធានារ៉ាប់រងអាយុជីវិត និងធានារ៉ាប់រងខ្នាតតូច ដែលបានកើនឡើងដល់ ១,៤ ទ្រីលានរៀល (៣៣១,៩ លានដុល្លារអាមេរិក) នៅឆ្នាំ២០២២។*

## ៣.១ ទីផ្សារទ្រព្យសកម្ម

### ក. ទីផ្សារមូលបត្រកម្មសិទ្ធិ

**សន្ទស្សន៍ផ្សារមូលបត្រកម្ពុជា និងមូលធនូបនីយកម្មទីផ្សារបានកើនឡើងបន្តិចធៀបនឹងឆ្នាំមុន។** នៅចុងឆ្នាំ២០២២ សន្ទស្សន៍ផ្សារមូលបត្រកម្ពុជា មានកម្រិត ៤៨៣,៧ សន្ទស្សន៍ កើនឡើង ២,២% ពី ៤៧៣,៤ សន្ទស្សន៍ កាលពីឆ្នាំមុន (ក្រាហ្វ ៣.១)។ ការកើនឡើងនេះត្រូវបានរួមចំណែកដោយការកើនឡើងនៃតម្លៃមូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា (ABC) រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) និងក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSS) ដែលទទួលបានផលចំណេញជាមធ្យមប្រចាំឆ្នាំចំនួន ២,៩% ៥,៦% និង ១៥,៥% រៀងគ្នា។ គួររំលេចថា បន្ទាប់ពីមានការជូនដំណឹងរបស់បរធនបាលកិច្ចហិរញ្ញវត្ថុអេស៊ីលីដា (AFT) ស្តីពីផែនការវិនិយោគរបស់ខ្លួនទៅលើមូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២២ សន្ទស្សន៍ផ្សារមូលបត្រកម្ពុជាបានកើនឡើងគួរឱ្យកត់សម្គាល់ដល់ ៦១០,៦ សន្ទស្សន៍ មុនពេលបង្ហាញពីនិន្នាការថយចុះរហូតដល់ត្រីមាសទី៣។

ក្រាហ្វ ៣.១ **ទីផ្សារមូលបត្រកម្ពុជា**
(ខែធ្នូ ឆ្នាំ២០២១-ខែធ្នូ ឆ្នាំ២០២២)




ប្រភព៖ ផ្សារមូលបត្រកម្ពុជា

**បន្ទាប់ពីបានធ្លាក់ចុះយ៉ាងគំហុកនៅឆ្នាំ២០២១ មូលធនូបនីយកម្មទីផ្សារនៃផ្សារមូលបត្រកម្ពុជា បានកើនឡើងបន្តិចនៅឆ្នាំ២០២២ ស្របតាមនិន្នាការរបស់តម្លៃមូលបត្រធនាគារអេស៊ីលីដា។** មូលធនូបនីយកម្មទីផ្សារ ទាំងទីផ្សារគោល និងទីផ្សារកំណើន បានកើនឡើង ៤% ពី ៧,២ ទ្រីលានរៀល នៅឆ្នាំ២០២១ ដល់ ៧,៥ ទ្រីលានរៀល (១,៨ ប៊ីលានដុល្លារអាមេរិក)។ មូលធនូបនីយកម្មទីផ្សាររបស់ធនាគារអេស៊ីលីដារួមចំណែក ៤,៧ ទ្រីលានរៀល (៦២,៧% នៃមូលធនូបនីយកម្មទីផ្សារសរុប) បន្ទាប់មកគឺកំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS) (១៥,៣%) និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (៨,៨%) (ក្រាហ្វ ៣.២)។

**៣.២** **ទំហំមូលធនូបនីយកម្មទីផ្សារ**
(ឆ្នាំ២០១៧ - ២០២២)




ប្រភព៖ ផ្សារមូលបត្រកម្ពុជា

ទីផ្សារកំណើនបានបន្តទាក់ទាញសហគ្រាសធុនតូចនិងមធ្យម ដើម្បីទទួលបានប្រភពមូលនិធិបន្ថែម ជាមួយនឹងការចុះបញ្ជីក្រុមហ៊ុន ជេអេស លែន ភីអ៊ិលស៊ី (JSL)។ ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យនេះត្រូវបានចុះបញ្ជីនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ និងបានបោះផ្សាយមូលបត្រកម្មសិទ្ធិប្រមាណ ២៥,៧ លានភាគហ៊ុន ដែលមានតម្លៃ IPO ចំនួន ២.៤២០រៀលក្នុងមួយភាគហ៊ុន។ សហគ្រាសធុនតូចនិងមធ្យមជាច្រើនទៀតត្រូវបានរំពឹងថានឹងចុះបញ្ជីក្នុងទីផ្សារកំណើន ដោយផ្តល់ជម្រើសកាន់តែច្រើនសម្រាប់វិនិយោគិនដែលមានកម្រិតទទួលយកហានិភ័យផ្សេងៗគ្នា។

ទីផ្សារមូលបត្រកម្មសិទ្ធិបន្តមានភាពសកម្ម ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងគួរឱ្យកត់សម្គាល់នៃតម្លៃជួញដូរប្រចាំថ្ងៃ។ តម្លៃនៃការជួញដូរជាមធ្យមប្រចាំថ្ងៃបន្តមានកំណើនរឹងមាំក្នុងអត្រា ១០១,១% ពី ១,១ ប៊ីលានរៀល ដល់ជាង ២,១ ប៊ីលានរៀល (០,៥ លានដុល្លារអាមេរិក) ហើយបរិមាណជួញដូរជាមធ្យមប្រចាំថ្ងៃ នៅតែមានកម្រិតខ្ពស់ ២០៧.០៧១ ភាគហ៊ុនក្នុងមួយថ្ងៃ ទោះបីជាបានថយចុះ -៩,១% ក៏ដោយ (ក្រាហ្វ ៣.៣)។ ទន្ទឹមនេះ ចំនួនគណនីជួញដូរបានកើនឡើងជាបន្តបន្ទាប់ ដែលឆ្លុះបញ្ចាំងពីកំណើននៃការចាប់អារម្មណ៍របស់វិនិយោគិន។ នៅចុងឆ្នាំ២០២២ ចំនួនគណនីជួញដូរបានកើនឡើង

**៣.៣** **ទំហំនិងតម្លៃជួញដូរជាមធ្យម**
(ឆ្នាំ២០១៧ - ២០២២)




ប្រភព៖ ផ្សារមូលបត្រកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

១៧,១% ដល់ ៣៦.១៥៥ គណនី ក្នុងនោះ វិនិយោគិនកម្ពុជាមានសមាមាត្រ ៨៧% (ក្រាហ្វ ៣.៤)។ ចំនួនវិនិយោគិន ទាំងជនជាតិខ្មែរនិងបរទេស ត្រូវបានរំពឹងថានឹងមានការកើនឡើង ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងសក្តានុពលសម្រាប់កំណើនសេដ្ឋកិច្ច។

ផ្សារមូលបត្រកម្ពុជាបានជំរុញឌីជីថលូបនីយកម្មគួរឱ្យកត់សម្គាត់ តាមរយៈការដាក់ឱ្យប្រើប្រាស់កម្មវិធីទូរស័ព្ទចល័ត CSX Trade ការធ្វើបច្ចុប្បន្នកម្មលើកម្មវិធីផ្សារហ៊ុន ដែលជាមគ្គុទ្ទេសក៍សម្រាប់ការវិនិយោគ និងការអនុញ្ញាតឱ្យមានការបើកគណនីតាមអនឡាញ។ ការផ្លាស់ប្តូរទាំងនេះបានផ្តល់នូវបរិយាកាសជួញដូរដ៏អំណោយផល និងបានគាំទ្រដល់ទំនុកចិត្តរបស់សាធារណជន ក្នុងការជួញដូរនៅលើផ្សារមូលបត្រកម្ពុជា។ នាពេលខាងមុខ ក្រុមហ៊ុនជាច្រើនត្រូវបានរំពឹងថានឹងចុះបញ្ជីនៅក្នុងផ្សារមូលបត្រកម្ពុជា ដែលនឹងផ្តល់ឱ្យវិនិយោគិនក្នុងស្រុកនិងបរទេសនូវជម្រើសកាន់តែច្រើន និងយុទ្ធសាស្ត្រក្នុងការធ្វើពិពិធកម្ម។ ជាលទ្ធផល ការជួញដូរប្រចាំថ្ងៃត្រូវបានរំពឹងថានឹងនៅបន្តមានភាពសកម្ម។

## ខ. ទីផ្សារមូលបត្របំណុល

### - មូលបត្ររដ្ឋ

នៅឆ្នាំ២០២២នេះ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមបោះផ្សាយមូលបត្ររដ្ឋសរុប ៧២,១ ប៊ីលានរៀល (១៧,៦ លានដុល្លារអាមេរិក) ជាមួយនឹងឥណប្រតិទានរយៈពេល ១ឆ្នាំ និងមានអត្រាគូប៉ុង ២,២% ដែលត្រូវធ្វើការទូទាត់រៀងរាល់ ៦ខែម្តង។ ការបោះផ្សាយមូលបត្ររដ្ឋនេះ ជាជំហានដ៏សំខាន់មួយក្នុងការរួមចំណែកដល់ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុរបស់កម្ពុជា និងការកៀរគរប្រភពហិរញ្ញប្បទានជារូបិយវត្ថុជាតិ។ ឧបករណ៍នេះក៏បានជួយសម្រួលដល់ប្រតិបត្តិការនយោបាយរូបិយវត្ថុផ្អែកលើយន្តការទីផ្សារ និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលផងដែរ។

៣.៤ ចំនួនគណនីជួញដូរ
(ឆ្នាំ២០១៧ - ២០២២)




ប្រភព៖ ផ្សារមូលបត្រកម្ពុជា

## - សញ្ញាបណ្ណសាជីវកម្ម

ទីផ្សារមូលបត្របំណុលសាជីវកម្មបានបន្តទាក់ទាញក្រុមហ៊ុនថ្មីៗ ក្នុងការស្វែងរកប្រភពហិរញ្ញប្បទានជារូបិយវត្ថុក្នុងស្រុក។ នៅចុងឆ្នាំ២០២២ សញ្ញាបណ្ណសាជីវកម្មសរុបមាន ៥១៥ ប៊ីលានរៀល (១២៥,១ លានដុល្លារអាមេរិក) ក្នុងនោះ សញ្ញាបណ្ណរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានចំណែក ៤០,៩% បន្ទាប់មកគឺក្រុមហ៊ុនដឹកជញ្ជូន (២៧,២%) ក្រុមហ៊ុននាំចេញ-នាំចូល (១៦,២%) និងក្រុមហ៊ុនទូរគមនាគមន៍ (១៥,៨%) (ក្រាហ្វ ៣.៥)។ ការបោះផ្សាយសញ្ញាបណ្ណសាជីវកម្មនេះឆ្លុះបញ្ចាំងពីតួនាទីរបស់ទីផ្សារមូលបត្របំណុលក្នុងការផ្តល់ហិរញ្ញប្បទានរយៈពេលវែងបន្ថែមទៀតទៅកាន់សាជីវកម្មក្នុងវិស័យផ្សេងៗ។

ក្រុមហ៊ុនរ៉ូយ៉ាល់ រេលវេ បានបោះផ្សាយមូលបត្របំណុល២ប្រភេទ ដែលគិតជាទឹកប្រាក់សរុប១៤០ប៊ីលានរៀល (៣៤ លានដុល្លារអាមេរិក)។ មូលបត្របំណុលទី១ គឺជាសញ្ញាបណ្ណធម្មតា ដែលមានចំនួន ៤១,៦ ប៊ីលានរៀល (១០ លានដុល្លារអាមេរិក) ជាមួយនឹងអត្រាគូប៉ុង ៧% ក្នុងមួយឆ្នាំ និងមានឥណប្រតិទាន ១០ឆ្នាំ។ ចំណែកឯមូលបត្របំណុលទី២ គឺជាសញ្ញាបណ្ណមានបុគ្គលធានាសម្រាប់វិនិយោគិនមានគុណវឌ្ឍិគ្រប់គ្រាន់ ដែលមានចំនួន ៩៨,៤ ប៊ីលានរៀល (២៤ លានដុល្លារអាមេរិក) ហើយមូលបត្របំណុលនេះបានចែកចេញជា ២ មាន៖ សញ្ញាបណ្ណដែលមានឥណប្រតិទាន ៥ឆ្នាំ មានអត្រាគូប៉ុង SOFR+៣,៥% ឬ ៥% ក្នុងមួយឆ្នាំ (យកអត្រាណាដែលខ្ពស់ជាង) និងសញ្ញាបណ្ណដែលមានឥណប្រតិទាន ១០ឆ្នាំ ដោយចាប់ពីឆ្នាំទី១ ដល់ ឆ្នាំទី៥ មានអត្រាគូប៉ុង SOFR+៣,៥% ឬ ៥% ក្នុងមួយឆ្នាំ (យកអត្រាណាដែលខ្ពស់ជាង) និងចាប់ពីឆ្នាំទី៦ ទៅឆ្នាំទី១០ មានអត្រាគូប៉ុង SOFR+៣,៧៥% ឬ ៥% ក្នុងមួយឆ្នាំ (យកអត្រាណាដែលខ្ពស់ជាង)។ ទន្ទឹមនេះ មូលបត្របំណុលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ LOLC និងធនាគារ ABA បានដល់ឥណប្រតិទានក្នុងឆ្នាំ២០២២នេះ។ គិតត្រឹមចុងឆ្នាំ២០២២

**៣.៥ មូលធនូបនីយកម្មទីផ្សារមូលបត្របំណុលសាជីវកម្ម**
(ឆ្នាំ២០២២)




ប្រភព៖ ផ្សារមូលបត្រកម្ពុជា

គ្រឹះស្ថានហិរញ្ញវត្ថុចំនួន ៣ ក្រុមហ៊ុននាំចេញ-នាំចូលចំនួន ១ ក្រុមហ៊ុនទូរគមនាគមន៍ចំនួន ១ និងក្រុមហ៊ុនដឹកជញ្ជូនចំនួន ១ បានចុះបញ្ជីក្នុងផ្សារមូលបត្របំណុល។ បើទោះបីជាការបោះផ្សាយសញ្ញាបណ្ណមានការកើនឡើងក៏ដោយ ក៏សកម្មភាពជួញដូរក្នុងផ្សារមូលបត្របំណុលនៅតែមានភាពអសកម្ម ដោយវិនិយោគិនបានរក្សាសញ្ញាបណ្ណរបស់ខ្លួនរហូតដល់ឥណប្រតិទាន។

ក្នុងចំណោមមូលបត្របំណុលដែលមានឥណ-ប្រតិទាន ៣ឆ្នាំ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ផ្តល់អត្រាគូប៉ុងខ្ពស់ជាងគេដល់ ៧,៥% ហើយមូលបត្របំណុលមានឥណប្រតិទាន ៥ឆ្នាំ មានអត្រាគូប៉ុងចន្លោះពី ៤,៥% ដល់ SOFR+៣,៥% (តារាង ៣.១)។ ទន្ទឹមនេះ ក្រុមហ៊ុន រ៉ូយ៉ាល់ រេលវេ ក៏បានបោះផ្សាយមូលបត្របំណុលមានឥណប្រតិទាន ១០ឆ្នាំ ដែលជាសញ្ញាបណ្ណសាជីវកម្មមានឥណប្រតិទានវែងជាងគេ ដោយបែងចែកជាសញ្ញាបណ្ណធម្មតានិងសញ្ញាបណ្ណមានបុគ្គលធានា។

## ៣.២ វិស័យធានារ៉ាប់រង

វិស័យធានារ៉ាប់រងបន្តមានវឌ្ឍនភាពល្អប្រសើរសម្រាប់អនុវិស័យធានារ៉ាប់រងគ្រប់ប្រភេទ។ បុព្វលាភធានារ៉ាប់រងសរុបបានកើនឡើង ១០,៧% ដល់ ១,៤ ទ្រីលានរៀល (៣៣១,៩ លានដុល្លារអាមេរិក) នៅឆ្នាំ ២០២២ (ក្រាហ្វ ៣.៦)។ បុព្វលាភធានារ៉ាប់រងអាយុជីវិតមានចំណែកធំជាងគេ ៥៨,៤% បន្ទាប់មកគឺធានារ៉ាប់រងទូទៅ (៣៩,៩%) និងធានារ៉ាប់រងខ្នាតតូច (១,៧%)។ ទន្ទឹមនេះ ទ្រព្យសកម្មសរុបនៃវិស័យធានារ៉ាប់រងបានកើនឡើង ១៤,៩% ដល់ប្រមាណ ៤ ទ្រីលានរៀល (៩៧៧ លានដុល្លារអាមេរិក) (ក្រាហ្វ ៣.៧)។ ភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ច (insurance penetration) ដែលវាស់វែងដោយបុព្វលាភសរុបធៀបនឹងផ.ស.ស បានកើនឡើងដល់ ១,១៧% នៅឆ្នាំ២០២២។

បុព្វលាភធានារ៉ាប់រងអាយុជីវិតបានកើនឡើង ១២,៦% ដល់ ៧៩២,២ ប៊ីលានរៀល (១៩៣,៨ លានដុល្លារអាមេរិក) ដែលគាំទ្រជាចម្បងដោយកិច្ចសន្យា

**តារាង ៣.១៖ អត្រាគូប៉ុងមូលបត្របំណុល**

| អ្នកបោះផ្សាយ | ឈ្មោះមូលបត្របំណុល | អត្រាគូប៉ុង | | |
|---|---|---|---|---|
| | | ៣ឆ្នាំ | ៥ឆ្នាំ | ១០ឆ្នាំ |
| ធនាគារភ្នំពេញពាណិជ្ជ (PPCB) | សញ្ញាបណ្ណ PPCB មានការការពារហានិភ័យអត្រាប្តូរប្រាក់ លេខ១ | ៦,៥% | | |
| | សញ្ញាបណ្ណ PPCB មានការការពារហានិភ័យអត្រាប្តូរប្រាក់ លេខ២ | ៦,៥% | | |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ | PRASAC | ៧,៥% | | |
| ក្រុមហ៊ុន អ អិម អេ (កម្ពុជា) | សញ្ញាបណ្ណសាជីវកម្ម អ អិម អេ ខេមបូឌា | | ៥,៥% | |
| ក្រុមហ៊ុន តែល កូថេក | សញ្ញាបណ្ណ តែលកូថេក | | ៤,៥% | |
| ក្រុមហ៊ុន រ៉ូយ៉ាល់ រេលវេ | សញ្ញាបណ្ណមានបុគ្គលធានា រ៉ូយ៉ាល់ រេលវេ១ | | SOFR* + ៣,៥% ឬ ៥% ក្នុងមួយឆ្នាំ** | |
| | សញ្ញាបណ្ណសាជីវកម្ម រ៉ូយ៉ាល់ រេលវេ | | | ៧% |
| | សញ្ញាបណ្ណមានបុគ្គលធានា រ៉ូយ៉ាល់ រេលវេ២ | | | - ឆ្នាំទី១-ទី៥: SOFR+៣,៥% ឬ ៥% ក្នុងមួយឆ្នាំ** - ឆ្នាំទី៦-ទី១០: SOFR+៣,៧៥% ឬ ៥% ក្នុងមួយឆ្នាំ** |

ប្រភព៖ ផ្សារមូលបត្រកម្ពុជា

ចំណាំ៖ *SOFR សំដៅលើអត្រាហិរញ្ញប្បទាន Overnight ដោយមានកាធានា, ** យកអត្រាខ្ពស់ជាង

**៣.៦ បុព្វលាភធានារ៉ាប់រងសរុប**
(ឆ្នាំ២០១៩ - ២០២២)




ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

**៣.៧ ទ្រព្យសកម្មសរុប**
(ឆ្នាំ២០១៩ - ២០២២)




ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

ទាយជ្ជទាន (៩,៩% នៃកំណើនសរុប) និងធានារ៉ាប់រងមានកាលកំណត់ (៤,១%)។ កិច្ចសន្យាទាយជ្ជទានមានចំណែកធំជាងគេនៃបុព្វលាភធានារ៉ាប់រងអាយុជីវិតសរុបស្មើនឹង ៧៩,៩% បន្ទាប់មកគឺធានារ៉ាប់រងអាយុជីវិតមានកាលកំណត់ (១៩,៤%) (ក្រាហ្វ ៣.៨)។ លើសពីនេះ ចំនួនកិច្ចសន្យាធានារ៉ាប់រងអាយុជីវិតថ្មី បានកើនឡើង ១០,៤% ពី ៤៨៥.២៤៩ ដល់ ៥៣៥,៨៧១ កិច្ចសន្យា។ អនុបាតការផ្តល់សំណងបានថយចុះពី ៨,៨% មកត្រឹម ៧,៣% ដោយការផ្តល់សំណងសរុបនៃធានារ៉ាប់រងអាយុជីវិតថយចុះ -៦,៧% មកត្រឹម ៥៨ ប៊ីលានរៀល (១៤,២ លានដុល្លារអាមេរិក)។

បុព្វលាភដុលធានារ៉ាប់រងទូទៅបានកើនឡើង ៧,១% ដល់ ៥៤០,៩ ប៊ីលានរៀល (១៣២,៣ លានដុល្លារអាមេរិក) ដែលគាំទ្រជាចម្បងដោយធានារ៉ាប់រងទ្រព្យសម្បត្តិឬអគ្គិភ័យ (៦,១% នៃកំណើនសរុប) ធានារ៉ាប់រងសុខភាព (៣%) និងធានារ៉ាប់រងយានយន្ត (១,៦%)។ ការធានារ៉ាប់រងទ្រព្យសម្បត្តិឬអគ្គិភ័យមានចំណែកធំជាងគេនៅក្នុងបុព្វលាភធានារ៉ាប់រងទូទៅស្មើនឹង ៣៤,១% បន្ទាប់មកគឺធានារ៉ាប់រងសុខភាព (២៣,៣%) និងធានារ៉ាប់រងយានយន្ត (១៧,៨%) (ក្រាហ្វ ៣.៩)។ អនុបាតការផ្តល់សំណងបានថយល្បឿនមកត្រឹម ២៣,៨% ខណៈការផ្តល់សំណងសរុបនៃធានារ៉ាប់រងទូទៅកើនឡើង ៦% ដល់ ១២៨,៧ ប៊ីលាន (៣១,៥ លានដុល្លារអាមេរិក)។

បុព្វលាភដុលធានារ៉ាប់រងខ្នាតតូចបានកើនឡើងខ្ពស់ ៣៨,៤% ដល់ ២៣,៤ ប៊ីលានរៀល (៥,៧ លានដុល្លារអាមេរិក) ដែលគាំទ្រជាចម្បងដោយធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល។ ផលិតផលធានារ៉ាប់រងខ្នាតតូចរួមមានធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល (៣៥,៣% នៃធានារ៉ាប់រងខ្នាតតូចសរុប) ធានារ៉ាប់រងសុខភាព (១៦,៧%) ធានារ៉ាប់រងមានកាលកំណត់ (៩,៣%) និងធានារ៉ាប់រងផ្សេងៗ (៣៨,៧%) (ក្រាហ្វ ៣.១០)។ អនុបាតការផ្តល់សំណងមានកំណើន ១៦% ហើយការផ្តល់សំណងសរុបនៃធានារ៉ាប់រងខ្នាតតូច

៣.៨ សមាសធាតុបុព្វលាភធានារ៉ាប់រងអាយុជីវិត (ឆ្នាំ២០២២)




ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

៣.៩ សមាសធាតុបុព្វលាភធានារ៉ាប់រងទូទៅ (ឆ្នាំ២០២២)




ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

៣.១០ សមាសធាតុបុព្វលាភធានារ៉ាប់រងខ្នាតតូច (ឆ្នាំ២០២២)




ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

បានកើនឡើង ៣៥,៦% ដល់ ៣,៧ ប៊ីលានរៀល (០,៩ លានដុល្លារអាមេរិក)។

## ៣.៣ សន្និដ្ឋាន

វិស័យហិរញ្ញវត្ថុមិនមែនធនាគារបន្តរីកចម្រើនជាលំដាប់ ដែលអាចជួយបំពេញបន្ថែមនូវការផ្តល់សេវាហិរញ្ញវត្ថុរបស់ប្រព័ន្ធធនាគារ និងរួមចំណែកជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុដែលមានភាពទូលំទូលាយ និងពិពិធកម្ម។ វិនិយោគិន ទាំងជាបុគ្គលនិងជាស្ថាប័ន មានជម្រើសកាន់តែច្រើន សម្រាប់គ្រប់គ្រងហានិភ័យរបស់ពួកគេ ក្នុងពេលដែលក្រុមហ៊ុនអាជីវកម្មក៏អាចស្វែងរកប្រភពហិរញ្ញប្បទានផ្សេងទៀត បន្ថែមលើឥណទានធនាគារ។ ទន្ទឹមនេះ ហានិភ័យក៏អាចកើតឡើងពីសកម្មភាពធនាគារស្រមោល ដូចជា ពីក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ ឬហាងបញ្ចាំ ជាដើម។ ដូច្នេះ កិច្ចខិតខំប្រឹងប្រែងរួមគ្នាគឺត្រូវការជាចាំបាច់ ដើម្បីពង្រឹងការប្រមូលនិងការចែករំលែកទិន្នន័យ ក៏ដូចជាការធ្វើឱ្យប្រសើរឡើងនូវការត្រួតពិនិត្យ សំដៅទប់ស្កាត់ហានិភ័យណាមួយពីធនាគារស្រមោលទៅលើប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។ ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងកិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីធានាបាននូវភាពរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា។

**ប្រអប់ ៣.១**

# ការវិភាគតារាងតុល្យការ

ស្ថានភាពហិរញ្ញវត្ថុនៃគ្រប់វិស័យដុលក្នុងឆ្នាំ ២០២២ (ទាំងផ្នែកទ្រព្យសកម្ម និងទ្រព្យអកម្ម) សរុបមាន ចំនួន ៤៥៥,១ ប៊ីលានដុល្លារអាមេរិក បានកើនឡើង ៧,៤% ធៀបនឹង ៤២៣,៨ ប៊ីលានដុល្លារអាមេរិកក្នុង ឆ្នាំ២០២១ ដោយក្នុងនោះ គ្រឹះស្ថានទទួលប្រាក់បញ្ញើ ផ្សេងទៀត (ODCs) បានរួមចំណែក ១៣៧,១ ប៊ីលាន ដុល្លារអាមេរិក វិស័យខាងក្រៅ ៩៥,១ ប៊ីលានដុល្លារ អាមេរិក គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ (NFCs) ៩៣,៦ ប៊ីលាន ដុល្លារអាមេរិក និងអង្គភាពគ្រួសារ ចំនួន ៦៩,៦ ប៊ីលាន ដុល្លារអាមេរិក។

ចំពោះស្ថានភាពហិរញ្ញវត្ថុសុទ្ធវិញ ODCs បាន បង្ហាញអំពីទ្រព្យសកម្មសុទ្ធ ចំនួន ២,២ ប៊ីលានដុល្លារ អាមេរិក កើនឡើង ៨,៨% (ឆ្នាំលើឆ្នាំ) ពីចំនួន ២ ប៊ីលាន ដុល្លារអាមេរិក ក្នុងឆ្នាំ២០២១។

លំហូរមូលធនពីគ្រប់វិស័យចូលក្នុង ODCs មាន ចំនួន ៦៧,៥ ប៊ីលានដុល្លារអាមេរិក បានកើនឡើង ១១,១% (ឆ្នាំលើឆ្នាំ) ជាចម្បងបណ្តាលមកពីការកើនឡើង នៃលំហូរចូលមូលធនពីអង្គភាពគ្រួសារ (១២,៧%) និង វិស័យខាងក្រៅ (១៨,៥%)។ ដោយឡែក មូលធនដែល ODCs បានផ្តល់ទៅកាន់គ្រប់វិស័យវិញមានចំនួន ៦៩,៦ ប៊ីលានដុល្លារអាមេរិក បានកើន ១១% ពីចំនួន ៦២,៧ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំមុន ដោយសារការកើនឡើង នៃការផ្តល់មូលធនទៅកាន់ NFCs (១៥,២%) និងអង្គភាព គ្រួសារ (២២,៨%) ដែលភាគច្រើនជាប្រាក់កម្ចី។

NFCs បានបង្ហាញទ្រព្យអកម្មសុទ្ធដែលភាគច្រើន ជាឥណទេយ្យត្រូវសងទៅកាន់វិស័យខាងក្រៅ និង ODCs។ ឥណទេយ្យត្រូវសងសុទ្ធ របស់ NFCs មានចំនួន ៦៥,៦ ប៊ីលានដុល្លារអាមេរិក បានកើនឡើង ២១,៣% ដោយសារ ការកើនឡើងនៃលំហូរចូលនៃវិនិយោគពីវិស័យខាងក្រៅ (៨,៦%) និងប្រាក់កម្ចីពី ODCs (១៥,២%)។ លំហូរចូល មូលធនមកកាន់ NFCs មានចំនួន ៧៩,៦ ប៊ីលានដុល្លារ អាមេរិក កើនឡើង ១៣,៣% (ឆ្នាំលើឆ្នាំ) ខណៈដែល

**៣.១១ ស្ថានភាពហិរញ្ញវត្ថុរួមតាមវិស័យដុល**

(គិតជាប៊ីលានដុល្លារអាមេរិក, ឆ្នាំ២០២២)




កំណត់សម្គាល់ ៖
- ទំហំរង្វង់ តំណាងឱ្យទំហំទឹកប្រាក់សរុបនៃទ្រព្យសកម្មនិងទ្រព្យអកម្មរបស់វិស័យនីមួយៗ
- ពណ៌នៃខ្សែដែលចេញពីវិស័យមួយទៅវិស័យផ្សេងទៀត តំណាងឱ្យបំណុលត្រូវទារពីវិស័យទាំងនោះ។

**៣.១២ ស្ថានភាពហិរញ្ញវត្ថុរួមតាមវិស័យសុទ្ធ**

(គិតជាប៊ីលានដុល្លារអាមេរិក, ឆ្នាំ២០២២)




កំណត់សម្គាល់:
- វិស័យសេដ្ឋកិច្ចដែលរំលេចដោយពណ៌ **ក្រហម** សំដៅលើឥណទាយិក (Net Debtor) ខណៈដែលវិស័យសេដ្ឋកិច្ចដែលរំលេចដោយពណ៌ **បៃតង** សំដៅលើឥណទាយក (Net Creditor)
- ទំហំរង្វង់ តំណាងឱ្យទំហំស្ថានភាពសុទ្ធ (Net Position) របស់វិស័យនីមួយៗ
- សញ្ញាព្រួញដែលចេញពីវិស័យមួយ ទៅវិស័យផ្សេងទៀត តំណាងឱ្យបំណុលត្រូវទារពីវិស័យទាំងនោះ។

លំហូរមូលធនចេញទៅកាន់គ្រប់វិស័យមានចំនួន ១៤ ប៊ីលានដុល្លារអាមេរិក បានធ្លាក់ចុះ -១៣,៦%។ វិស័យខាងក្រៅ មានឥណទេយ្យត្រូវទារសុទ្ធ ចំនួន ៣៩,៧ ប៊ីលានដុល្លារអាមេរិក កើនឡើង ៣៥,២%។ លំហូរចូលមូលធនពីវិស័យខាងក្រៅមកគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជា មានចំនួន ៦៧៤, ប៊ីលានដុល្លារអាមេរិក បានកើនឡើង ៩,៦% ខណៈលំហូរចេញទៅវិស័យក្រៅប្រទេសវិញ មានចំនួន ២៧,៧ ប៊ីលានដុល្លារអាមេរិក ថយចុះ -១៣,៧%។ NFCs ជាអ្នកទទួលមូលធនចម្បងពីវិស័យនេះ ដែលមានសមាមាត្រស្មើនឹង ៦៦% នៃលំហូរចេញសរុបពីវិស័យខាងក្រៅ ខណៈដែលលំហូរមូលធនពី NFCs ទៅកាន់វិស័យខាងក្រៅបានរួមចំណែកត្រឹម ២0% ប៉ុណ្ណោះ។

# IV ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់

*ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់បានលើកកម្ពស់ប្រសិទ្ធភាពអន្តរប្រតិបត្តិការ និងបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។ ការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានដាក់ចេញនូវសេវាកម្មទូទាត់ឌីជីថលប្រកបដោយភាពច្នៃប្រឌិត ដើម្បីគាំទ្រដល់កំណើនតម្រូវការនៅក្នុងប្រក្រតីកម្មថ្មី។ ចំនួនគណនីកាបូបអេឡិចត្រូនិកបានកើនឡើងដល់ ១៩,៥ លានគណនី ហើយទំហំនៃការទូទាត់រាយតាមប្រព័ន្ធអេឡិចត្រូនិកបានកើនឡើងដល់ជាង ៩ដងនៃផ.ស.ស.។ ការប្រើប្រាស់សេវាធនាគារចល័តបានកើនឡើងជាលំដាប់ ដែលគាំទ្រដោយកំណើននៃអត្រាប្រើប្រាស់ទូរស័ព្ទចល័តនិងអ៊ីនធឺណិត។ លើសពីនេះ ប្រតិបត្តិការទូទាត់តាមរយៈប្រព័ន្ធបាគង និង QR កូត បានកើនឡើងគួរឱ្យកត់សម្គាល់នៅឆ្នាំ២០២២ ដែលឆ្លុះបញ្ចាំងពីការកើនឡើងនៃការចាប់អារម្មណ៍ និងការប្រើប្រាស់របស់សាធារណជន។*

**ស្របតាមការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និងសេដ្ឋកិច្ចឌីជីថល ធនាគារជាតិនៃកម្ពុជាបានលើកកម្ពស់ការច្នៃប្រឌិតក្នុងសេវាកម្មហិរញ្ញវត្ថុឌីជីថល ដើម្បីកាត់បន្ថយការចំណាយ ជំរុញអន្តរប្រតិបត្តិការ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។** ប្រព័ន្ធទូទាត់និងផាត់ទាត់ត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ក្នុងមួយទសវត្សចុងក្រោយនេះ ទាំងសម្រាប់ការទូទាត់រាយ និងតម្លៃធំ ដើម្បីគាំទ្រដល់សេវាកម្មហិរញ្ញវត្ថុឌីជីថលដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស រួមមាន ប្រព័ន្ធផាត់ទាត់ជាតិ (NCS) ប្រព័ន្ធធនាគារអនឡាញ (OBS) ប្រព័ន្ធសេវាទូទាត់រហ័ស (FAST) ប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS) ប្រព័ន្ធបាគង ប្រព័ន្ធរីថៃលផេ និងស្តង់ដារខេអេចឃ្យូអរ (KHQR) (ក្រាហ្វ ៤.១)។ លើសពីនេះធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់តម្លៃធំបាគង (LVPS) ដើម្បីជួយសម្រួលដល់ប្រតិបត្តិការអន្តរធនាគារ និងទីផ្សារហិរញ្ញវត្ថុ។

**នៅក្នុងបរិការណ៍ប្រក្រតីកម្មថ្មី ការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។** ប្រព័ន្ធទូទាត់អេឡិចត្រូនិកថ្មីៗដែលបានដាក់ឱ្យប្រើប្រាស់ដោយធនាគារជាតិនៃកម្ពុជា បានផ្តល់ជាមធ្យោបាយទូទាត់ដ៏មានប្រសិទ្ធភាព និងងាយស្រួល ប្រកបដោយសុវត្ថិភាព និងរលូនក្នុងអំឡុងពេលរាតត្បាតនៃជំងឺកូវីដ-១៩ ហើយនិន្នាការនេះ

**៤.១ ប្រព័ន្ធទូទាត់សងប្រាក់របស់ធនាគារជាតិនៃកម្ពុជា**

(ឆ្នាំ២០១២ - ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**៤.២ ទំហំទឹកប្រាក់នៃការទូទាត់រាយតាមប្រព័ន្ធអេឡិចត្រូនិក**

(ឆ្នាំ២០១៩ - ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

បានបន្តកើនឡើង ដែលឆ្លុះបញ្ចាំងពីទំនុកចិត្ត និងការប្រើប្រាស់ក្នុងចំណោមសាធារណជន។ នៅឆ្នាំ២០២២ ទំហំនៃការទូទាត់រាយតាមប្រព័ន្ធអេឡិចត្រូនិក[១៩] រួមទាំងប្រាក់រៀល និងដុល្លារអាមេរិក បានកើនឡើង ៣៥% ដល់ ១.១១០,៦ ទ្រីលានរៀល (២៧២ ប៊ីលានដុល្លារអាមេរិក) ដែលស្មើនឹងជាង ៩ដងនៃផ.ស.ស. (ក្រាហ្វ ៤.២)។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាពិសេស គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ក៏បានអភិវឌ្ឍសេវាទូទាត់ឌីជីថលប្រកបដោយភាពច្នៃប្រឌិត ដើម្បីគាំទ្រដល់តម្រូវការដែលកំពុងកើនឡើង។ ចំនួនគណនីកាបូបអេឡិចត្រូនិកបានកើនឡើងជាលំដាប់ដល់ ១៩,៥ លានគណនី ហើយចំនួនអតិថិជនដែលគ្មានគណនី (Walk-in) នៅតាមបណ្តាភ្នាក់ងារផ្តល់សេវាទូទាត់ មានប្រមាណ ១៣៥,៦ លាននាក់ នៅឆ្នាំ២០២២ ដែលបង្ហាញពីលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការកាន់តែច្រើនក្នុងតម្លៃសមរម្យ សម្រាប់អតិថិជនក្នុងធ្វើប្រតិបត្តិការផ្សេងៗ ដូចជាការទូទាត់វិក្កយបត្រ និងការផ្ទេរប្រាក់ (ក្រាហ្វ ៤.៣)។ ទំហំសរុបនៃការទូទាត់ដោយប្រើគណនីកាបូបអេឡិចត្រូនិកបានកើនឡើង ៣១% ដល់ ២៦២,៨ ទ្រីលានរៀល (៦៤,៣ ប៊ីលានដុល្លារអាមេរិក) ហើយចំនួនប្រតិបត្តិការក៏បានកើនឡើងដល់ ៤៦៧,៤ លានប្រតិបត្តិការ (ក្រាហ្វ ៤.៤)។

ការប្រើប្រាស់សេវាធនាគារចល័តបានកើនឡើងជាលំដាប់ ដែលត្រូវបានគាំទ្រដោយកំណើននៃការប្រើប្រាស់ទូរស័ព្ទចល័ត និងអ៊ីនធឺណិត គួបផ្សំនឹងការផ្តល់សេវាហិរញ្ញវត្ថុឌីជីថលដែលមានភាពងាយស្រួល ដែលអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការធនាគារឌីជីថលយ៉ាងទូលំទូលាយ ដូចជា ការទូទាត់សងឥណទាន ការផ្ទេរប្រាក់ ការទូទាត់វិក្កយបត្រ ការបញ្ចូលលុយទូរស័ព្ទ ការបើកប្រាក់បៀវត្សរ៍ ការពិនិត្យសមតុល្យ ជាដើម។ ខណៈដែលទំហំនៃសេវាធនាគារអ៊ីនធឺណិតបានធ្លាក់ចុះ -១១,៥% មកត្រឹម ៨០,៥ ទ្រីលានរៀល

**៤.៣ ចំនួនគណនីកាបូបអេឡិចត្រូនិក និងអតិថិជន Walk-in**
(ឆ្នាំ២០១៩ - ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**៤.៤ ទំហំនិងចំនួនប្រតិបត្តិការតាមកាបូបអេឡិចត្រូនិក**
(ឆ្នាំ២០១៩ - ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[១៩] ការទូទាត់រាយតាមប្រព័ន្ធអេឡិចត្រូនិក រួមមានទាំងប្រតិបត្តិការទូទាត់ជាប្រាក់រៀល និងដុល្លារអាមេរិក តាមរយៈកាបូបអេឡិចត្រូនិករបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ សេវាធនាគារអ៊ីនធឺណិត សេវាធនាគារចល័ត និងការទូទាត់តាមប័ណ្ណទូទាត់។

(១៩,៧ ប៊ីលានដុល្លារអាមេរិក) ទំហំនៃការទូទាត់តាមសេវាធនាគារចល័តបានកើនឡើង ៩៧,៨% ដល់ ៦៧៣,២ ទ្រីលានរៀល (១៦៤,៧ ប៊ីលានដុល្លារអាមេរិក) (ក្រាហ្វ ៤.៥)។ ដូចគ្នានេះដែរ ចំនួនប្រតិបត្តិការនៃសេវាធនាគារអ៊ីនធឺណិតបានធ្លាក់ចុះមកត្រឹម ៣,៣ លានប្រតិបត្តិការ ខណៈដែលចំនួនប្រតិបត្តិការធនាគារចល័តបានកើនឡើងដល់ ៩៨៥,១ លានប្រតិបត្តិការ។

ការប្រើប្រាស់ប័ណ្ណទូទាត់បានកើនឡើងជាលំដាប់ឆ្លុះបញ្ចាំងតាមរយៈនិន្នាការកើនឡើងនៃទំហំប្រតិបត្តិការ និងចំនួនប័ណ្ណទូទាត់ដែលបានចេញផ្សាយ។ នៅឆ្នាំ២០២២ ទំហំសរុបនៃការប្រើប្រាស់ប័ណ្ណទូទាត់ បានកើនឡើង ១៦% ដល់ ៩៨ ទ្រីលានរៀល (២៤ ប៊ីលានដុល្លារអាមេរិក) ជាមួយនឹងប្រតិបត្តិការចំនួន ១១៩,៧ លាន ហើយចំនួនប័ណ្ណទូទាត់ដែលកំពុងចរាចរបានកើនដល់ ១២,៣ លានប័ណ្ណ (ក្រាហ្វ ៤.៦)។

ប្រព័ន្ធបាគង ដែលត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ នៅខែតុលា ឆ្នាំ២០២២ បានបង្កើនប្រសិទ្ធភាពប្រតិបត្តិការប្រព័ន្ធទូទាត់ សម្រួលដល់អន្តរប្រតិបត្តិការរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ ចំនួនគណនីបាគងបានកើនឡើងដល់ ៥២២,៦ ពាន់គណនី នៅឆ្នាំ២០២២។ ជាមួយគ្នានេះ ទំហំសរុបនៃប្រតិបត្តិការទូទាត់តាមរយៈប្រព័ន្ធបាគងបានកើនឡើង ៤,៤ដង ដល់ ៦២,៧ ទ្រីលានរៀល (១៥,៣ ប៊ីលានដុល្លារអាមេរិក) ជាមួយនឹងប្រតិបត្តិការចំនួន ២៦,១ លាន (ក្រាហ្វ ៤.៧)។

ការដាក់ឱ្យប្រើប្រាស់ស្តង់ដារខេអេចឃ្យូអរ (KHQR) ដែលត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការនៅខែកក្កដា ឆ្នាំ២០២២ បានជួយសម្រួលដល់អន្តរប្រតិបត្តិការនៃការទូទាត់តាម ឃ្យូអរកូដ នៅក្នុងប្រទេស ព្រមទាំងបានជំរុញការតភ្ជាប់ការទូទាត់ឆ្លងដែននៅក្នុងតំបន់។ ទំហំនៃការទូទាត់តាម QR កូដ បានកើនឡើង ១៤,៣ដង ដល់ ១៣,៧ ទ្រីលានរៀល (៣,៤ ប៊ីលានដុល្លារអាមេរិក) ហើយចំនួនប្រតិបត្តិការបានកើនឡើងជាង ៥ដង ដល់ ២៣,៣ លានប្រតិបត្តិការ (ក្រាហ្វ ៤.៨)។

**៤.៥ ទំហំទឹកប្រាក់នៃប្រតិបត្តិការសេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័ត**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**៤.៦ ទំហំនិងចំនួនប្រតិបត្តិការនៃការទូទាត់ដោយប្រើប្រាស់ប័ណ្ណទូទាត់**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**៤.៧ ទំហំនិងចំនួនប្រតិបត្តិការនៃការទូទាត់តាមប្រព័ន្ធបាគង**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ដើម្បីរួមចំណែកជំរុញសមាហរណកម្ម និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ឱ្យកាន់តែស៊ីជម្រៅ ការតភ្ជាប់ការទូទាត់ឆ្លងដែនជាមួយសមាជិកអាស៊ានផ្សេងទៀតក៏ត្រូវបានពង្រីកជាលំដាប់ ដើម្បីជួយសម្រួលដល់ការផ្ញើពាណិជ្ជកម្ម ទេសចរណ៍ និងការផ្ទេរប្រាក់ឆ្លងដែន ព្រមទាំងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុក្នុងតំបន់។

សរុបមក ការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃប្រព័ន្ធទូទាត់សងប្រាក់ បានលើកកម្ពស់ការទូទាត់ឱ្យកាន់តែមានប្រសិទ្ធភាព សុវត្ថិភាព និងតម្លៃសមរម្យ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។ និន្នាការកើនឡើងនៃការទូទាត់តាមឌីជីថលក៏ទាមទារឱ្យមានការត្រួតពិនិត្យយ៉ាងជិតដល់ និងការការពារលំហូរសាច់ប្រាក់ និងសុវត្ថិភាពនៃប្រតិបត្តិការទូទាត់ ព្រមទាំងលើកកម្ពស់ការការពារអ្នកប្រើប្រាស់ ដើម្បីរក្សាទំនុកចិត្តសាធារណៈ។ ធនាគារជាតិនៃកម្ពុជាបានបន្តលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងឌីជីថល ជាពិសេសក្នុងចំណោមប្រជាជនវ័យក្មេងដែលមានបំណងទទួលយកសេវាកម្មហិរញ្ញវត្ថុឌីជីថល។ ទន្ទឹមនេះ សន្តិសុខសាយប័រ និងការការពារអ្នកប្រើប្រាស់ ក៏ត្រូវបានពង្រឹងផងដែរ ដើម្បីធានាបាននូវស្ថិរភាពនៅក្នុងប្រព័ន្ធធនាគារ។ លើសពីនេះ ការត្រួតពិនិត្យដល់ទីកន្លែង និងតាមឯកសារ ត្រូវបានអនុវត្តជាបន្តបន្ទាប់ ដើម្បីតាមដានវឌ្ឍនភាពអាជីវកម្ម និងបញ្ហាប្រឈម ព្រមទាំងដាក់ចេញនូវអនុសាសន៍កែតម្រូវនានាសម្រាប់ការកាត់បន្ថយហានិភ័យ។

**៤.៨ ទំហំនិងចំនួនប្រតិបត្តិការនៃការទូទាត់តាម QR កូដ**

(ឆ្នាំ២០១៩ - ២០២២)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ឧបសម្ព័ន្ធទី១

### តារាងទី១៖ ជញ្ជីងទូទាត់កម្ពុជា

(ភាគរយនៃផ.ស.ស., ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| សមតុល្យជញ្ជីងទូទាត់ | ៧,១ | ៥,៩ | ៩,៩ | ២,៥ | ០,៣ | ១,១៧ |
| គណនីហិរញ្ញវត្ថុ | ១៤,២ | ១៦,៤ | ១៩,៤ | ៤,៨ | ៣៩,៩ | ២៦,១ |
| គណនីចរន្ត និងដើមទុន | -៦,៩ | -១០,៥ | -៩,៥ | -២,៤ | -៣៩,៦ | -២៤,៩ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### តារាងទី២៖ លំហូរវិនិយោគផ្ទាល់បរទេសតាមវិស័យ

(ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| លំហូរវិនិយោគផ្ទាល់បរទេស (ប៊ីលានដុល្លារអាមេរិក) | ២,៨ | ៣,២ | ៣,៧ | ៣,៦ | ៣,៥ | ៣,៦ |
| កសិកម្ម | ០,២ | ០,២ | ០,២ | ០,២ | ០,១ | ០,១ |
| អាជីវកម្មធនធានរ៉ែ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| កម្មន្តសាល | ០,៤ | ០,៤ | ០,៦ | ០,៦ | ០,៧ | ០,៨ |
| ហិរញ្ញវត្ថុ | ១,០ | ១,១ | ១,២ | ១,៤ | ១,៣ | ១,១ |
| ការស្នាក់នៅ | ០,៣ | ០,៤ | ០,៥ | ០,៤ | ០,២ | ០,២ |
| ទូរគមនាគមន៍ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| សំណង់និងអចលនទ្រព្យ | ០,៥ | ០,៦ | ០,៧ | ០,៦ | ០,៦ | ០,៨ |
| ផ្សេងៗ | ០,៥ | ០,៤ | ០,៤ | ០,៤ | ០,៤ | ០,៥ |
| កំណើនសរុប (ភាគរយ) | ១២,៦ | ១៥,២ | ១៤,០ | -១,០ | -៣,៩ | ២,៧ |

ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

### តារាងទី៣៖ អត្រាប្តូរប្រាក់

(ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាម (NEER) | ៩៧,៤ | ៩៩,២ | ៩៧,៨ | ៩៨,៧ | ១០០,៩ | ៩៧,៦ |
| អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិត (REER) | ៩៤,៦ | ៩៦,១ | ៩៤,៩ | ៩៤,២ | ៩៤,៩ | ៩១,៧ |
| ប្រាក់រៀលធៀបនឹងដុល្លារអាមេរិក | ៤.០៥១ | ៤.០៥១ | ៤.០៦១ | ៤.០៩៣ | ៤.០៩៩ | ៤.១០២ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី៤៖ ទុនបម្រុងអន្តរជាតិ

(ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ទុនបម្រុងអន្តរជាតិ (ប៊ីលានដុល្លារអាមេរិក) | ១២,២ | ១៤,៦ | ១៨,៨ | ២១,៣ | ២០,៣ | ១៧,៨ |
| ចំនួនខែនៃការនាំចូលទំនិញនិងសេវា | ៨,០ | ៨,០ | ៨,៦ | ១០,០ | ៨,៣ | ៧,០ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី៥៖ កំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ

(ភាគរយ, ឆ្នាំ២០១៧-២០២២ប)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ប |
|---|---|---|---|---|---|---|
| កសិកម្ម | ១,៧ | ១,១ | -០,៥ | ០,៦ | ១,២ | ០,៣ |
| កាត់ដេរ | ៥,៨ | ៩,៦ | ៦,៦ | -៦,១ | ១២,៧ | ១២,៩ |
| សំណង់ | ១៨,០ | ១៧,៥ | ២០,៨ | -១,៨ | ១,១ | ០,៥ |
| ពាណិជ្ជកម្ម អចលនទ្រព្យ និងហិរញ្ញវត្ថុ | ៧,៥ | ៧,៣ | ៦,៩ | -៤,៧ | -១,០ | ២,៦ |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ៥,៩ | ៥,៥ | ៣,១ | -៣២,២ | -៣៩,៥ | ១៨,២ |
| ផ្សេងៗ | ៨,១ | ៧,៧ | ៨,១ | ១,៤ | ៦,៥ | ៥,៤ |
| កំណើន ផ.ស.ស. | ៧,០ | ៧,៥ | ៧,១ | -៣,១ | ៣,០ | ៥,២ |

ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## តារាងទី៦៖ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ

(ភាគរយ, ឆ្នាំ២០១៧-២០២២ប)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ប |
|---|---|---|---|---|---|---|
| កសិកម្ម | ០,៣ | ០,២ | -០,១ | ០,១ | ០,២ | ០,១ |
| កាត់ដេរ | ១,០ | ១,៧ | ១,២ | -១,១ | ២,៣ | ២,៥ |
| សំណង់ | ១,៥ | ១,៦ | ២,០ | -០,២ | -០,១ | ០,១ |
| ពាណិជ្ជកម្ម អចលនទ្រព្យ និងហិរញ្ញវត្ថុ | ១,៤ | ១,៣ | ១,២ | -០,៨ | -០,២ | ០,៤ |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ០,៣ | ០,៣ | ០,២ | -១,៥ | -១,៣ | ០,៣ |
| ផ្សេងៗ | ២,៥ | ២,៤ | ២,៥ | ០,៤ | ២,១ | ១,៨ |
| កំណើន ផ.ស.ស. | ៧,០ | ៧,៥ | ៧,១ | -៣,១ | ៣,០ | ៥,២ |

ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## តារាងទី៧៖ ចំនួនភ្ញៀវអន្តរជាតិបែងចែកតាមគោលបំណង

(លាននាក់, ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| កម្សាន្ត | ៥,០ | ៥,៣ | ៥,០ | ១,០ | ០,១ | ១,៨ |
| ធុរកិច្ច និងការងារ | ០,៤ | ០,៧ | ១,៤ | ០,៣ | ០,១ | ០,៤ |
| ផ្សេងៗ | ០,២ | ០,២ | ០,២ | ០,១ | ០,០ | ០,១ |
| ចំនួនភ្ញៀវអន្តរជាតិសរុប | ៥,៦ | ៦,២ | ៦,៦ | ១,៣ | ០,២ | ២,៣ |
| កំណើនភ្ញៀវអន្តរជាតិ (ភាគរយ, ឆ្នាំលើឆ្នាំ) | ១១,៨ | ១០,៧ | ៦,៦ | -៨០,២ | -៨៥,០ | ១.០៥៨,៦ |

ប្រភព៖ ក្រសួងទេសចរណ៍

## តារាងទី៨៖ ទេសចរក្នុងស្រុក

(លាននាក់, ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| រាជធានីភ្នំពេញ | ២,៧ | ២,៤ | ២,៤ | ១,៨ | ១,២ | ២,៤ |
| ខេត្តសៀមរាប | ៣,១ | ៣,២ | ២,១ | ០,៧ | ០,៤ | ២,៤ |
| តំបន់ឆ្នេរ | ៣,១ | ៣,៣ | ៣,២ | ២,៩ | ២,១ | ៧,១ |
| តំបន់អេកូទេសចរណ៍ | ០,៥ | ០,៦ | ០,៧ | ០,៦ | ០,៤ | ០,៧ |
| ចំនួនទេសចរក្នុងស្រុកសរុប | ១០,៩ | ១១,១ | ១១,៣ | ៧,២ | ៤,៧ | ១៣,៩ |
| កំណើនទេសចរក្នុងស្រុក (ភាគរយ, ឆ្នាំលើឆ្នាំ) | ២,១ | ១,៨ | ២,៣ | -៣៦,១ | -៣៥,៥ | ១៩៨,៨ |

ប្រភព៖ ក្រសួងទេសចរណ៍

## តារាងទី៩៖ សន្ទស្សន៍ថ្លៃលំនៅដ្ឋាន

(ឆ្នាំ២០២១-២០២២)

| ២០២១ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សន្ទស្សន៍ថ្លៃរួម | ១០៣ | ១០៤,៦ | ១០៦,៤ | ១០៩,២ | ១១១,៨ | ១១៣,៥ | ១១៣ | ១១២,១ | ១១១ | ១១១ | ១១០,២ | ១១១ |
| រាជធានីភ្នំពេញ | ១០៤,១ | ១០៥,៧ | ១០៧,៧ | ១១០,៥ | ១១៣ | ១១៤,៧ | ១១៤,៤ | ១១៣,៣ | ១១២,២ | ១១២,៤ | ១១១,៦ | ១១២,២ |
| បណ្តាខេត្តផ្សេងទៀត | ៩៤,៩ | ៩៦,២ | ៩៦,៤ | ៩៩,៦ | ១០២,៥ | ១០៤,៤ | ១០២,៨ | ១០៣ | ១០២,៤ | ១០០,៦ | ១០០ | ១០១,៥ |

| ២០២២ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សន្ទស្សន៍ថ្លៃរួម | ១១០,៧ | ១១១,៩ | ១១១,២ | ១០៩,៤ | ១០៨,៦ | ១០៩ | ១១១,៩ | ១១៣,៥ | ១១៤,៦ | ១១៥,១ | ១១៤,៧ | ១១៤,៨ |
| រាជធានីភ្នំពេញ | ១១២,២ | ១១៣,៩ | ១១៣,៣ | ១១១,១ | ១០៩,៨ | ១១០,៤ | ១១៣,៦ | ១១៥,៤ | ១១៦,៥ | ១១៦,៨ | ១១៦ | ១១៦ |
| បណ្តាខេត្តផ្សេងទៀត | ១០០,៦ | ៩៩,៥ | ៩៧,៩ | ៩៨,៩ | ១០០,៤ | ១០០,៣ | ១០១,១ | ១០២,១ | ១០២,៤ | ១០៤ | ១០៧ | ១០៧,៦ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី១០៖ ការរួមចំណែកក្នុងអតិផរណា

(ការប្រែប្រួលប្រចាំឆ្នាំគិតជាភាគរយ, ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| អតិផរណា | ២,៩ | ២,៥ | ១,៩ | ២,៩ | ២,៩ | ៥,៤ |
| ក្រុមម្ហូបអាហារ | ១,៨ | ១,៣ | ១,១ | ២,៥ | ១,៥ | ២,៧ |
| ក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ | ០,២ | ០,៤ | -០,១ | -០,៣ | ០,៨ | ១,១ |
| ក្រុមអតិផរណាស្នូល | ០,៩ | ០,៧ | ០,៩ | ០,៧ | ០,៦ | ១,៥ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី១១៖ ដុល្លារូបនីយកម្មហិរញ្ញវត្ថុ

(ភាគរយ, ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| សមាមាត្រប្រាក់បញ្ញើជារូបិយប័ណ្ណ ធៀបនឹងរូបិយវត្ថុទូទៅ | ៨៣,៨ | ៨៥,៧ | ៨៤,១ | ៨៣,៩ | ៨៣,០ | ៨៣,០ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ ធៀបនឹងប្រាក់បញ្ញើសរុប | ៩៣,៤ | ៩៤,១ | ៩៣,៥ | ៩៣,១ | ៩១,៤ | ៩០,៤ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ឧបសម្ព័ន្ធទី២

### តារាងទី១២៖ សូចនាករវិស័យធនាគារធៀបនឹងផ.ស.ស.

(ភាគរយ, ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ទ្រព្យសកម្មធៀបនឹងផ.ស.ស. | ១៥១ | ១៦៧ | ១៨៩ | ២២៥ | ២៥១ | ២៦៤ |
| ឥណទានធៀបនឹងផ.ស.ស. | ៩៣ | ១០៤ | ១២០ | ១៤៥ | ១៦៩ | ១៨៣ |
| ប្រាក់បញ្ញើធៀបនឹងផ.ស.ស. | ៨៦ | ១០០ | ១០៨ | ១២៨ | ១៤៣ | ១៤៦ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### តារាងទី១៣៖ ឥណទាន និងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជតាមប្រភេទរូបិយវត្ថុ

(ឆ្នាំ២០១៧-២០២២)

| ឥណទាន | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ឥណទានជារៀល (ទ្រីលានរៀល) | ១,២ | ៣,៥ | ១០,៧ | ១៥,០ | ១៨,២ | ២០,៧ |
| ឥណទានជាដុល្លារអាមេរិក (ទ្រីលានរៀល) | ៦៤,៧ | ៧៨,៣ | ៩២,៨ | ១១២,៥ | ១៤២,៥ | ១៦៨,០ |
| សមាមាត្រឥណទានជារៀល (ភាគរយ) | ១,៩ | ៤,៣ | ១០,៤ | ១១,៨ | ១១,៤ | ១១,០ |
| **ប្រាក់បញ្ញើ** | **២០១៧** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២** |
| ប្រាក់បញ្ញើជារូបិយវត្ថុជាតិ (ទ្រីលានរៀល) | ៤,១ | ៥,៤ | ៧,៥ | ៩,៥ | ១៣,៦ | ១៩,៥ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស (ទ្រីលានរៀល) | ៦៥,៥ | ៨៣,២ | ៩៦,០ | ១១១,៧ | ១២៩,២ | ១៥៤,៩ |
| សមាមាត្រនៃប្រាក់បញ្ញើជារូបិយវត្ថុជាតិ (ភាគរយ) | ៥,៩ | ៦,១ | ៧,៣ | ៧,៩ | ៩,៦ | ១១,២ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### តារាងទី១៤៖ ឥណទានធនាគារពាណិជ្ជទៅតាមវិស័យ - តម្លៃ និងសមាមាត្រ

(ឆ្នាំ២០១៧-២០២២)

| តម្លៃ (ទ្រីលានរៀល) | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៦,៥ | ៦,៨ | ៧,១ | ៩,៨ | ១២,៨ | ១៥,៥ |
| ឧស្សាហកម្មរ៉ែ | ០,២ | ០,២ | ០,២ | ០,៥ | ០,៧ | ០,៩ |
| កម្មន្តសាល | ៤,២ | ៤,៥ | ៤,៦ | ៥,២ | ៦,៣ | ៨,១ |

| | | | | | | |
|---|---|---|---|---|---|---|
| ការផ្គត់ផ្គង់សេវាសាធារណៈ | ០,៥ | ០,៥ | ០,៩ | ១,៦ | ២,០ | ១,៩ |
| សំណង់ | ៦,២ | ៧,៦ | ៩,៩ | ១២,៥ | ១៥,៣ | ១៨,១ |
| ការជួញដូរដុំ | ៨,៣ | ៩,៥ | ១១,៧ | ១២,៧ | ១៥,៤ | ១៨,៥ |
| ការជួញដូររាយ | ១១,៨ | ១៣,៤ | ១៦,២ | ១៩,៨ | ២៥,៩ | ៣០,៧ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៣,០ | ៣,៩ | ៤,៧ | ៥,១ | ៧,២ | ៨,៣ |
| ដឹកជញ្ជូន និងស្តុកបណ្តោះអាសន្ន | ១,២ | ១,៦ | ២,០ | ៣,៤ | ៤,៤ | ៤,៩ |
| បណ្តាញព័ត៌មាន និងទូរគមនាគមន៍ | ០,៥ | ០,៧ | ០,៩ | ១,១ | ១,២ | ០,៩ |
| អាជីវកម្មជួល និងភតិសន្យាប្រតិបត្តិការ | ១,៥ | ២,៦ | ៣,៨ | ៣,៥ | ២,៦ | ២,៧ |
| អចលនទ្រព្យ | ៣,៨ | ៦,១ | ៨,៦ | ១០,៨ | ១៤,១ | ១៨,០ |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងទៀត | ៤,៩ | ៥,៧ | ៦,៣ | ៦,៨ | ៨,៤ | ១០,០ |
| ឥណទានបុគ្គល | ៤,៥ | ៦,៦ | ៨,៤ | ១១,៤ | ១៤,០ | ១៤,១ |
| ឥណទានទិញផ្ទះ | ៦,២ | ៨,៤ | ១២,១ | ១៧,០ | ២២,៣ | ២៧,៣ |
| ឥណទានផ្សេងទៀត | ០,៩ | ១,០ | ១,២ | ១,១ | ២,២ | ២,៥ |
| សរុប | ៦៤,៨ | ៧៩,៧ | ៩៩,៤ | ១២២,៩ | ១៥៥,៣ | ១៨៣,៤ |

| សមាមាត្រ (ភាគរយ) | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១០,០ | ៨,៥ | ៧,១ | ៨,០ | ៨,២ | ៨,៤ |
| ឧស្សាហកម្មរ៉ែ | ០,៣ | ០,២ | ០,២ | ០,៤ | ០,៤ | ០,៥ |
| កម្មន្តសាល | ៦,៥ | ៥,៦ | ៤,៧ | ៤,២ | ៤,១ | ៤,៤ |
| ការផ្គត់ផ្គង់សេវាសាធារណៈ | ០,៧ | ០,៧ | ០,៩ | ១,៣ | ១,៣ | ១,០ |
| សំណង់ | ៩,៦ | ៩,៥ | ១០,០ | ១០,១ | ៩,៨ | ៩,៩ |
| ការជួញដូរដុំ | ១២,៨ | ១១,៩ | ១១,៨ | ១០,៣ | ៩,៩ | ១០,១ |
| ការជួញដូររាយ | ១៨,២ | ១៦,៨ | ១៦,៣ | ១៦,១ | ១៦,៧ | ១៦,៧ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៤,៧ | ៥,០ | ៤,៧ | ៤,១ | ៤,៦ | ៤,៥ |
| ដឹកជញ្ជូន និងស្តុកបណ្តោះអាសន្ន | ១,៩ | ២,០ | ២,០ | ២,៨ | ២,៨ | ២,៧ |
| បណ្តាញព័ត៌មាន និងទូរគមនាគមន៍ | ០,៨ | ០,៨ | ០,៩ | ០,៩ | ០,៨ | ០,៥ |

| | | | | | | |
|---|---|---|---|---|---|---|
| អាជីវកម្មជួល និងភតិសន្យាប្រតិបត្តិការ | ២,៤ | ៣,៣ | ៣,៨ | ២,៩ | ១,៧ | ១,៥ |
| អចលនទ្រព្យ | ៦,០ | ៧,៦ | ៨,៧ | ៨,៨ | ៩,០ | ៩,៨ |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងទៀត | ៧,៥ | ៧,១ | ៦,៣ | ៥,៥ | ៥,៤ | ៥,៤ |
| ឥណទានបុគ្គល | ៧,០ | ៨,៣ | ៨,៤ | ៩,៣ | ៩,០ | ៧,៧ |
| ឥណទានទិញផ្ទះ | ៩,៥ | ១០,៦ | ១២,១ | ១៣,៨ | ១៤,៣ | ១៤,៩ |
| ឥណទានផ្សេងទៀត | ១,៤ | ១,២ | ១,២ | ០,៨ | ១,៤ | ១,៤ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី១៥៖ អនុបាតគ្របខ័ណ្ឌសន្ទនីយភាពរបស់ធនាគារពាណិជ្ជ

(ភាគរយ, ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| កម្រិតអប្បបរមា | ៧០ | ៨០ | ៩០ | ១០០ | ១០០ | ១០០ |
| អនុបាតគ្របខ័ណ្ឌសន្ទនីយភាពជាក់ស្តែង | ១៣៩,៥ | ១៥៨,៧ | ១៥៥,៧ | ១៦២,៤ | ១៥១,៦ | ១៤៣,៨ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី១៦៖ សមាមាត្រប្រភពមូលនិធិធនាគារពាណិជ្ជ

(ភាគរយ, ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ប្រាក់បញ្ញើចរន្ត | ១៦ | ១៧ | ១៧ | ១៥ | ១៦ | ១៣ |
| ប្រាក់បញ្ញើសន្សំ | ២២ | ២៥ | ២២ | ២១ | ២០ | ១៨ |
| ប្រាក់បញ្ញើមានកាលកំណត់ | ៣០ | ២៨ | ២៩ | ៣០ | ៣០ | ៣២ |
| ផ្សេងៗ | ០ | ០ | ០ | ០ | ០ | ១ |
| កម្ចីរយៈពេលខ្លីជាង១ឆ្នាំ | ៣ | ៣ | ៥ | ៥ | ៤ | ៥ |
| កម្ចីរយៈពេលវែងជាង១ឆ្នាំ | ៨ | ៥ | ៥ | ៧ | ៧ | ៨ |
| កម្ចីជាដើមទុនរយៈពេលវែងជាង១ឆ្នាំ | ១ | ១ | ២ | ២ | ២ | ១ |
| ដើមទុន | ២០ | ២០ | ២០ | ២១ | ២១ | ២១ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី១៧៖ ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និងមូលនិធិភាគទុនិករបស់ធនាគារពាណិជ្ជ

(ភាគរយ, ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម | ១,៥ | ១,៥ | ១,៨ | ១,៦ | ១,៧ | ១,៣ |
| មូលនិធិភាគទុនិក | ៨,៧ | ៨,៦ | ១០,១ | ៨,៧ | ៨,៩ | ៧,០ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី១៨៖ ភាពគ្រប់គ្រាន់នៃដើមទុនរបស់ធនាគារពាណិជ្ជ

(ភាគរយ, ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| កម្រិតបទប្បញ្ញត្តិ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ |
| ដើមទុនថ្នាក់ទី១ | ២១,៣ | ២១,២ | ២០,០ | ២០,២ | ២០,០ | ១៩,៤ |
| អនុបាតសាធនភាព | ២២,៩ | ២៣,៤ | ២៣,០ | ២៣,១ | ២២,៩ | ២២,២ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី១៩៖ ទ្រព្យសកម្មក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

(ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ចំនួន (ទ្រីលានរៀល) | ២០,៣ | ២៦,៦ | ៣៥,៩ | ៣៤,៣ | ៣៧,១ | ៤៤,៤ |
| កំណើន (ភាគរយ) | ៣០,៦ | ៣១,២ | ៣៤,៧ | -៤,៥ | ៨,១ | ១៩,៨ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី២០៖ ឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៅតាមវិស័យ - តម្លៃ និងសមាមាត្រ

(ឆ្នាំ២០១៧-២០២២)

| តម្លៃ (ទ្រីលានរៀល) | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| កសិកម្ម | ៤,៤ | ៤,៦ | ៥,៧ | ៥,៣ | ៥,៧ | ៦,៩ |
| កម្មន្តសាល | ០,១ | ០,១ | ០,២ | ០,៣ | ០,៥ | ០,៧ |
| ពាណិជ្ជកម្ម និងទំនិញ | ៣,២ | ៣,៨ | ៥,៤ | ៥,៨ | ៧,៣ | ៩,១ |
| សេវាកម្ម | ១,៨ | ២,៤ | ៤,២ | ៤,៤ | ៤,៦ | ៥,៣ |
| ដឹកជញ្ជូន | ០,៨ | ១,១ | ១,៧ | ១,៦ | ១,៦ | ១,៧ |

| | | | | | | |
|---|---|---|---|---|---|---|
| សំណង់ | ០,៧ | ០,៩ | ១,០ | ៨,៦ | ១០,៣ | ១២,៩ |
| អង្គភាពគ្រួសារ | ៥,៨ | ៨,០ | ១០,០ | ៨,៦ | ១០,៣ | ១២,៩ |
| ផ្សេងៗ | ០,៤ | ០,៨ | ១,១ | ០,៥ | ០,៤ | ០,៥ |
| សរុប | ១៧,២ | ២១,៨ | ២៩,៣ | ២៧,៥ | ៣១,៧ | ៣៨,៩ |
| **សមាមាត្រ (ភាគរយ)** | **២០១៧** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២** |
| កសិកម្ម | ២៥,៥ | ២១,១ | ១៩,៤ | ១៩,៣ | ១៧,៩ | ១៧,៨ |
| កម្មន្តសាល | ០,៧ | ០,៧ | ០,៨ | ១,០ | ១,៦ | ១,៨ |
| ពាណិជ្ជកម្ម និងទំនិញ | ១៨,៨ | ១៧,៦ | ១៨,៣ | ២០,៩ | ២៣,០ | ២៣,៣ |
| សេវាកម្ម | ១០,៤ | ១១,០ | ១៤,៤ | ១៦,០ | ១៤,៤ | ១៣,៦ |
| ដឹកជញ្ជូន | ៤,៦ | ៥,០ | ៥,៧ | ៥,៩ | ៥,២ | ៤,៤ |
| សំណង់ | ៤,០ | ៤,២ | ៣,៥ | ៣,៨ | ៤,៣ | ៤,៥ |
| អង្គភាពគ្រួសារ | ៣៣,៨ | ៣៦,៧ | ៣៤,២ | ៣១,២ | ៣២,៤ | ៣៣,២ |
| ផ្សេងៗ | ២,២ | ៣,៨ | ៣,៦ | ១,៩ | ១,១ | ១,៣ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី២១៖ អនុបាតក្របខ័ណ្ឌសន្ទនីយភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

(ភាគរយ, ឆ្នាំ២០១៧-២០២២)

| | **២០១៧** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២** |
|---|---|---|---|---|---|---|
| អនុបាតក្របខ័ណ្ឌសន្ទនីយភាពរបស់ MDIs | ១៥៩,៥ | ២១៣,៦ | ១៧០,១ | ២៤០,៤ | ១៦០,១ | ១៥៦,៦ |
| កម្រិតបទប្បញ្ញត្តិ | ៧០ | ៨០ | ៩០ | ១០០ | ១០០ | ១០០ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី២២៖ គុណភាពឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

(ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ឥណទានហួសកាលកំណត់ទូទាត់សងរយៈពេល ៣០ថ្ងៃ (ប៊ីលានរៀល) | ២៧១,៦ | ២៧៥,៥ | ២២៤,៣ | ៥០១,៩ | ៧៦៥,៤ | ៩៧៩,៩ |
| អនុបាតឥណទានមិនដំណើរការ (ភាគរយ) | ១,៦ | ១,៣ | ០,៨ | ១,៨ | ២,៤ | ២,៥ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី២៣៖ ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និងមូលនិធិភាគទុនិក របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

(ភាគរយ, ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម | ២,៧ | ២,៧ | ២,៨ | ២,៨ | ២,៨ | ៣,០ |
| មូលនិធិភាគទុនិក | ១២,៨ | ១៣,៥ | ១៤,៨ | ១២,៤ | ១២,៧ | ១៣,៦ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី២៤៖ ស្ថានភាពដើមទុនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

(ភាគរយ, ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| កម្រិតបទប្បញ្ញត្តិ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ |
| អនុបាតសាធនភាព | ១៦,៩ | ១៦,៤ | ១៦,២ | ១៩,៨ | ១៨,២ | ១៨,៦ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

# ឧបសម្ព័ន្ធទី៣

## ទីផ្សារមូលបត្រកម្ពុជា
### ទីផ្សារគោល
(គិតជារៀលក្នុងមួយភាគហ៊ុន)



**ធនាគារ អេស៊ីលីដា**
(ខែធ្នូ ឆ្នាំ២០២១ - ខែធ្នូ ឆ្នាំ២០២២)



**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**
(ខែធ្នូ ឆ្នាំ២០២១ - ខែធ្នូ ឆ្នាំ២០២២)



**កំពង់ផែស្វយ័តក្រុងភ្នំពេញ**
(ខែធ្នូ ឆ្នាំ២០២១ - ខែធ្នូ ឆ្នាំ២០២២)



**ផេសថិក (ខេមបូឌា)**
(ខែធ្នូ ឆ្នាំ២០២១ - ខែធ្នូ ឆ្នាំ២០២២)



**ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា)**
(ខែធ្នូ ឆ្នាំ២០២១ - ខែធ្នូ ឆ្នាំ២០២២)



**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
(ខែធ្នូ ឆ្នាំ២០២១ - ខែធ្នូ ឆ្នាំ២០២២)



**ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត**
(ខែធ្នូ ឆ្នាំ២០២១ - ខែធ្នូ ឆ្នាំ២០២២)

ប្រភព៖ ផ្សារមូលបត្រកម្ពុជា

## ទីផ្សារកំណើន

(គិតជារៀលក្នុងមួយភាគហ៊ុន)







ប្រភព៖ ផ្សារមូលបត្រកម្ពុជា

## តារាងទី២៥៖ ទំហំមូលនិធិភាគទុនិកមូលធនូបនីយកម្មទីផ្សារ

(ប៊ីលានរៀល, ឆ្នាំ២០១៧-២០២២)

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ធនាគារអេស៊ីលីដា (ABC) | - | - | - | ៧.៤០៧,១ | ៤.៥៥៦,៩ | ៤.៦៨៦,៨ |
| កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS) | ៤៣៧,៤ | ៨៦៦,៣ | ១.៦៦៤,០ | ១.២៨០,០ | ១.១៩២,៥ | ១.១៩២,៥ |
| រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) | ៣៣៥,៧ | ៣៦៥,៣ | ៥២១,៨ | ៥៣០,៥ | ៦២២,៧ | ៦៥៧,៥ |
| កំពង់ផែស្វយ័តក្រុងភ្នំពេញ (PPAP) | ១០៦,៣ | ១៥៨,៩ | ២៥៨,៦ | ២៤២,០ | ៣០៨,១ | ២៨៩,៦ |
| ផេសថិក (ខេមបូឌា) ម.ក (PESTECH) | - | - | - | ២១៧,៣ | ២៣៦,១ | ២៣៦,១ |
| ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP) | ១៦៣,២ | ២០៨,៤ | ១៨៥,៤ | ៨៤,៨ | ១៩៨,៨ | ១៧១,៨ |
| ហ្គ្រេនធ្វីនអ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (GTI) | ១៨៨,០ | ១៧២,៨ | ១៧៦,០ | ១២៨,០ | ១៦៨,៨ | ១៥២,០ |
| ឌីប៊ីឌី អ៊ិនជីនារីង ម.ក (DBDE) | - | - | - | - | ១៤,៩ | ១៥,៤ |
| ជេអេស លែន ភីអិលស៊ី (JSL) | - | - | - | - | - | ១២៧,៥ |
| សរុប | ១.២៣០,៦ | ១.៧៧១,៧ | ២.៨០៥,៨ | ៩.៨២៧,៧ | ៧.១៩៩,៨ | ៧.៤៧៩,២ |

ប្រភព៖ ទីផ្សារមូលបត្រកម្ពុជា (CSX)

## តារាងទី២៦៖ មូលបត្ររដ្ឋ

(ខែកញ្ញា ឆ្នាំ២០២២ - ខែមេសា ឆ្នាំ២០២៣)

| កាលបរិច្ឆេទបោះផ្សាយ | កញ្ញា-២២ | វិច្ឆិកា-២២ | ធ្នូ-២២ | មករា-២៣ | កុម្ភៈ-២៣ | មីនា-២៣ | មេសា-២៣ |
|---|---|---|---|---|---|---|---|
| បរិមាណមូលបត្ររដ្ឋសរុប (ឯកតា) | ៩១.៨០០ | ២៤.៣០០ | ៦.០០០ | ២៥.០០០ | ៧២.០០០ | ៩.០០០ | ៩.០០០ |
| តម្លៃចារឹក | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ |
| តម្លៃបោះផ្សាយ | ៩៩៨.០៣៣ | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ | ៩៩៨.៨៣២ |
| ឥណប្រតិទាន | ១ ឆ្នាំ | ១ ឆ្នាំ | ១ ឆ្នាំ | ១ ឆ្នាំ | ១ ឆ្នាំ | ៣ ឆ្នាំ | ១ ឆ្នាំ |
| អត្រាគូប៉ុង | ២,០ | ២,២ | ២,២ | ៣,៤ | ៤,០ | ៤,២ | ៣,៤ |
| អត្រាការប្រាក់ (ភាគរយក្នុង ១ឆ្នាំ) | ២,២ | ២,២ | ២,២ | ៣,៦ | ៤,១ | ៤,៥ | ៤,០ |
| ចំនួនដងនៃការទូទាត់គូប៉ុង | ២ ដង | ២ ដង | ២ ដង | ២ ដង | ២ ដង | ២ ដង | ២ ដង |

ប្រភព៖ ទីផ្សារមូលបត្រកម្ពុជា (CSX)

## តារាងទី២៧៖ វិស័យធានារ៉ាប់រង

(ឆ្នាំ២០១៩-២០២២)

ទ្រព្យសកម្មសរុប

| ប៊ីលានរៀល | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|
| ធានារ៉ាប់រងទូទៅ | ២៤៦.៩៩៤,៣ | ២៧៦.៣១៦,៧ | ២៩៣.៦៣២,៩ | ៣០៨.៩៧៦,៩ |
| ធានារ៉ាប់អាយុជីវិត | ៣៤៤.៦២២,៤ | ៤៦១.៨២៩,៦ | ៥៥១.៧៥៩,០ | ៦៦២.៧៦៣,៤ |
| ធានារ៉ាប់រងខ្នាតតូច | ៦.០៤៨,៣ | ៣.២៥៧,០ | ៥.២៥០,៨ | ៥.២៤៦,៨ |
| សរុប | ៥៩៧.៦៦៥,១ | ៧៤១.៤០៣,២ | ៨៥០.៦៤២,៧ | ៩៧៦.៩៨៧,១ |
| **សមាមាត្រ (ភាគរយ)** | **២០១៩** | **២០២០** | **២០២១** | **២០២២** |
| ធានារ៉ាប់រងទូទៅ | ៤១,៣ | ៣៧,៣ | ៣៤,៥ | ៣១,៦ |
| ធានារ៉ាប់អាយុជីវិត | ៥៧,៧ | ៦២,៣ | ៦៤,៩ | ៦៧,៨ |
| ធានារ៉ាប់រងខ្នាតតូច | ១,០ | ០,៤ | ០,៦ | ០,៥ |

### បុព្វលាភសរុប

| ប៊ីលានរៀល | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|
| ធានារ៉ាប់រងទូទៅ | ៤១០,៨ | ៤៦៦,៨ | ៥០២,៧ | ៥៤០,៩ |
| ធានារ៉ាប់រងអាយុជីវិត | ៥៨៥,១ | ៦២៥,៤ | ៧០០,១ | ៧៩២,២ |
| ធានារ៉ាប់រងខ្នាតតូច | ២៨,៦ | ២០,៥ | ១៦,៨ | ២៣,៤ |
| សរុប | ១.០២៤,៦ | ១.១១២,៧ | ១.២១៩,៦ | ១.៣៥៦,៤ |

### បុព្វលាភធានារ៉ាប់រងទូទៅ

| ប៊ីលានរៀល | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|
| យានយន្ត | ៧៦,៦ | ៨៥,៨ | ៨៧,៩ | ៩៦,៦ |
| ទ្រព្យសម្បត្តិ | ១១៩,០ | ១៥២,៩ | ១៥២,៩ | ១៨៤,៨ |
| MAT | ១៥,៧ | ១១,៧ | ១៧,៣ | ៣០,៥ |
| វិស្វកម្ម | ៤១,៥ | ៣៤,៨ | ៣៦,៨ | ២៤,៤ |
| គ្រោះថ្នាក់បុគ្គល | ២៤,២ | ២០,៨ | ២៣,៣ | ២៨,១ |
| សុខភាព | ៧៤,៤ | ៨៨,១ | ១០៩,៩ | ១២៥,៨ |
| ផ្សេងៗ | ៥៩,៤ | ៧២,៦ | ៧៤,៦ | ៥០,៩ |
| សរុប | ៤១០,៨ | ៤៦៦,៨ | ៥០២,៧ | ៥៤០,៩ |
| **សមាមាត្រ (ភាគរយ)** | **២០១៩** | **២០២០** | **២០២១** | **២០២២** |
| យានយន្ត | ១៨,៧ | ១៨,៤ | ១៧,៥ | ១៧,៨ |
| ទ្រព្យសម្បត្តិ | ២៩,០ | ៣២,៨ | ៣០,៤ | ៣៤,២ |
| MAT | ៣,៨ | ២,៥ | ៣,៤ | ៥,៦ |
| វិស្វកម្ម | ១០,១ | ៧,៥ | ៧,៣ | ៤,៥ |
| គ្រោះថ្នាក់បុគ្គល | ៥,៩ | ៤,៥ | ៤,៦ | ៥,២ |
| សុខភាព | ១៨,១ | ១៨,៩ | ២១,៩ | ២៣,៣ |
| ផ្សេងៗ | ១៤,៥ | ១៥,៦ | ១៤,៨ | ៩,៤ |

### បុព្វលាភធានារ៉ាប់រងអាយុជីវិត

| ប៊ីលានរៀល | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|
| មានកាលកំណត់ | ៧៣,១ | ៨៩,២ | ១២៤,០ | ១៥៣,៧ |
| ពេញមួយជីវិតកាល | ២,២ | ៤,៥ | ៥,០ | ៣,២ |
| ទាយជ្ជទាន | ៥០៦,២ | ៥២៥,១ | ៥៦០,២ | ៦៣២,៦ |
| ផ្សេងៗ | ៣,៦ | ៦,៥ | ១១,០ | ២,៦ |
| សរុប | ៥៨៥,១ | ៦២៥,៤ | ៧០០,១ | ៧៩២,២ |
| **សមាមាត្រ (ភាគរយ)** | **២០១៩** | **២០២០** | **២០២១** | **២០២២** |
| មានកាលកំណត់ | ១២,៥ | ១៤,៣ | ១៧,៧ | ១៩,៤ |
| ពេញមួយជីវិតកាល | ០,៤ | ០,៧ | ០,៧ | ០,៤ |
| ទាយជ្ជទាន | ៨៦,៥ | ៨៤,០ | ៨០,០ | ៧៩,៩ |
| ផ្សេងៗ | ០,៦ | ១,០ | ១,៦ | ០,៣ |

### បុព្វលាភធានារ៉ាប់រងខ្នាតតូច

| ប៊ីលានរៀល | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|
| សុខភាព | ១១,២ | ៧,៤ | ៤,៥ | ៣,៩ |
| គ្រោះថ្នាក់បុគ្គល | ៣,៤ | ៣,១ | ២,៣ | ៨,២ |
| មានកាលកំណត់ | ១០,១ | ៧,៧ | ៦,៧ | ២,២ |
| ផ្សេងៗ | ៣,៩ | ២,៣ | ៣,២ | ៩,០ |
| សរុប | ២៨,៦ | ២០,៥ | ១៦,៨ | ២៣,៤ |
| **សមាមាត្រ (ភាគរយ)** | **២០១៩** | **២០២០** | **២០២១** | **២០២២** |
| សុខភាព | ៣៩,១ | ៣៦,១ | ២៦,៩ | ១៦,៧ |
| គ្រោះថ្នាក់បុគ្គល | ១២,០ | ១៥,២ | ១៣,៨ | ៣៥,៣ |
| មានកាលកំណត់ | ៣៥,២ | ៣៧,៥ | ៤០,១ | ៩,៣ |
| ផ្សេងៗ | ១៣,៧ | ១១,២ | ១៩,២ | ៣៨,៧ |

ប្រភព៖ និយ័តករធានារ៉ាប់រងកម្ពុជា

**ឧបសម្ព័ន្ធទី៤**

## តារាងទី២៨៖ ទំហំទឹកប្រាក់នៃការទូទាត់រាយតាមប្រព័ន្ធអេឡិចត្រូនិក

(ទ្រីលានរៀល, ឆ្នាំ២០១៩-២០២២)

| | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|
| ការទូទាត់ជាប្រាក់រៀល | ៥៨,៩ | ៨៩,០ | ១៣៧,៣ | ១៩៧,២ |
| ការទូទាត់ជាប្រាក់ដុល្លារអាមេរិក | ២៨៥,២ | ៤២៩,៤ | ៦៨៧,៩ | ៩១៣,៤ |
| ទំហំទឹកប្រាក់សរុប | ៣៤៤,១ | ៥១៨,៣ | ៨២៥,២ | ១.១១០,៦ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី២៩៖ ចំនួនគណនីកាបូបអេឡិចត្រូនិក និងអតិថិជន Walk-in

(លានគណនី, ឆ្នាំ២០១៩-២០២២)

| | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|
| គណនីកាបូបអេឡិចត្រូនិក | ៥,២ | ៩,៦ | ១៣,៦ | ១៩,៥ |
| អតិថិជន Walk-in | ៤៤,៧ | ៥៦,៥ | ១០៦,២ | ១៣៥,៦ |
| គណនីកាបូបអេឡិចត្រូនិក | ៥,២ | ៩,៦ | ១៣,៦ | ១៩,៥ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី៣០៖ ទំហំទឹកប្រាក់និងចំនួនប្រតិបត្តិការនៃការទូទាត់ តាមគណនីកាបូបអេឡិចត្រូនិក

(ទ្រីលានរៀល, ឆ្នាំ២០១៩-២០២២)

| | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|
| ការទូទាត់ជាប្រាក់រៀល | ៤៩,៨ | ៧០,៧ | ៨៨,៥ | ១១៩,៩ |
| ការទូទាត់ជាប្រាក់ដុល្លារអាមេរិក | ៩១,៤ | ៩៨,១ | ១០៩,៦ | ១៤០,២ |
| ទំហំទឹកប្រាក់សរុប | ១៤១,២ | ១៦៨,៩ | ១៩៨,១ | ២៦០,១ |
| ចំនួនប្រតិបត្តិការសរុប (គិតជាលាន) | ១៩៨,៩ | ២៥៨,៧ | ៣៤៣,៨ | ៤៦៧,៤ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី៣១៖ ទំហំទឹកប្រាក់នៃសេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័ត

(ទ្រីលានរៀល, ឆ្នាំ២០១៩-២០២២)

| | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|
| សេវាធនាគារអ៊ីនធឺណិត | ៩១,៦ | ៩៧,២ | ៩០,១ | ៨០,១ |
| សេវាធនាគារចល័ត | ១១៤,០ | ២៣២,១ | ៤៥២,៩ | ៦៧២,៤ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី៣២៖ ការប្រើប្រាស់ប័ណ្ណទូទាត់

(ទ្រីលានរៀល, ឆ្នាំ២០១៩-២០២២)

| | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|
| ការទូទាត់ជាប្រាក់រៀល | ៣,២ | ៨,០ | ១២,៨ | ២២,៤ |
| ការទូទាត់ជាប្រាក់ដុល្លារអាមេរិក | ៤៤,១ | ៦២,២ | ៧១,៣ | ៧៥,៧ |
| ទំហំទឹកប្រាក់សរុប | ៤៧,៣ | ៧០,២ | ៨៤,១ | ៩៨,០ |
| ចំនួនប្រតិបត្តិការសរុប (គិតជាលាន) | ៧៤,៤ | ៩៧,៣ | ១០៥,៣ | ១១៩,៧ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី៣៣៖ ការទូទាត់តាមប្រព័ន្ធបាគង

(ទ្រីលានរៀល, ឆ្នាំ២០២០-២០២២)

| | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|
| ការទូទាត់ជាប្រាក់រៀល | ០,០៤ | ២,៥ | ១២,៨ |
| ការទូទាត់ជាប្រាក់ដុល្លារអាមេរិក | ០,១៤ | ១១,៨ | ៤៩,៩ |
| ទំហំទឹកប្រាក់សរុប | ០,២ | ១៤,៣ | ៦២,៧ |
| ចំនួនប្រតិបត្តិការសរុប (គិតជាលាន) | ០,២ | ៨,២ | ២៦,១ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាងទី៣៤៖ ការទូទាត់តាមឃ្យូអរកូដ

(ឆ្នាំ២០១៩-២០២២)

| | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|
| ទំហំទឹកប្រាក់សរុប (ប៊ីលានរៀល) | ៨៣,៥ | ២៩៨,១ | ៩៥៣,៧ | ១៣.៦២៦,១ |
| ចំនួនប្រតិបត្តិការសរុប (គិតជាលាន) | ២,១ | ៤,៨ | ៤,៤ | ២៣,៣ |
| ទំហំទឹកប្រាក់សរុប | ៤៧,៣ | ៧០,២ | ៨៤,១ | ៩៨,០ |
| ចំនួនប្រតិបត្តិការសរុប (គិតជាលាន) | ៧៤,៤ | ៩៧,៣ | ១០៥,៣ | ១១៩,៧ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា



បោះពុម្ពដោយ ធនាគារជាតិ នៃកម្ពុជា